# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# វិការៈនៃកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


រៀបចំឡើងដោយ៖

និស្សិតឈ្មោះ **ហោន សុជាតា**

**លី តេខ**

ណែនាំដោយលោកគ្រូ៖

លោក **ខាត់ ធី**


ថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២១

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរនាក់ **លី តេង** និង **ហេន សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី**២៤**នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **ឆ្នាំ ២០២០-២០២៤** សូមលំឱនកាយ វាចាចិត្ត ដើម្បីសម្តែងនូវការដឹងគុណ និង កតញ្ញូធម៌ យ៉ាងជ្រាលជ្រៅជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ ៖

**លោកឪពុក លី សុខាម៉ារ៉ា** **លោកឪពុក ទួន សាមេន**

**អ្នកម្តាយ ជ័យ ពេជ្រផល្លីន** **អ្នកម្តាយ នាង លីណា**

យើងខ្ញុំទាំងពីរនាក់សូមសម្តែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ ថែរក្សាកូនទាំងពីកូនបានកើតរហូត ដល់ធំដឹងក្តីជាមួយការអប់រំល្អៗ និងបានផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មានប្រៀនប្រដៅកូន ឱ្យខិតខំរៀនសូត្រ មានសេចក្តីព្យាយាម និងមានការតស៊ូក្នុងជីវិត។ លោកទាំងពីរបានលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត និងទាំងថវិការយ៉ាងច្រើនដើម្បីផ្គត់ផ្គង់ ដល់ការសិក្សារបស់កូនដើម្បីឲ្យទទួលបាននូវចំណេះដឹងខ្ពង់ខ្ពស់សម្រាប់ខ្លួនឯងនិងជាធនធានមនុស្សដ៏សំខាន់សម្រាប់សង្គមជាតិ។

យើងខ្ញុំសូមថ្លៃអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **លោកគ្រូ ខាត់ ធី** ដែលជាលោកគ្រូណែនាំក្នុងការសរសេរសារណា និងសាស្ត្រាចារ្យទាំងអស់ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសស្ត្រសេដ្ឋកិច្ចដែលបានលះបង់ទាំងកម្លាំងក្លាយ និងកម្លាំងចិត្តដើម្បីបង្ហាត់បង្រៀនគ្រប់និស្សិតទាំងអស់នៅថ្នាក់កន្លងមកឲ្យយល់ដឹងអំពីក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដែរមានការកំណត់យ៉ាងជាក់លាក់អំពីបទបញ្ញត្តិដែលបានកំណត់នៅក្នុងច្បាប់ឲ្យកាន់តែច្បាស់។ ដោយយកចិត្តទុកដាក់ និងបានផ្តល់ដំបូន្មានល្អៗ សម្រាប់កែសម្រួលរាល់ចំណុចខ្វះខាត់របស់និស្សិតគ្រប់ៗ គ្នាអោយទទួលបាននូវចំណេះដឹងថ្មីៗ ដើម្បីឆ្ពោះទៅរកភាពជោគជ័យនាពេលអនាគត។

ជាកិច្ចបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមលើកហត្ថប្រណមបួងសួងដល់បារមីវត្ថុសក្តិសិទ្ធិទេព្តាក្នុងលោកសូមប្រសិទ្ធិពរជ័យសិរីសួស្តីជូនចំពោះ អ្នកមានគុណទាំងពីររបស់យើងខ្ញុំដែលជា **លោកឪពុក និង អ្នកម្តាយ** ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ មិត្តភក្តិទាំងអស់ និង **លោកគ្រូ ខាត់ ធី** ជាអ្នកដឹកនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រា សូមជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ ជោគជ័យគ្រប់ភារកិច្ចការងារ ព្រមទាំងជួបនូវពុទ្ធពរទាំង៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

# អារម្ភកថា

សៀវភៅសារណាដែលកំពុងតែមានវត្តមាននៅក្នុងដៃរបស់លោកអ្នកនេះ គឺត្រូវបានសម្រិតសម្រាំងយ៉ាងខ្លាំងក្នុងការខិតខំស្រាវជ្រាវដោយយកចិត្តទុកដាក់ជាទីបំផុត ដោយដកស្រង់នូវខ្លឹមសារនិងគោលគំនិតប្រកបដោយគុណភាព និង សារៈប្រយោជន៍យ៉ាងចាំបាច់គួរជាទីកត់សម្គាល់បំផុត ដើម្បីយកចងក្រងសៀវភៅនេះឡើងក្នុងគោលបំណងពង្រីកចំណេះដឹងបន្ថែមឲ្យកាន់តែស៊ីជម្រៅលើកិច្ចសន្យា ។

នៅក្នុងសង្គមរស់នៅនាពេលបច្ចុប្បន្ន យើងខ្ញុំបានមើលឃើញថា ការទំនាក់ទំនង រវាងបុគ្គលនឹងបុគ្គល រវាងបុគ្គលនឹងនីតិបុគ្គល ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង និង មានភាពចាំបាច់សម្រាប់បំពេញតម្រូវការក្នុងជីវភាពរស់នៅសព្វថ្ងៃ។ យ៉ាងណាមិញការទំនាក់ទំនងនេះ ប្រាកដណាស់នឹងនាំមកនូវចំណងគតិយុត្តរវាងគូភាគីទាំងសងខាង ដូចនេះក្នុងទំនាក់ទំនងវិស័យជួញដូរ ឬ ជំនួញគឺពិតជាចាំបាច់ណាច់ក្នុងការតម្រូវឲ្យមានកិច្ចសន្យាច្បាស់លាស់។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិ អំពីកិច្ចសន្យាជាច្រើនប្រភេទ ដែលសុទ្ធសឹងជាកិច្ចសន្យាប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃដើម្បីបម្រើប្រជាពលរដ្ឋ ក៏ដូចជាសម្រួលដល់ការរស់នៅប្រកបដោយតម្លាយភាព និង យុត្តិធម៌។ ការបង្កើតកិច្ចសន្យាពិតណាស់ មានភាពងាយស្រួលគឺគ្រាន់តែភាគីនៃកិច្ចសន្យាមានឆន្ទៈព្រមព្រៀងគ្នា ឬ សំណើ និង ស្វីការត្រូវគ្នាជាការស្រេច ប៉ុន្តែការបង្កើតកិច្ចសន្យាមួយដែលត្រឹមត្រូវប្រកបដោយគតិយុត្ត គ្មានវិការៈ ដែលជាមូលហេតុនាំឲ្យមានការលុបចោល និង មោឃភាពនោះ គឺពិតជាលំបាក ពីព្រោះការសម្តែងឆន្ទៈនៃការព្រមព្រៀងមិនបានសម្តែងពេញពីក្រអៅដួងចិត្តឆន្ទៈពិតប្រាកដរបស់អ្នកបង្ហាញឆន្ទៈឡើយ។ មានកត្តាជាច្រើនដែលជាហេតុនាំឲ្យកិច្ចសន្យាមានវិការៈ ដែលច្បាប់បានជួយការពារបុគ្គលទន់ខ្សោយ ឬ បុគ្គលសុចរិតដែលគ្មានកំហុស ឲ្យរួចផុតពីការអនុវត្តកាតព្វកិច្ច ពីសំណាក់បុគ្គលទុច្ចរិត ខិលខូចក្នុងសង្គម ដែលមានចេតនាអាក្រក់។ យើងខ្ញុំទាំងពីរមានជំនឿថា ប្រជាពលរដ្ឋខ្មែរមួយចំនួនពិតមិនទាន់បានយល់ដឹងពីសិទ្ធិរបស់ខ្លួន និង អ្វីទៅជាវិការៈនៃកិច្ចសន្យា ដែលជាមូលហេតុនៃការលុបចោល ឬ មោឃភាព នៅឡើយនោះទេ ហេតុដូច្នេះហើយទើបយើងទាំងពីរនាក់បានមូលមតិគ្នា ផ្តល់ជាចំណេះដឹងសម្រេចចិត្តចងក្រងសារណាក្រោមប្រធានបទ **វិការៈនៃកិច្ចសន្យា** នេះឡើង។

ការចងក្រងសារណានេះ ជសមិទ្ធផលដំបូងរបស់យើងខ្ញុំទាំងពីរ និងដោយក្មេងខ្ចីផ្នែកគតិយុត្ត និងបទពិសោធន៍ ហេតុនេះយើងខ្ញុំទាំងពីរក៏សូមខន្តីអភ័យទោសទុកជាមុខពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និង មិត្តអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គាំឆ្គងដែលកើតមានឡើងដោយអចេតនាណាមួយដែលមានឡើងនៅក្នុងសៀវភៅកិច្ចការស្រាវជ្រាវមួយក្បាលនេះ ពីព្រោះថានៅក្នុងការសិក្សាស្រាវជ្រាវតែងតែមាននូវចំណុតខ្វះខាត

តិចតួចក្តី ឬច្រើនក្តីប្រាកដជាមានជាក់ជាពុំខាន ទាំងអក្ខរាវិរុទ្ធ ទាំងពាក្យពេចន៍ និងទាំងអត្ថន័យក្តី។ ដូច្នេះហើយយើងខ្ញុំទាំងពីររីករាយទទួលយកដោយក្តីសោមនស្សរីករាយ នូវការរិះគន់ពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត មិត្តអ្នកអាន ក៏ដូចជាពីសំណាក់បណ្តាលជនគ្រប់មជ្ឈដ្ឋានក្នុងគោលបំណងដើម្បីឲ្យកាន់តែមានភាពសុក្រិតថែមទៀត។

ក្នុងនាមយើងខ្ញុំទាំងពីរជាអ្នករៀបរៀងកិច្ចការស្រាវជ្រាវមួយនេះក៏សង្ឃឹមថាស្នាដៃឯកសារមួយនេះនឹងក្លាយជាប្រយោជ៍ ព្រមទាំងផ្តល់នូវចំណេះដឹងបន្ថែមទៀត សម្រាប់ធ្វើជាគន្លឹះដល់ប្អូនៗជំនាន់ក្រោយអាចមកធ្វើការសិក្សាបន្ថែមទៀតបាន ដោយដាក់បញ្ចូលនូវគំនិតថ្មីបន្ថែមទៀត។

ជាចុងក្រោយយើងខ្ញុំទាំង២ រូបសូមជូនពរដល់អ្នកមានគុណទាំងពីរ លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតរួមក៏ដូចជាមិត្តអ្នកអានទាំងអស់អោយជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺ : **អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................................១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ.......................................................................................................២

៣. គោលបំណងនៃការស្រាវជ្រាវ.........................................................................................................២

៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ.............................................................................................៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................................................៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ..............................................................................................................៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.........................................................................................................៤

## ជំពូកទី១

**ផ្នែកទី១៖ សញ្ញាណទូទៅនៃកិច្ចសន្យា**...........................................................................................៥

១.១ និយមន័យ........................................................................................................................៦

១.២. ការព្រមព្រៀងបង្កើតកិច្ចសន្យា.........................................................................................៦

**ផ្នែកទី២៖ ល័ក្ខខ័ណ្ឌសុពលភាពនៃកិច្ចសន្យា**

២.១. ល័ក្ខខ័ណ្ឌទម្រង់ ..............................................................................................................៧

២.១.១. កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់....................................................................................៨

២.១.២. កិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរ.............................................................................៨

២.២. លិខិតឯកជន និង លិខិយថាភូត...........................................................................................៨

២.២.១. លិខិតឯកជន...............................................................................................................៩

២.២.២. លិខិយថាភូត.................................................................................................................៩

២.៣. ល័ក្ខខ័ណ្ឌគ្រឹះ ឬលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា...................................................................១០

២.៣.១. ការព្រមព្រៀង................................................................................................................១០

២.៣.១.១. សំណើ.......................................................................................................១១
ក. ល័ក្ខខ័ណ្ឌនៃសំណើ...........................................................................................១២
ខ. កាលកំណត់នៃសំណើ.........................................................................................១៣
គ. ការបញ្ចប់សំណើ...............................................................................................១៣
២.៣.១.២. ស្ទីការ.......................................................................................................១៤
ក. ល័ក្ខខ័ណ្ឌនៃស្ទីការ..............................................................................................១៤
២.៣.២. កម្មវត្ថុនៃកិច្ចសន្យា..................................................................................................១៥
២.៣.២.១. ភាពស្របច្បាប់ ឬ ផ្ទុយនឹងការអនុវត្តដោយបង្ខំ..................................................១៦
២.៣.២.២. ភាពមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ..........................១៦

**ផ្នែកទី ៣ ៖ សមត្ថភាពចុះកិច្ចសន្យា** ..........................................................................................១៧
៣.១. ជនដែលអនុញ្ញាតឲ្យចុះកិច្ចសន្យា........................................................................................១៧
៣.១.១. អនីតិជន..........................................................................................................១៨
៣.១.២. អនីតិជនមានអត្តាធីនភាព.....................................................................................១៨
៣.១.៣ អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម.....................................................១៩
៣.២. ជនដែលមិនអនុញ្ញាតឲ្យចុះកិច្ចសន្យា..................................................................................២០
៣.២.១. អនីតិជននៅក្រោមអំណាចមេបា............................................................................២០
៣.២.២. ជនដែលនៅក្រោមហិតូបត្ថម្ភ.................................................................................២០
៣.២.៣. ជននៅក្រោមអាណាព្យាបាលទូទៅ..........................................................................២១

# ជំពូកទី២

# វិការៈនៃកិច្ចសន្យា


**ផ្នែកទី១ ៖ វិការៈ**..........................................................................................២៣

១.១ និយមន័យនៃវិការៈ..........................................................................................២៣

១.២ មូលហេតុវិការៈកិច្ចសន្យា..........................................................................................២៣

**ផ្នែកទី២ ៖ ប្រភេទនៃវិការៈក្នុងកិច្ចសន្យា**..........................................................................................២៣

២.១ ការភាន់ច្រឡំ..........................................................................................២៣

២.១.១ ល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំ..........................................................................................២៤

២.១.១.១ ចំណុចដែលភាគីបង្ហាញឆន្ទៈយល់ថាសំខាន់..........................................................................................២៤

២.១.១.២ ភាគីទាំងសងខាងភាន់ច្រឡំ..........................................................................................២៤

២.២ ការឆបោក..........................................................................................២៥

២.២.១ ល័ក្ខខ័ណ្ឌនៃការឆបោក..........................................................................................២៥

២.២.១.១ គោលបំណងទុច្ចរិត..........................................................................................២៦

២.២.១.២ ការឆបោក ដែលប្រព្រឹត្តដោយភាគីម្ខាងទៀត..........................................................................................២៦

២.២.១.៣ ការឆបោក ដែលប្រព្រឹត្តដោយតតិយជន..........................................................................................២៦

២.២.១.៤ ភាពខុសច្បាប់នៃសកម្មភាពឆបោក..........................................................................................២៧

២.៣ ព័ត៌មានមិនពិត..........................................................................................២៧

២.៣.១ ល័ក្ខខ័ណ្ឌនៃព័ត៌មានមិនពិត..........................................................................................២៨

២.៣.១.១ ព័ត៌មានផ្ទុយពីការពិត..........................................................................................២៨

២.៣.១.២ អ្នកបង្ហាញឆន្ទៈដឹងថាហេតុមិនពិត នឹងមិនបង្ហាញឆន្ទៈទេ..........................................................................................២៩

២.៣.១.៣ ភាគីម្ខាងទៀតមិនដឹងអំពីព័ត៌មានមិនពិត..........................................................................................២៩

២.៤ ការរំលោភលើស្ថានភាព..........................................................................................៣០

២.៤.១ លក្ខខណ្ឌនៃការរំលោភលើស្ថានភាព..........................................................................................៣០

២.៤.១.១ ឋានៈ ឬ ស្ថានភាព មិនស្មើគ្នា....................................................................៣០

២.៤.១.២ បង្ហាញឆន្ទៈដោយមានការភ័យខ្លាច...........................................................៣១

២.៤.១.៣ បង្ហាញឆន្ទៈដោយមិនអាចប្រឆាំងតបតបាន..................................................៣១

២.៥ ការគម្រាមកំហែង.........................................................................................................៣២

២.៥.១ ល័ក្ខខ័ណ្ឌនៃការគម្រាមកំហែង..................................................................................៣២

២.៥.១.១ ភាគីម្ខាងទៀត គម្រាមគំហែង....................................................................៣២

២.៥.១.២ បង្ខិតបង្ខំដោយខុសច្បាប់.......................................................................៣៣

២.៥.១.៣ បង្កើតកិច្ចសន្យាដោយការភ័យខ្លាច...........................................................៣៣

២.៦ ការកេងចំណេញហួសហេតុ...........................................................................................៣៣

២.៦.១ លក្ខខណ្ឌនៃការកេងចំណេញហួសហេតុ......................................................................៣៤

២.៦.១.១ លំបាកផ្នែកសេដ្ឋកិច្ច ភាពល្ងង់ ខ្វះបទពិសោធន៍..........................................៣៤

២.៦.១.២ ការកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់.....................................................៣៤

២.៧ បឋមនីយផ្លូវចិត្ត.........................................................................................................៣៥

២.៧.១ ល័ក្ខខ័ណ្ឌនៃបឋមនីយផ្លូវចិត្ត..........................................................................................៣៥

២.៧.១.១ អ្នកបង្ហញឆន្ទៈមានឋមនីយផ្លូវចិត្ត..............................................................៣៥

២.៧.១.២ ភាគីម្ខាងទៀតបានដឹងថាកាបង្ហាញឆន្ទៈមានឋមនីយផ្លូវចិត្ត.............................៣៦

២.៨ ការបង្ហាញឆន្ទៈមិនពិត...................................................................................................៣៦

២.៨.១ ល័ក្ខខ័ណ្ឌនៃការបង្ហាញឆន្ទៈមិនពិត..........................................................................៣៦

២.៨.១.១ អ្នកបង្ហាញឆន្ទៈមិនបង្ហាញឆន្ទៈពិតប្រាកដ....................................................៣៧

២.៨.១.២ ការបង្ហាញឆន្ទៈដោយឃុបឃិត..................................................................៣៧

## ជំពូកទី៣

## ការលុបចោល និង មោឃៈភាពនៃកិច្ចសន្យា

**ផ្នែកទី ១ ៖ ការលុបចោល**..........៣៩

១.១ មូលហេតុនៃការលុបចោល..........៣៩

១.១.១ ជនខ្វះសមត្ថភាពខាងឆន្ទៈ..........៤០

១.១.២. ជនខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព..........៤១

១.១.២.១ អនីតិជន..........៤១

១.១.២.២ ជនស្ថិតក្រោមអាណាព្យាបាលទូទៅ..........៤២

១.១.២.៣ ជនស្ថិតក្រោមហិតូបត្ថម្ភ..........៤៣

១.១.៣ ការលុបចោលដោយមូលហេតុវិការៈនៃកិច្ចសន្យា..........៤៤

១.២ អ្នកមានសិទ្ធិ និង វិធីលុបចោល..........៤៤

១.២.១ អ្នកមានសិទ្ធិ..........៤៤

ក. ករណីវិការៈនៃការបង្ហាញឆន្ទៈ..........៤៤

ខ. ករណីខ្វះសមត្ថភាព..........៤៥

១.២.២ វិធីលុបចោល..........៤៥

១.៣ ការផ្តល់សច្ចានុមតិ..........៤៦

១.៣.១ អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ..........៤៦

១.៣.២ សច្ចានុមតិដែលកំណត់ដោយច្បាប់..........៤៦

១.៤. អានុភាពនៃការលុបចោល..........៤៧

១.៤.១ អាជ្ញាយុកាលនៃការលុបចោល..........៤៨

**ផ្នែកទី២ មោឃៈភាព**. ..........៤៩

២.១ មូលហេតុនៃមោឃៈភាព..........៥០

២.១.១ ខ្លឹមសារនៃកិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ..........៥០

២.១.២ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ.............................................៥០

២.១.៣ ខុសនឹងទម្រង់ច្បាប់.............................................................................................៥១

២.១.៤ ការបង្ហាញឆន្ទៈមិនពិត..........................................................................................៥១

២.២. អ្នកមានសិទ្ធិអះអាងអំពីមោឃៈភាព និង វិធីអះអាង.............................................................៥២

២.២.១ អ្នកមានសិទ្ធិ.........................................................................................................៥២

២.២.២ វិធីអះអាង.............................................................................................................៥២

២.៣. អានុភាពនៃមោឃៈភាព..................................................................................................៥៣

២.៣.១ អាជ្ញាយុកាលនៃការអះអាងអំពីមោឃៈភាព.............................................................៥៣

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

៙❖៙

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងជីវភាពប្រចាំថ្ងៃ របស់បុគ្គលទាំងអស់តែងតែបានជួបប្រទះនូវការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដែលការប្រាស្រ័យនោះមានដូចជាការដោះដូរទំនិញការជួយជាកម្លាំង ឬការទិញលក់ផលិតផលរវាងគ្នានិងគ្នាទៅវិញទៅមក។ រាល់ការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ឬ អាជីវកម្មដែលជាជីវភាពប្រចាំថ្ងៃ ដោយមានទម្រង់ជាផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សរ ទើបអាចបង្កើតបានជាកិច្ចសន្យាមួយបាន។ កិច្ចសន្យាទាំងពីរប្រភេទសុទ្ធតែកើតឡើងដោយសារទំនុកចិត្តរបស់ភាគីទាំងសងខាងដោយគ្រាន់តែកិច្ចសន្យាដែលធ្វើដោយលាយលក្ខណ៍អក្សរវាមានលក្ខណៈសំខាន់និងពិសេសជាង ព្រោះនៅពេលដែលមានវិវាទកើតឡើងអាចទុកជាសក្ខីតាងក្នុងការដោះស្រាយវិវាទចំពោះមុខតុលាការបាន។ លើសពីនេះ ទៅទៀត ការបង្កើតកិច្ចសន្យា គឺស្ថិតក្នុងគោលបំណងបង្កើតឲ្យមានភាពច្បាស់លាស់រវាងគ្នានឹងគ្នា ភាពស្មោះត្រង់ ក៏ដូចជាភាពជឿទុកចិត្តបានដែលមិនបណ្តាលឲ្យមានការបាត់បង់ ឬ ខូចខាតនូវផលប្រយោជន៍ចំពោះគ្នាទៅវិញទៅមកផងដែរ។ បច្ចុប្បន្ននេះដោយសារតែមានការយល់ដឹងអំពីផ្នែកច្បាប់ក៏ដូចជាយល់ដឹងអំពីសេដ្ឋកិច្ចទាំងក្នុងប្រទេសនិងក្រៅប្រទេសផងនោះ គេឃើញថាមានទំនាក់ទំនងរវាងបុគ្គលឯកជនជាច្រើន ត្រូវបានគ្រប់គ្រងដោយកិច្ចសន្យាជាច្បាប់របស់គូភាគីនោះ ហើយវាជាឧបករណ៍គតិយុត្តសម្រាប់ការពារប្រយោជន៍ដល់គូភាគីទាំងសងខាង។ ការរំលាយ ឬ មោឃភាព នៃកិច្ចសន្យា គឺកើតឡើងនៅពេលដែលកិច្ចសន្យាដែលបានបង្កើតនោះ ប្រកបដោយភាពវិការៈ ដែលសង្គមមិនអាចទទួលយកបាន ក៏ដូចជាច្បាប់បានការពារបញ្ញត្តិទុកជាមុខសម្រាប់សង្គមមួយប្រកបដោយតម្លាភាព និង យុត្តិធម៌ ដែលជាស្ពានឆ្ពោះទៅរកនីតិរដ្ឋ។

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានផ្តល់សិទ្ធិដល់ភាគីម្ខាងទៀតដែលបានខូចខាតនូវផលប្រយោជន៍ពីការចុះកិច្ចសន្យាដោយមានវិការៈនៃកិច្ចសន្យាដែលបានធ្វើឡើង អាចធ្វើការលុបចោលកិច្ចសន្យានោះវិញបាន ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើអ្វីទៅជាវិការៈនៃកិច្ចសន្យា? តើមានហេតុផលអ្វីខ្លះនៅដែលនាំឲ្យកិច្ចសន្យាមានវិការៈ? តើត្រូវបំពេញលក្ខខ័ណ្ឌអ្វីខ្លះទើបយើងអាចដឹងថា ជាកិច្ចសន្យាដែលមានវិការៈ ដែលជាមូលហេតុនៃការអនុវត្តការរំលាយទៅវិញ? តើការរំលាយកិច្ចសន្យាត្រូវមាននីតិវិធីយ៉ាងដូចម្តេចខ្លះ? តើការរំលាយកិច្ចសន្យាមានអានុភាពបែបណាទៅលើភាគីនៃកិច្ចសន្យា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវប្រធានបទ **វិការៈនៃកិច្ចសន្យា** នេះគឺ យើងខ្ញុំទាំងពីររូបមានបំណងចង់ស្វែងយល់ឱ្យកាន់តែច្បាស់ជាក់លាក់ ឲ្យស៊ីជម្រៅបន្ថែមទៀត ក៏ដូចជាចង់ចែករំលែកបទពិសោធន៍នៃការខិតខំស្រាវជ្រាវអំពីវិការៈកិច្ចសន្យា ដែលពួកយើងបានសិក្សាយល់ដឹងទៅកាន់មនុស្សគ្រប់គ្នាដែលបានអានវណ្ណកម្មស្នាដៃរបស់ពួកយើងទាំងពីររូប។ ដោយមូលហេតុយើងសង្កេតឃើញថា នាពេលបច្ចុប្បន្ននេះប្រទេសកម្ពុជាកំពុងស្ថិតនៅក្រោមម្លប់សន្តិភាព មានការអភិវឌ្ឍន៍ជឿនលឿនដើរទៅមុខឥតឈប់ឈរ ហើយប្រជាពលរដ្ឋក៏មានជីវភាព សេដ្ឋកិច្ចល្អជាមុនមួយកម្រិតស្របតាមការវិវឌ្ឍន៍របស់ប្រទេសជាតិផងដែរ ជាហេតុនាំឱ្យខ្ញុំទាំងរូបចង់ធ្វើការស្រាវជ្រាវលម្អិតទៅលើកិច្ចសន្យា ដោយមានចក្ខុវិស័យសម្លឹងឃើញថា កិច្ចសន្យា គឺពិតជាសំខាន់ ព្រោះមានការទាក់ទងនឹងជីវភាពសេដ្ឋកិច្ច ការប្រាស្រ័យទាក់របស់សង្គមមនុស្សដែលពុំអាចខ្វះបាន ក៏ដូចជាពុំអាចមើលរំលងបាន ទើបយើងខ្ញុំទាំងពីរនាក់រួមមតិតែមួយ ធ្វើការសម្រេចចិត្តសិក្សាស្រាវជ្រាវចងក្រងនូវប្រធានបទនេះឡើង ទុកគ្រាន់ជាឯកសារជំនួយស្មារតី សម្រាប់សិស្សនិស្សិតជំនាន់ក្រោយៗ និង មិត្តអ្នកអានដែលស្រឡាញ់ចូលចិត្តការសិក្សា ដើម្បីអានស្វែងយល់ប្រកបដោយពុទ្ធិចំណេះដឹង និង រក្សាទុកជាការចងចាំផ្ទាល់ខ្លួនក្នុងវិស័យគតិយុត្តទាក់ទិននឹងកិច្ចសន្យា។

## ៤. ទំហំ និង ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ស្នាដៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រមួយនេះ គឺសិក្សាទៅលើទំនាក់ទំនងទូទៅជុំវិញពីកិច្ចសន្យាតែប៉ុណ្ណោះ ជាពិសេសផ្តោតទៅលើវិការៈនៃកិច្ចសន្យាតែម្តង គឺមិនធ្វើការបកស្រាយលម្អិតសង្កត់ធ្ងន់ទៅលើការបង្កើតកិច្ចសន្យានោះទេ។ បន្ថែមលើសពីនេះ ការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ គឺផ្អែកសំខាន់តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ដែលជាឯកសារគោលដ៏សំខាន់ ក៏ដូចជាបានដកស្រង់ចេញពីសៀវភៅដែលមានខ្លឹមសារល្អៗរបស់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មួយចំនួន និង ពីអត្ថបទរបស់អ្នកមានចំណេះដឹងផ្នែកច្បាប់នានា ដែលបានធ្វើការបង្ហាញបកស្រាយ មានការទាក់ទងនឹងប្រធានបទរបស់យើងខ្ញុំទាំងពីររូបត្រូវសិក្សាស្រាវជ្រាវ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺ ចង់ធ្វើការចែករំលែកឱ្យទៅនិស្សិត អ្នកសិក្សាជំនាន់ក្រោយ និង មិត្តអ្នកអានដែលបានអានសិក្ខាប័ននេះនៅគ្រប់ទីមជ្ឈដ្ឋាន ជាពិសេសអ្នកដែលស្រឡាញ់ពេញចិត្តការសិក្សាច្បាប់ ឬ ផ្នែកនីតិសាស្ត្រ ក៏ដូចជានិស្សិតដែលកំពុងសិក្សារៀនសូត្រផ្នែកនីតិសាស្ត្រស្រាប់ រួមទាំងយើងខ្ញុំទាំងពីររូបផងដែរ ដែលជាអ្នកតាក់តែងចងក្រងនូវសារណានេះ ទុកគ្រាន់ជាឯកសារជំនួយប្រាជ្ញាស្មារតី អាចសិក្សាស្វែងយល់បង្កើនចំណេះដឹងផ្ទាល់ខ្លួនបន្ថែមផង និង ចង់សម្រេចភាពច្បាស់លាស់ទៅលើវិការៈនៃកិច្ចសន្យាដែលជាមូលហេតុនៃការរំលាយនោះតែម្តង ហើយក៏ជាការចូលរួមចំណែកលើកស្ទួយនីតិឯកជននៅកម្ពុជាផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ស្នាដៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំទាំងពីររូបបានទទួលតាមរយៈការស្រាវជ្រាវប្រមូលទិន្នន័យក៏ដូចជាព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីឲ្យស្នាដៃមួយនេះពោរពេញដោយអត្ថន័យខ្លឹមសារល្អៗ និង ទទួលបានប្រសិទ្ធិភាពខ្ពស់ក្នុងការសិក្សា។ នៅក្នុងខ្លឹមសារនៃស្នាដៃនេះ គឺយើងខ្ញុំទាំងពីរ

នាក់បានដកស្រង់ចេញពីគោលគំនិតក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ , សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី , សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី និង ឯកសារផ្សេងៗទៀត ហើយក៏ដូចជាសៀវភៅរបស់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកមានចំណេះដឹងផ្នែកច្បាប់ជាច្រើនរូបទៀតជាគោលផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារអត្ថបទសិក្សាស្រាវជ្រាវនៃប្រធានបទ **វិការៈនៃកិច្ចសន្យា** នេះ យើងនឹងធ្វើការសិក្សាចំនួន ៣ ជំពូក សំខាន់ៗ គឺ ៖

- **ជំពូកទី ១ ៖ ការបង្កើតកិច្ចសន្យា**
- **ជំពូកទី ២ ៖ វិការៈនៃកិច្ចសន្យា**
- **ជំពូកទី ៣ ៖ ការលុបចោល និង មោឃភាពនៃកិច្ចសន្យ**

# ជំពូកទី ១

# ការបង្កើតកិច្ចសន្យា

# ជំពូកទី ១
# ការបង្កើតកិច្ចសន្យា

## ផ្នែកទី ១៖ សញ្ញាណទូទៅនៃកិច្ចសន្យា

យោងតាមស្ថានភាពសង្គមសព្វថ្ងៃ ប្រជាពលរដ្ឋទូទៅមិនថាអាជីវករ អ្នកជំនួញ ឬអ្នកធ្វើការ តែងតែទិញទំនិញដោះដូរផលបរអ្វីមួយ គឺពួកគេតែងតែជៀសមិនផុតពីការបង្កើតកិច្ចសន្យាទេ ។ ការបង្កើតកិច្ចសន្យាទាំងនោះគ្រាន់តែមានសំណើ និងស្ទីការត្រូវគ្នាគឺគ្រប់គ្រាន់ហើយ ប៉ុន្តែកិច្ចសន្យាខ្លះមានច្រើនរូបភាព ច្រើនទម្រង់អាស្រ័យទៅលើឆន្ទៈការព្រមព្រៀងរបស់គូភាគី ។ ដើម្បីឱ្យភាគីនៃកិច្ចសន្យាបានបង្ហាញឆន្ទៈពិតរបស់ខ្លួនចាំបាច់ត្រូវតែមានការយល់ដឹង នឹងស្វែងយល់ឱ្យបានច្បាស់ពីល័ក្ខខ័ណ្ឌ នៃការបង្កើតកិច្ចសន្យា ។ ល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យាមានសារៈសំខាន់ណាស់ ដោយសារកិច្ចសន្យាកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគីដែលមានបំណងក្នុងការបង្កើតកាតព្វកិច្ចសម្រាប់ផលប្រយោជន៍ និងជៀសវាងកំហុសកើតឡើងដោយចេតនា និងអចេតនាណាមួយដោយសារមិនគោរពតាមល័ក្ខខ័ណ្ឌ។ ដូចច្នេះប្រសិនបើកិច្ចសន្យាដែលបានបង្កើតហើយ ឬកំពុងតែបង្ហាញឆន្ទៈក្នុងការបង្កើតមានវិការៈ ដែលជាមូលហេតុនាំឱ្យមានការរំលាយកិច្ចសន្យាអាចត្រូវបានមោឃៈ ឬ លុបចោលកិច្ចសន្យានោះបាន។

កិច្ចសន្យាគឺជាការព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬពីរក្រុមដើម្បីបង្កើតនូវកាតព្វកិច្ច កែប្រែកាតព្វកិច្ច ឬលុបចោលកាតព្វកិច្ច។ នៅក្នុងមាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណីបានឲ្យនិយមន័យកាតព្វកិច្ចថា៖

១. កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។

២. បុគ្គលដែលមានករណីយកិច្ចហៅថាកូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល។

៣. ម្ចាស់បំណុលមានសិទ្ធិត្រូវគ្នាទៅនឹងករណីយកិច្ចរបស់កូនបំណុល។[1]

[1] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣០៨

## ១.១. និយមន័យនៃកិច្ចសន្យា ៖

តាមន័យទូលាយ កិច្ចសន្យា គឺជាឯកសារភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលទទួលស្គាល់ និងគ្រប់គ្រងសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនានាចំពោះកិច្ចសន្យា។

តាមន័យចង្អៀត កិច្ចសន្យាផ្អែកតាមមាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា ឆ្នាំ២០០៧ គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។ តាមន័យនេះ កិច្ចសន្យា ជាប្រភពមួយនៃការបង្កើតឲ្យមានកាតព្វកិច្ច ដែលជាចំណងគតិយុត្តចងបុគ្គលពីរនាក់ ឬច្រើននាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់ មានករណីកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។[2]

## ១.២. ការព្រមព្រៀងបង្កើតកិច្ចសន្យា ៖

ការព្រមព្រៀង ជាដំណាក់កាលដំបូងមុននឹងឈានដល់ការបង្កើតកិច្ចសន្យា គឺត្រូវមានការព្រមព្រៀងពីគូភាគី នៃកិច្ចសន្យាដែលការព្រមព្រៀង គឺជាការសម្តែងឆន្ទៈយល់ព្រមរបស់គូភាគីនីមួយៗ ដើម្បីបង្ហាញគោលបំណងពិតប្រាកដក្នុងការបង្កើតកិច្ចសន្យា៉។ ការព្រមព្រៀង អាចកើតឡើងបានដោយសារ ភាគីម្ខាងបានធ្វើសំណើ និងភាគីម្ខាងទៀតបានទទួល និងតបសំណើដែលហៅថា ស្វីការ។ យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧) ក្នុងនោះ ការព្រមព្រៀងត្រូវធ្វើឡើងដោយសេរី ពិតប្រាកដ គ្មានការបន្លំបោកប្រាស់ និងពុំមានការបង្ខិតបង្ខំពី បុគ្គលណាមួយដែលមានផលប្រយោជន៍ទាក់ទងនៅក្នុងកិច្ចសន្យា។[3] ការព្រមព្រៀងមិនត្រូវមានការ គាបសង្កត់លើរូបរាងកាយ ឬខាងផ្នែកសេដ្ឋកិច្ច ឬប្រើប្រាស់ឥទ្ធិពលបង្ក្រាបដោយមានការគំរាម កំហែងពីភាគីម្ខាងទៀត។ បានសេចក្តីថា នៅក្នុងការបង្កើតកិច្ចសន្យា ត្រូវតែមានការព្រមព្រៀងដោយមិនមានការបន្លំបោកប្រាស់ដោយ ការឆបោក ភូតភរ ដើម្បីឱ្យភាគីជឿទុកចិត្តហើយព្រមព្រៀង និងយល់ព្រមចុះកិច្ចសន្យាជាមួយខ្លួន ដូចនេះវាបណ្តាលឱ្យមានការលុបចោលកិច្ចសន្យាកើតឡើងបាន។

---

[2] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣១១

[3] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៦

# ផ្នែកទី២៖ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

## ២.១. លក្ខខណ្ឌទម្រង់

ចំពោះលក្ខខណ្ឌទម្រង់នេះពុំមានកំណត់ទម្រង់ច្បាស់លាស់ទេ ហើយក្នុងជីវភាពប្រចាំថ្ងៃ កិច្ចសន្យាផ្ទាល់មាត់នេះត្រូវបានគេយកមកអនុវត្តជាប្រចាំទៅលើសកម្មភាពតូចតាចនានា ព្រោះកិច្ចសន្យានេះមានភាពសាមញ្ញ ងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្ត ប៉ុន្តែអាចផ្តល់ភាពលំបាកក្នុងការដោះស្រាយនៅពេលដែលមានវិវាទកើតឡើង ។ កិច្ចសន្យា មួយ អាចធ្វើឡើងដោយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។[4] ប៉ុន្តែដើម្បីជៀសវាងការឈ្លោះប្រកែកគ្នាជារឿយៗ អំពីកិច្ចសន្យាដែលធ្វើឡើងដោយផ្ទាល់មាត់ដែលគ្មានភស្តុតាងច្បាស់លាស់ ទើបច្បាប់បានតម្រូវឲ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ ទើបកិច្ចសន្យាអាចមានសុពលភាពគតិយុត្ត។ ដោយឡែក កិច្ចសន្យាដែលដែលភាគីម្ខាងទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត។ ចំពោះលក្ខខណ្ឌទម្រង់នេះពុំមានកំណត់ទម្រង់ច្បាស់លាស់ទេ ហើយក្នុងជីវភាពប្រចាំថ្ងៃ កិច្ចសន្យាផ្ទាល់មាត់នេះត្រូវបានគេយកមកអនុវត្តជាប្រចាំទៅលើសកម្មភាពតូចតាចនានា ព្រោះកិច្ចសន្យានេះមានភាពសាមញ្ញ ងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្ត ប៉ុន្តែអាចផ្តល់ភាពលំបាកក្នុងការដោះស្រាយនៅពេលដែលមានវិវាទកើតឡើង ។ ម៉្យាងវិញទៀតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ តម្រូវឱ្យកិច្ចសន្យាមួយចំនួនត្រូវតែធ្វើជាលិខិតយថាភូតទើបបង្កើតឱ្យកិច្ចសន្យានោះមានសុពលភាព ។

ឧទាហរណ៍ ៖ (ក) ជាអ្នកទិញ បានសួរ (ខ) ជាអ្នកលក់ថា តើកាបូបមួយនេះមានតម្លៃប៉ុន្មាន? (ខ) បានឆ្លើយតបថា កាបូបនេះមានតម្លៃ ១០.០០០៛ (មួយម៉ឺនរៀល) ហើយបន្ទាប់មក (ក) ក៏ប្រគល់លុយ ហើយ (ខ) ក៏ប្រគល់កាបូប (នេះជាលក្ខខណ្ឌទម្រង់ ដែលងាយៗក្នុងការអនុវត្តប្រចាំថ្ងៃ) ។ បើក្រឡេកទៅមើលទម្រង់លាយលក្ខណ៍អក្សរវិញ កិច្ចសន្យាធ្វើឡើងដោយលាយលក្ខណ៍អក្សរ គឺជាកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយគូភាគីនៃកិច្ចសន្យា ដែលជាទូទៅនៅក្នុងកិច្ចសន្យាមានសរសេរកាលបរិច្ឆេទ ស្នាមម្រាមដៃ អំពីតម្លៃ ពេលវេលា និងកម្មវត្ថុនៃកិច្ចសន្យាជាដើម ។

[4] ក្រឹត-ច្បាប់លេខ៣៨ មាត្រា ១៤

### ២.១.១. កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់

កិច្ចសន្យាផ្ទាល់មាត់គឺជាកិច្ចសន្យាដែលត្រូវបានគេយកមកអនុវត្តជាប្រចាំទៅលើសកម្មភាពតូចតាចនានា ព្រោះកិច្ចសន្យានេះមានភាពសាមញ្ញ ងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្ត ប៉ុន្តែអាចផ្តល់ភាពលំបាកក្នុងការដោះស្រាយនៅពេលដែលមានវិវាទកើតឡើង ។ ជាទូទៅ កិច្ចសន្យា នៅ ក្នុង ជីវភាពរស់នៅប្រចាំថ្ងៃពុំមានធ្វើ ជាលាយលក្ខណ៍អក្សរទេ ។

ឧទាហរណ៍ ៖ យុវជនម្នាក់ទៅតូបលក់សៀវភៅដើម្បីទិញសៀវភៅ និងប៊ិកយកទៅប្រើប្រាស់ ក្នុងការសិក្សាគឺម្ចាស់តូបលក់សៀវភៅ និងយុវជននោះមិនធ្វើកិច្ចសន្យាលាយលក្ខណ៍អក្សរអ្វីទេគ្រាន់តែប្រគល់យកសម្ភារដែលខ្លួនទិញហើយប្រគល់ប្រាក់តាមតម្លៃព្រមព្រៀងគ្នាជាការស្រេច ។

### ២.១.២. កិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរ

កិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរគឺជាភស្តុតាងដែលអាចការពារប្រយោជន៍ឲ្យភាគីរងគ្រោះនៅពេលមានវិវាទកើតឡើងបាន ។ ទោះបីជាការបង្កើតកិច្ចសន្យា អាចធ្វើឡើងដោយផ្ទាល់មាត់យ៉ាងណាក៏ដោយ តែបណ្តាលយុធិត្តាធិការជាច្រើនពិតជាតម្រូវអោយមានប្រភេទនៃកិច្ចសន្យាសំខាន់ៗមួយចំនួនត្រូវសរសេរជាលាយលក្ខណ៍អក្សរ ទើបអាចដាក់ឱ្យប្រតិបត្តិបាន។ លើសពីនេះទៅទៀតភាគីទាំងឡាយនៃកិច្ចសន្យា គួរតែធ្វើកិច្ចសន្យាសំខាន់ៗជាលាយលក្ខណ៍អក្សរ ទោះបីមិនមានច្បាប់តម្រូវក៏ដោយ ព្រោះការសរសេរនោះនាំអោយបានការលើកទឹកចិត្តដល់គូភាគីនៃកិច្ចសន្យាអោយមានភាពច្បាស់លាស់ពេញឡើងថែមទៀត ក្នុងការធ្វើកិច្ចសន្យារបស់ពួកគេ និង ផ្តល់ ភស្តុតាងយ៉ាងមុតមាំ ដើម្បីការពារផលប្រយោជន៍របស់ពួកគេនៅក្នុងការបង្កើតកិច្ចសន្យា។ ជាទូទៅកិច្ចសន្យាអាចធ្វើជា លិខិតយថាភូត និង លិខិតឯកជន ជាល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យា។

## ២.២ លិខិតឯកជន និងយថាភូត

### ២.២.១. លិខិតឯកជន

លិខិតឯកជន គឺជាលិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃ ។[5] ហើយលិខិតឯកជន ជាលិខិតដែលធ្វើឡើងដោយពុំមានមន្ត្រីរាជការសាធារណៈណាមួយជួយដឹង ឮ និងឃើញនោះទេមានតែហត្ថលេខានៃគូភាគីតែប៉ុណ្ណោះ។ ជាពិសេស លិខិតឯកជនជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។ ដូចនេះ កិច្ចសន្យាដែលធ្វើឡើងក្នុងទម្រង់ជាលិខិតឯកជន គឺជាកិច្ចសន្យាដែលធ្វើឡើងដោយការ ព្រមព្រៀងកិច្ចការណាមួយ ដើម្បីបង្កើតឱ្យមានលក្ខណៈគតិយុត្តតាមផ្លូវច្បាប់។ បានសេចក្តីថា កិច្ចសន្យាទូទៅដែរ នៅពេលដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យា គឺត្រូវធ្វើឡើងក្នុងទម្រង់លិខិតឯកជនដោយមិនមានការចូលរួមពីសារការី។ ការបង្កើតកិច្ចសន្យារយៈលិខិតនេះ ងាយស្រួលក្នុងការបង្កើត និងការរំលាយ នៅពេលដែលកិច្ចសន្យានោះមានវិការៈ ។

### ២.២.២. លិខិយថាភូត

លិខិតយថាភូតគឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ដោយមន្ត្រីសាធារណៈត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ ឬ តាមន័យចង្អៀតលិខិតទាំងឡាយដែលរៀបចំឡើងដោយសាការី។ លិខិតឯកជនដែលបានធ្វើឡើងស្របតាមលក្ខខណ្ឌគតិយុត្តដែលមានភាពត្រឹមត្រូវ អាចជឿជាក់បានក៏ពិតមែន ប៉ុន្តែវាមានតម្លៃគតិយុត្តទាបជាលិខិតយថាភូត។លិខិតយថាភូតជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ដោយមន្ត្រីសារធារណៈដែលត្រូវបាអនុញ្ញាតឱ្យប្រតិបត្តិមុខងារនេះហើយតាមន័យចង្អៀតវាក៏ជាលិខិតទាំងឡាយណាដែលរៀបចំឡើងដោយសារការី។[6] តាមន័យនេះ លិខិតយថាភូតសំខាន់បំផុតសម្រាប់ភាគីក្នុងកិច្ចសន្យាដោយសារទម្រង់នេះមានលក្ខណៈ

[5] សន្ធានុក្រមផ្នែករដ្ឋប្បវេណី (អនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការរដ្ឋមន្ត្រី ឆ្នាំ ២០០៧)

[6] សន្ធានុក្រមផ្នែករដ្ឋប្បវេណី (អនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការរដ្ឋមន្ត្រី ឆ្នាំ ២០០៧)

រឹងមាំ និងមានការចុះបញ្ជីដោយបុគ្គលដែលមានសមត្ថកិច្ច និងច្បាប់។ម៉្យាងទៀត មាត្រា៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១បានកំណត់ផងដែរនូវអត្ថន័យនលិខិតយថាភូតជាលិខិតដែលត្រូវធ្វើឡើដោយសារការី ឬលិខិតឯកជនដោយសារការីចុះនិទ្ទេសថាលិខិតនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ចុះកាលបរិច្ឆេទនិងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថាលិខិតនោះមានភាពត្រឹមត្រូវតាមផ្លូវច្បាប់។ជាគោលការណ៍កិច្ចសន្យាដែលធ្វើឡើងក្នុងទម្រង់លិខិតយថាភូតហើយនៅពេលដែលមានវិវាទលិខិតនេះជាភស្តុតាងចាំបាច់សម្រាប់ការតតាំងក្តី។

## ២.៣. លក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

លក្ខខណ្ឌគ្រឹះ ឬលក្ខខណ្ឌសុពលភាពក្នុងការបង្កើតកិច្ចសន្យាជាគោលការណ៍ដែលទាក់ ទងទៅនឹងភាគី ហើយកិច្ចសន្យាដែលបានបង្កើតឡើង មិនមែនសុទ្ធតែមានសុពលភាពនោះទេ។ ដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាពបាន លុះត្រាតែកិច្ចសន្យានោះបានបង្កើតឡើងដោយមាន ការព្រមព្រៀង សមត្ថភាព និងមានកម្មវត្ថុនៃកិច្ចសន្យា។ ជារួមការបង្កើតកិច្ចសន្យាដែលទាមទារឱ្យមានការព្រមព្រៀង សមត្ថភាព និងកម្មវត្ថុទើបកិច្ចសន្យាអាច បង្កើតឡើងបាន។ ជាពិសេស ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងពីវិការៈក្នុងការបង្ហាញឆន្ទៈ និង លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចាប់ពីមាត្រា ៣៤៥ រហូតដល់មាត្រា ៣៥៥ ។[7]

### ២.៣.១. ការព្រមព្រៀង

ការព្រមព្រៀងបង្កើត គឺជាឆន្ទៈរបស់ភាគីចុះកិច្ចសន្យា ដើម្បីបង្កើត និងភ្ជាប់នូវកាតព្វកិច្ចផ្សេងៗរវាងគូភាគី។នៅក្នុងនោះផងដែលធាតុផ្សំដើម្បីបង្កការព្រមព្រៀងមានចំនួន ២ធំៗគឺ៖ សំណើនិងស្វីការ។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧) មាត្រា ៣៣៦ កថាខណ្ឌទី១ បានចែងថាកិច្ចសន្យាមាន

[7] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧

អានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា។ ការព្រមព្រៀង គឺជាការសម្ដែងឆន្ទៈយល់ព្រមរបស់ភាគីនីមួយៗ ដើម្បីបង្ហាញគោលបំណងពិតប្រាកដក្នុងការបង្កើតកិច្ចសន្យា”។[8] ការព្រមព្រៀង អាចកើតឡើងបានដោយសារភាគីម្ខាងបានធ្វើសំណើ និងភាគីម្ខាងទៀតបានទទួល និងតបសំណើដែលហៅថា ស្វីការ។ ក្នុងនោះ ការព្រមព្រៀងត្រូវធ្វើឡើងដោយសេរី ពិតប្រាកដ គ្មានការបន្លំបោកប្រាស់ និងពុំមានការបង្ខិតបង្ខំពី បុគ្គលណាមួយដែលមានផលប្រយោជន៍ទាក់ទងនៅក្នុងកិច្ចសន្យា។ ការព្រមព្រៀងមិនត្រូវមានការ គាបសង្កត់លើរូបរាងកាយ ឬខាងផ្នែកសេដ្ឋកិច្ច ឬប្រើប្រាស់ឥទ្ធិពលបង្ក្រាបដោយមានការគំរាម កំហែងពីភាគីម្ខាងទៀត។ បានសេចក្ដីថា នៅក្នុងការបង្កើតកិច្ចសន្យា ត្រូវតែមានការព្រមព្រៀងដោយមិនមានការបន្លំបោកប្រាស់ដោយ ការឆបោក ភូតភរ ដើម្បីឱ្យភាគីជឿទុកចិត្តហើយព្រមព្រៀង និងយល់ព្រមចុះកិច្ចសន្យាជាមួយខ្លួន ដូចនេះវាបណ្ដាលឱ្យមានការលុបចោលកិច្ចសន្យាកើតឡើងបាន។

### ២.៣.១.១. សំណើ

សំណើ[9] គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណង គតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ ដូចនេះ គេឱ្យនិយម ន័យសំណើថាជាការស្នើបង្កើតកិច្ចសន្យាមួយរវាងបុគ្គលម្នាក់ទៅនឹងបុគ្គលម្នាក់ទៀត។ សំណើ ដែលបានស្នើអាចជាសំណើជាក់លាក់ និងប្រាកដប្រជា គឺត្រូវធ្វើឡើងតាមរយៈការសរសេរលិខិតជា លាយលក្ខណ៍អក្សរ ឬជាពាក្យសំដី ហើយត្រូវតែមានការបង្ហាញឱ្យបានច្បាស់លាស់ថា អ្នកស្នើ មាន ឆន្ទៈប្រាកដប្រជា ដើម្បីចុះកិច្ចសន្យា។ ម្យ៉ាងទៀត សំណើត្រូវបង្ហាញពីគោលបំណងយ៉ាងរឹងមាំ របស់អ្នកផ្ដល់សំណើ ក្នុងការធ្វើអ្វីមួយតាមការព្រមព្រៀង ដែលបានភ្ជាប់ដោយកាតព្វកិច្ចតាមផ្លូវ ច្បាប់។ ភាគីដែលមានបំណងបង្កើតនូវសំណើត្រូវធ្វើការជូនដំណឹងអំពីសំណើរបស់ខ្លួន ដើម្បីឱ្យ សំណើបានដល់អ្នកទទួលសំណើ។

[8] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៣៣៦ កថាខណ្ឌទី១

[9] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៣៣៧ កថាខណ្ឌទី២

### ក. លក្ខខណ្ឌនៃសំណើ

ក្នុងការបង្កើតសំណើមួយឲ្យមានសុពលភាព អ្នកដែលផ្តល់សំណើត្រូវបង្ហាញឆន្ទៈរបស់ខ្លួនឲ្យបានពិតប្រាកដ និងជាក់លាក់ ថាខ្លួនពិតជាចង់បង្កើតសំណើនោះមែន។ លើសពីនេះទៅទៀត ខ្លឹមសារនៃសំណើត្រូវតែមានភាពជាក់លាក់ និងច្បាស់លាស់ផងដែរដូចជា៖ ការកំណត់អត្តសញ្ញាណនៃគូភាគី តាវកាលិក និងពេលវេលាកំណត់ជាដើម។ សំណើអាចធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

- **គោលបំណងពិតប្រាកដនៃសំណើ ៖** គោលបំណងពិតប្រាកដនៃសំណើ គឺជាការកំណត់តាមរយៈពាក្យសំដី ឬអំពើរបស់ភាគី ដែលជាមនុស្សប្រកបគតិមានហេតុផលត្រឹមត្រូវ។ ប្រសិនបើអ្នកស្នើធ្វើសំណើ មានការភ័យខ្លាច ខឹង ឬលេងសើច ញុះញុងសំណើបែបនេះគឺគ្មានគោលបំណងពិតប្រាកដនោះទេ។[10]
- **ភាពច្បាស់លាស់នៃសំណើ៖** សំណើត្រូវតែមានខ្លឹមសារជាក់លាក់ច្បាស់លាស់ និងសមហេតុសមផល នោះមានន័យថា សំណើត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់អំពីប្រភេទនៃវត្ថុ បរិមាណ តម្លៃ គុណភាព ពេលវេលា ទីកន្លែងជាដើម។[11]
- **ការជូនដំណឹងអំពីសំណើ៖** ជូនដំណឹងអំពីសំណើគឺបង្ហាញពីគោលបំណងរបស់ខ្លួនទៅកាន់អ្នកទទួលសំណើ ។ ហើយការជូនដំណឹងអំពីសំណើក៏ជាអានុភាពមួយរបស់សំណើ កើតឡើងនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត។ ដោយសំណើបានទៅដល់ដៃអ្នកទទួលហើយអានុភាពនៃសំណើក៏ត្រូវបាត់បង់ទៅវិញ ប្រសិនបើនៅពេលដែលមានដំណឹងអំពីការដកសំណើវិញ បានដល់ភាគីម្ខាងទៀត នៅក្នុងពេលជាមួយគ្នា និងពេលសំណើដល់ ឬមុនពេលសំណើដល់។ ហេតុនេះហើយទើបសំណើ ក៏មានបែបបទមួយ ចំនួនរួមមាន សំណើដែលមានកំណត់អំឡុងពេល និងគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ។

[10] កិច្ចសន្ទាពិសេស មេធាវី ជ្រា ឈុយឡេង ទំព័រ ៤ ឆ្នាំ ២០១៨

[11] កិច្ចសន្ទាពិសេស មេធាវី ជ្រា ឈុយឡេង ទំព័រ ៥ ឆ្នាំ ២០១៨

### ខ.ការកំណត់នៃសំណើ

កាលកំណត់នៃសំណើ គឺជាបែបបទមួយ ចំនួនរួមមាន សំណើដែលមានកំណត់អំឡុងពេល និងគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ។[12]

- **សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការៈ** គឺសំណើនោះ អាចកើតឡើងពេលដែលមានការកំណត់រយៈពេលមួយសម្រាប់ស្វីកា ហើយអំឡុងពេលសម្រាប់សំណើត្រូវគិតចាប់ ពីថ្ងៃដែលជូនដំណឹងពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង។ លើសពីនេះ សំណើនឹងបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ធ្វើការ។
- **សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការៈ** គឺសំណើនោះ ត្រូវបាត់បង់អានុភាពពេលគូភាគី ទទួលសំណើមិនយល់ព្រមភ្លាមៗ ក្នុងស្ថានភាពដែលគូភាគី កំពុងនិយាយគ្នា ហើយអាចឆ្លើយតបភ្លាមៗបាន។ អ្នកស្នើ មិនអាចដកសំណើវិញក្នុងអំឡុងពេលសមរម្យបានទេ បើ គូភាគីមិនបាននិយាយគ្នា។ ដោយឡែក បើការជូនដំណឹងពីការដកនោះបាន ទៅដល់ភាគី ម្ខាងទៀតមុនពេល ដែលភាគីនោះជូនដំណឹងពីស្វីការទើបការដកសំណើរមានអានុភាព៉។

### គ. ការបញ្ចប់សំណើ

សំណើអានឹងត្រូវបានបញ្ចប់ ដោយសារមូលហេតុដូចជាៈ

- ការដកសំណើ ឬ ការលុបសំណើ
- ការបដិសេធសំណើដោយអ្នកទទួលដំណឹង
- ម្ចាស់ដែលធ្វើសំណើទទួលមរណភាព
- កម្មវត្ថុនៃកិច្ចសន្យាត្រូវបានបំផ្លាញ ឬ ខូចខាត

[12] កិច្ចសន្យាពិសេស មេធាវី ជ្រា ឈុយឡេង ទំព័រ ៦ ឆ្នាំ ២០១៨

### ២.៣.១.២. ស្វីការ

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ មាន ន័យថា ស្វីការជាការសំដែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួន ចំពោះសំណើ ដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។[13] ស្វីការ អាចជាអំពើដែលកើតឡើងដោយអ្នក ទទួលសំណើ ដែលឆ្លុះបញ្ចាំងពីគោលបំណងរបស់អ្នកទទួលសំណើ ក្នុងកិច្ចព្រមព្រៀងជាប់ កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលផ្អែកលើរាល់លក្ខខណ្ឌសំណើដែលបានទទួល។ ជារួម ច្បាប់ពុំបាន កំណត់ច្បាស់លាស់លើអត្ថន័យនៃស្វីការនោះទេ វាអាស្រ័យទៅតាមយុត្តិសាស្ត្រនាពេលបច្ចុប្បន្ន ដោយសកម្មភាពដែលត្រូវបានទទួលស្គាល់ថាជាស្វីការ ក៏ធ្វើឱ្យកិច្ចសន្យាអាចកើតឡើងបានដែរ ។

ឧទាហរណ៍ ៖ លោក A បានដាក់លក់រថយន្តរបស់ខ្លួនក្នុងតម្លៃ៣0,000ដុល្លា ទៅលោក B (សំណើរ)។ ហើយនៅថ្ងៃទី៣១ ធ្នូ ២០២១ លោក B បានយល់ព្រមទិញ និងប្រគល់ប្រាក់ទៅលោក A (ស្វីការ)។ នេះមានន័យថា សំណើរ និងស្វីការបានជួបគ្នា នោះបង្កើតបានជាកិច្ចសន្យាដែលមានអានុភាព។

#### ក. លក្ខខណ្ឌនៃស្វីការ

ស្វីការមួយមានអានុភាព នៅពេលដែលស្វីការបានទៅដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការនោះវិញបានទៅដល់អ្នកស្នើនៅពេលព្រមគ្នានឹងពេលដែលស្វីការបានទៅដល់ ឬ មុនពេលដែលស្វីការបានទៅដល់ នោះអានុភាពនៃស្វីការមិនត្រូវបានកើតឡើយ។[14] ជាធម្មតាអ្នកធ្វើស្វីការត្រូវយល់ព្រមទាំងស្រុងនូវរាល់ចំណុចដែលមានកំណត់នៅក្នុងសំណើ។ ស្វីការត្រូវធ្វើឡើងឲ្យទាន់ពេលមុននិងសំណើរលត់ ស្វីការត្រូវតែបញ្ជូនឲ្យទៅដល់អ្នកស្នើ។ លើសពីនេះទៅទៀតស្វីការត្រូវធ្វើដូចទៅ នឹងសំណើដៃ ស្វីការអាចធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ឬ ដោយតណ្លើភាព។

[13] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី ៣

[14] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៧

- **អ្នកមានសិទ្ធិក្នុងការផ្តល់ស្វីការ ៖** មានតែអ្នកទទួលសំណើប៉ុណ្ណោះ ទើបអាចធ្វើសំណើនោះក្នុងគោលបំណងបង្កើតកិច្ចសន្យាមួយបាន។ [15]
- **ការជូនដំណឹងអំពីស្វីការ ៖** ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ កិច្ចសន្យាកើតឡើងនៅពេលដែលសំណើជួបនឹងស្វីការ។ ដូច្នេះប្រសិនបើអ្នកទទួលសំណើចង់បង្កើតកិច្ចសន្យានោះគាត់ត្រូវធ្វើយ៉ាងណាបញ្ជូនស្វីការរបស់គាត់ឱ្យបានទៅដល់ភាគីនៃសំណើ។ អានុភាពនៃស្វីការ មាននៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ នៅពេលដែលពុំមាន ការជំទាស់លើសំណើដែលអ្នកស្នើដាក់មក ការបង្ហាញឆន្ទៈស្វីការនេះ ជាការយល់ព្រមដោយ គ្មាន លក្ខខណ្ឌដោយឡែក ប្រសិនបើមានការប្រឆាំង ឬជំទាស់លើសំណើនោះ ហើយអ្នកធ្វើស្វីការ បានដាក់លក្ខខណ្ឌ ឬកែប្រែសារធាតុសំណើនាំឱ្យស្វីការមិនមានសុពលភាពទទេ តែវានឹងមាន អានុភាពជាសំណើថ្មី ។
- **ស្វីការត្រូវតែធ្វើមុខពេលសំណើរលត់ ៖** ប្រសិនបើសំណើត្រូវបានគេរំលត់មុនពេលមានស្វីការកើតឡើងនោះគ្មានកិច្ចសន្យាដែលមានសុពលភាពកើតឡើងទេ ដោយហេតុថាកិច្ចសន្យាដែលមានសុពលភាពត្រូវកើតឡើងដោយសារការជួបគ្នារវាងសំណើដែលមានសុពលភាពនឹងស្វីការដែលមានសុពលភាព។ ប្រសិនបើគូភាគីកំពុងតែនិយាយទល់មុខគ្នា នោះនឹងមានភាពងាយស្រួលកំណត់ថា ពេលណាសំណើនឹងត្រូវរំលត់តែប្រសិនបើភាគីបានធ្វើទំនាក់ទំនងជាមួយគ្នាពីចម្ងាយនោះវានឹងមានភាពពិបាកក្នុងការកំណត់ថាពេលសំណើនឹងត្រូវរំលត់ អ្នកស្នើអាចចាត់ទុកថាស្វីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលគឺជាសំណើថ្មី។ ករណីដែលមានការជូនដំណឹងអំពីការដកស្វីការវិញ គឺមានលក្ខណៈដូច សំណើដែរ។ សរុបមក កិច្ចសន្យាត្រូវកើតឡើងពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ។[16]

### ២.៣.២. កម្មវត្ថុនៃកិច្ចសន្យា

កិច្ចសន្យាមួយនឹងមានសុពលភាពនៅពេលដែលកាតព្វកិច្ចបានកើតឡើងពីកិច្ចសន្យានោះជាកម្មវត្ថុមួយជាក់លាក់អាចធ្វើកើតនិងស្របច្បាប់ មានរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អរបស់ប្រពៃណី។

[15] កិច្ចសន្យាពិសេស មេធាវី ជ្រា ឈុនឡេង ទំព័រ ១៣ ឆ្នាំ ២០១៨

[16] មាត្រា ៣៨២ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

កម្មវត្ថុនៃ កិច្ចសន្យាគឺជាកាតព្វកិច្ច ឯកម្មវត្ថុនៃកាតព្វកិច្ចគឺជាតាវកាលិ ( អំពើ ឬ វត្ថុ ) ។ ក្នុងនោះផងដែរកម្មវត្ថុនៃកិច្ចសន្យាត្រូវតែជាក់លាក់ មានន័យថាភាគីកិច្ចសន្យាត្រូវតែយល់ច្បាស់ពីអ្វីដែលខ្លួនបានសន្យាចំពោះកិច្ចសន្យានៅពេលបច្ចុប្បន្នដែរ ដូច្នេះប្រសិនបើកម្មវត្ថុមិនមាននៅពេលចុះកិច្ចសន្យាដោយសារកម្មវត្ថុនោះបានបាត់បង់កិច្ចសន្យានឹងពុំមានសុពលភាពឡើយ។

### ២.៣.២.១. ភាពស្របច្បាប់ ឬ ភាពផ្ទុយច្បាប់នឹងការអនុវត្តដោយបង្ខំ

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិច្បាប់ នោះវាត្រូវបានចាត់ទុកជាមោឃៈ ។[17] បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺសំដៅទៅលើបញ្ញត្តិដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិនេះ។

ឧទាហរណ៍៖ នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា ភាគីម្ខាងនៃកិច្ចសន្យា មិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់បានបង្ហាញឆន្ទៈដោយសារការភាន់ច្រឡំក៏ដោយ។ ការព្រមព្រៀងនេះត្រូវបានចាត់ទុកថាជាមោឃៈ ព្រោះវា កិច្ចសន្យាបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

### ២.៣.២.២. ភាពមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម៖

សំដៅទៅលើ បើទោះបីជាគូភាគីបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈដែរ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម និងទំនៀមទំលាប់ល្អ ។

ឧទាហរណ៍៖ នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា បង្កើតកិច្ចសន្យាជួញដូរគ្រឿងញៀនជាមួយគ្នា។ បើទោះបីជាគូភាគីទាំងសងខាងដឹងហើយថាកិច្ចសន្យាជួញដូរគ្រឿងញៀនជាអំពើខុសច្បាប់ក៏ដោយ ។ កិច្ចសន្យាជួញដូរគ្រឿងញៀនជាអំពើដែលផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អក្នុងសង្គម។

---

[17] មាត្រា ៣៥៤ កថាខណ្ឌទី ១ ចំណុច ក នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

## ផ្នែកទី ៣ ៖ សមត្ថភាពចុះកិច្ចសន្យា

ជាទូទៅមនុស្សគ្រប់រូបត្រូវបានទទួលស្គាល់យ៉ាងពេញលេញអំពីសិទ្ធិរបស់ខ្លួន ដែលពួកគេអាចប្រើប្រាស់សិទ្ធិនេះ ក្នុងការធ្វើសកម្មភាពផ្សេងៗបានដោយសេរី កុំឱ្យតែប៉ះពាល់ ដល់សិទ្ធិអ្នកដ៏ទៃ និងផ្ទុយនឹងបញ្ញត្តិច្បាប់ ។ ក៏ប៉ុន្តែសកម្មភាពដែលបានធ្វើឡើង មានសកម្មភាពមួយចំនួនត្រូវបានច្បាប់ទទួលស្គាល់ និងមានសុពលភាពពេញលេញ ហើយសកម្មភាពដែលបានធ្វើឡើងដោយជនមួយចំនួនទៀតត្រូវបាន ច្បាប់មិនទទួលស្គាល់ថាមានសុពលភាព ឬតម្រូវឱ្យមានការយល់ព្រមដោយជនដែលមានផលប្រយោជន៍ផ្សេងទៀត ដើម្បីឱ្យមានសុពលភាពលើសកម្មភាពទាំងនោះជាអាទិ៍ ។ សកម្មភាពមួយចំនួនដែលបានធ្វើឡើងហើយមិនត្រូវបានទទួលស្គាល់ ឬមិនមានសុពលភាព គឺដោយហេតុថាជនដែលបានធ្វើសកម្មភាពទាំងនោះត្រូវបានកំណត់ថា ជាជនដែលខ្វះសមត្ថភាព ឬត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ។

សមត្ថភាពគឺជាសម្បទានរបស់បុគ្គលម្នាក់ៗដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យា ។ កិច្ចសន្យានឹងមានសុពលភាពនៅពេលដែលកាតព្វកិច្ចបានកើតឡើងពីកិច្ចសន្យានោះជាកម្មវត្ថុមួយជាក់លាក់អាចធ្វើកើតនិងស្របច្បាប់ មានរបៀបរៀបរយជាសាធារណៈ ឬ ទំនៀមទម្លាប់ល្អ។ កម្មវត្ថុនៃកិច្ចសន្យាគឺជាកាតព្វកិច្ច ឯកម្មវត្ថុនៃកាតព្វកិច្ចគឺជាតាវកាលិក (អំពើ ឬ វត្ថុ ) ។ ក្នុងនោះផងដែរកម្មវត្ថុនៃកិច្ចសន្យាត្រូវតែជាក់លាក់ មានន័យថាភាគីនៃកិច្ចសន្យាត្រូវតែយល់ច្បាស់អំពីអ្វីដែលខ្លួនបានសន្យាចំពោះកិច្ចសន្យាដែលមានកម្មវត្ថុជាតាវកាលិកចេញពីអំពើរបស់មនុស្ស។ កម្មវត្ថុជាក់លាក់ ក៏មានន័យថាជាកម្មវត្ថុត្រូវវតែមាននៅពេលបច្ចុប្បន្នដែរ ដូច្នេះប្រសិនបើកម្មវត្ថុមិនមាននៅពេលចុះកិច្ចសន្យាដោយសារកម្មវត្ថុបានបាត់បង់ កិច្ចសន្យានឹងពុំមានសុពលភាពឡើយ ។

### ៣.១. ជនដែលអនុញ្ញាតឲ្យចុះកិច្ចសន្យា

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជនដែលត្រូវបានអនុញ្ញាតិក្នុងការធ្វើសកម្មភាពសំដៅដល់រូបវន្តបុគ្គលទាំងឡាយណាដែលមានសមត្ថភាពក្នុងការយល់ដឹងនិងវិនិច្ឆ័យពី សកម្មភាពតាមផ្លូវច្បាប់របស់ខ្លួនបាន ។ ហើយបានកំណត់យកជនដែលត្រូវបានអនុញ្ញាតិក្នុងការធ្វើសកម្មភាព ដោយផ្អែកទៅលើ

សមត្ថភាពរបស់ជននោះមានចំនួន ០៣ (បី)ប្រភេទ គឺ៖ នីតិជន, អនីតិជនមានអត្តាធីនភាព អនីតិដែលត្រូវបាន អនុញ្ញត្តិឲ្យប្រកបអាជីវកម្មបាន ។

### ៣.១.១. អនីតិជន

តាមន័យទូទៅអនីតិជន គឺជាបុគ្គលដែលមានអាយុគ្រប់តាមច្បាប់បានកំណត់ ហើយមានសមត្ថភាព ឯករាជ្យខាងអំពើ។[18] យោងតាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ នីតិជន សំដៅទៅលើជន ដែលមានអាយុ ១៨ឆ្នាំ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ ក្នុងការបង្កើតកិច្ចសន្យា នីតិជនត្រូវបានកំណត់ថាជាជនដែល មានសមត្ថភាពពេញលេញទាំងស្រុងក្នុងការសំរេចចិត្ត និងធ្វើសកម្មភាពបង្ហាញឆន្ទៈចុះកិច្ចសន្យាមួយបាន។ ជាទូទៅប្រភេទមនុស្សមួយចំនួន មិនអាចមានសមត្ថភាពចុះកិច្ចសន្យាបានទេ ប៉ុន្តែមានករណីមួយចំនួនទៀត ដែលច្បាប់អនុញ្ញាតឲ្យចុះកិច្ចសន្យាបានដែរដូច ៖

#### ៣.១.១.១. អនីតិជនមានអត្តាធីនភាព

យោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី «អត្តាធីនភាព» គឺជាស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបាន រួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ឬ រួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

អត្តាធីនភាព គឺមានអានុភាពអាចធ្វើឱ្យច្បាប់ចាត់ទុកថាអនីតិជននោះបានដល់នីតិភាពហើយ (ក្លាយ ជាជនដែលមានសិទ្ធិដូចនីតិជនដែលមានអាយុគ្រប់ ១៨ ឆ្នាំ ផងដែរ) និងអាចធ្វើសកម្មភាពបានដូចជានីតិជន ដែរ។ ដោយសារតែអានុភាពនេះ អនីតិជននោះអាចធ្វើសកម្មភាពពាណិជ្ជកម្ម ដូចជាការបើកអាជីវកម្មផ្ទាល់ខ្លួន ដោយមិនចាំបាច់មានការអនុញ្ញាតពីម្តាយឪពុក (អ្នកដែលមានអំណាចមេបា) ឬ អ្នកអាណាព្យាបាលសម្រាប់អ នីតិជន។ អនីតិជន ព្រមទាំងអាចធ្វើសកម្មភាពកិច្ចសន្យា ដោយអាចបង្កើត កែប្រែ និងរំលត់កាតព្វកិច្ចបាន និង

[18] សន្ទានុក្រមផ្នែករដ្ឋប្បវេណី (អនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការរដ្ឋមន្ត្រី ឆ្នាំ ២០០៧)

អាចធ្វើនូវសកម្មភាពឯកតោភាគីបានថែមទៀត។ លើសពីនេះទៀត អនីតិជនអាចទទួលបាននូវបុគ្គលភាពគតិយុត្ត (ភាពជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច) យ៉ាងពេញលេញទៀតផង។[19]

- ក្នុងករណីដែលអនីតិជនដែលបានដល់អាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ មិនចាំបាច់ពឹងពាក់នរណា តុលាការអាចប្រកាសនូវអត្តាធីនភាពបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជន។ ក្នុង ករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានអំណាចមេបាផងដែរ។
- ផ្សេងពីល័ក្ខខ័ណ្ឌខាងលើ ប្រសិនបើអនីតិជននោះបានរៀបអាពាហ៍ពិពាហ៍ហើយ អនីតិជនក៏អាចទទួលបាននូវអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការឡើយ (ក្នុងករណីនេះ ទោះបីភាគីនៃចំណងអាពាហ៍ពិពាហ៍បានលែងលះគ្នាហើយក៏ដោយ ក៏អានុភាពនៃអត្តាធីភាព មិនត្រូវរលត់ឡើយ)។

### ៣.១.១.២. អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម

អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ៖

១- អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបាន ដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការ អាជីវកម្មនោះបាន អ្នកមានអំណាច មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។[20]

[19] ក្រមរប្បវេដ្ឋណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០,០៨ ធ្នូ ២០០៧, មាត្រា ២១

[20] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០

## ៣.២. ជនដែលមិនអនុញ្ញាតឱ្យចុះកិច្ចសន្យា

ចំពោះបុគ្គលដែលខ្វះប្រការណាមួយនៃបញ្ញាស្មារតី ឬ អាយុ ជាបុគ្គលដែលអសមត្ថភាពក្នុងការធ្វើកិច្ចសន្យា តាមកំណត់ច្បាប់បុគ្គលនោះមិនអាចធ្វើការចុះកិច្ចសន្យាសុពលភាពមួយបានទេ។ ជនទាំងនោះត្រូវបានចាត់ទុកថាជាអសមត្ថជនក្នុងការចុះកិច្ចសន្យា។ អសមត្ថជន គឺជាជនដែលគ្មានសមត្ថភាពក្នុងការធ្វើអ្វីមួយដែលច្បាប់ហាមឃាត់ បានមានន័យថា អសមត្ថជននោះ ទោះបីជាមានអាយុលើសពី ១៨ឆ្នាំ ក៏ដោយ ក៏មិនអាចចុះកិច្ចសន្យា បង្កើតសិទ្ធិ និងករណីកិច្ចបានឡើយដោយហេតុថាសិទ្ធិតាមផ្លូវច្បាប់របស់ជននោះត្រូវបានកំណត់ដូចជា ៖ អនីតិជននៅក្រោមអំណាចមេបា ជននៅក្រោមហិតូបត្ថម្ភ និង ជននៅក្រោមអាណាព្យាបាលទូទៅ។

### ៣.២.១. អនីតិជននៅក្រោមអំណាចមេបា

អនីតិជននៅក្រោមអំណាចមេបាសំដៅទៅលើជនដែលមិនទាន់ដល់នីតិភាព ពោលគឺមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ។ ជាគោលការណ៍អនីតិជនមិនអាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបានទេ ជារួមសកម្មភាពដែលបានធ្វើឡើងដោយឯករាជ្យអាចត្រូវបានលុបចោល។ ដើម្បីអោយអនីតិជននៅក្រោមអំណាចមេបាអាចធ្វើសកម្មភាពបាន គឺចាំបាច់ត្រូវធ្វើសកម្មភាពតាមរយៈអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន នោះ។ ចំពោះអនីតិជនដែលចង់ ធ្វើសកម្មភាពគតិយុត្តបានលុះត្រាតែ ទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ប៉ុន្តែជាករណីលើលែងអនីតិជនត្រូវបានទទួលស្គាល់អោយធ្វើសកម្មភាពឯករាជ្យចំពោះសកម្មភាពទាំងឡាយណាដែលមិនសូវសំខាន់ ។

### ៣.២.២. ជនដែលនៅក្រោមហិតូបត្ថម្ភ

ចំពោះហិតូបត្ថម្ភ៖ ចំពោះបុគ្គលដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹង និងវិនិច្ឆ័យដោយ សារបញ្ហាស្មារតី តុលាការអាចប្រកាសចាប់ផ្តើមហិតូបត្ថម្ភតាមរយៈពាក្យសុំរបស់សាមីខ្លួន, សហព័ទ្ធ, ញាតិដែលស្ថិតក្នុង ៤ ថ្នាក់, អ្នកអាណាព្យាបាល, អ្នកត្រួតពិនិត្យអាណាព្យាបាលទូទៅ, មេឃុំ ឬចៅសង្កាត់ ឬ

តំណាងអយ្យការ ។[21] មុនពេលប្រកាសរបបនេះ តុលាការត្រូវស្តាប់មតិយោបល់របស់វេជ្ជបណ្ឌិត និងផ្តល់ឱកាសឲ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួន ពិតជាមានបញ្ហាផ្នែកស្មារតី និងមានការយល់ដឹងតិចតួចពិតប្រាកដមែន ។

ហិតូបត្ថម្ភកៈ ជាអ្នកមានតួនាទីត្រួតពិនិត្យ និងថែរក្សាជនស្ថិតក្រោមហិតូបត្ថម្ភ។ តុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈដោយឆន្ទានុសិទ្ធិចំណែកឯនីតិវិធីនៃការជ្រើសតាំង ហិតូបត្ថម្ភកៈត្រូវអនុវត្តដូចការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ។[22]

ជាគោលការណ៍ សកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ ដែលមិនបានការយល់ព្រមពីហិតូបត្ថម្ភកៈត្រូវមានការលុបចោលលុះត្រាតែសកម្មភាពនោះជាសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ។ ប៉ុន្តែក្នុងករណីមានការយល់ព្រមពី ហិតូបត្ថម្ភកៈសាមីខ្លួន អាចធ្វើសកម្មភាពដូចជាៈ ការទទួល ឬការប្រើប្រាស់ទុន, ការខ្ចីទ្រព្យ ឬការធានា, ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឲ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត, ការធ្វើសកម្មភាពបណ្តឹង, ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម, ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសន្តតិកម្ម ឬការបែងចែកមត៌ក, ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់បន្ទុក, ការសាងសង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ, ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លីលើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែចំពោះអចលនវត្ថុ និងសកម្មភាពដែលតុលាការប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហតូបត្ថម្ភកៈ ។

### ៣.២.៣. ជននៅក្រោមអាណាព្យាបាលទូទៅ

ចំពោះជនក្រោមអាណាព្យាបាលទូទៅ៖ ចំពោះបុគ្គលដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ហើយខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យជាអចិន្ត្រៃយ៍ ដោយខ្លួនមានបញ្ហាស្មារតី តុលាការអាចប្រកាសចាប់ផ្តើមរបបអាណាព្យាបាលទូទៅ តាមរយៈពាក្យសុំរបស់សាមីខ្លួន, សហព័ទ្ធ, ញាតិដែលស្ថិតក្នុង ៤ ថ្នាក់, អ្នក

[21] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០,០៨ ធ្នូ ២០០៧, មាត្រា២៨ កថាខណ្ឌទី១
[22] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០,០៨ ធ្នូ ២០០៧, មាត្រា២៩

អាណាព្យាបាលសម្រាប់អនីតិជន, អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន, ហិតូបត្ថម្ភកៈ, មេឃុំ ឬចៅសង្កាត់, ឬតំណាងអយ្យការ ។[23] មុនពេលប្រកាសរបបនេះតុលាការត្រូវស្តាប់មតិយោបល់របស់វេជ្ជបណ្ឌិត និងផ្តល់ឱកាសឲ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួន ពិតជាមានបញ្ហាផ្នែកស្មារតីពិតប្រាកដមែន ។

អ្នកអាណាព្យាបាលទូទៅ ជាអ្នកគ្រប់គ្រងត្រួតពិនិត្យលើជននៅក្រោមអាណាព្យាបាលទូទៅ ហើយតុលាការជ្រើសតាំងអ្នកអាណាព្យាបាលដោយឆន្ទានុសិទ្ធិ និងត្រូវធ្វើឡើងតាមរយៈការទាមទាររបស់ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ, ជនក្រោមអាណាព្យាបាលទូទៅ, សហព័ទ្ធ, ញាតិនៅក្នុង ៤ ថ្នាក់, មេឃុំ, ចៅសង្កាត់, តំណាងអយ្យការ ឬបុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ ។

ជាគោលការណ៍សកម្មភាពរបស់ជនក្រោមអាណាព្យាបាលទូទៅអាចលុបចោលបាន លុះត្រាតែសកម្មភាពនោះជាសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាការទិញបាយ,ម្ហូប,របស់ប្រើប្រាស់ប្រចាំថ្ងៃជាដើម ។ កិច្ចសន្យាមានសរសេរកាលបរិច្ឆេទ ស្នាមម្រាមដៃ អំពីតម្លៃ ពេលវេលា និងកម្មវត្ថុនៃកិច្ចសន្យាជាដើម ។

[23] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៥

# ជំពូកទី ២
# វិការៈនៃកិច្ចសន្យា

# ជំពូកទី ២ វិការៈនៃកិច្ចសន្យា

## ផ្នែកទី ១ ៖ វិការៈ

### ១.១ និយមន័យ

វិការៈ គឺជាការប្រែប្រួលចាកពីភាពប្រក្រតី។ [24]

### ១.២ សញ្ញាណវិការៈនៃកិច្ចសន្យា

វិការៈគឺជាកាបង្ហាញឆន្ទៈដែលខុសប្រក្រតីបណ្តាលឲ្យកិច្ចសន្យាអាចត្រូវបាន ភាគីណាមួយ ឬគូភាគីមានសិទ្ធិលុបចោល ឬអាចលុបចោលបាន ដោយហេតុថាការបង្ហាញឆន្ទៈមានវិការៈ។ វិការៈក្នុងការបង្ហាញឆន្ទៈស្តែងឡើងនោះមានខ្លះកើតចេញពីឆន្ទៈរបស់បុគ្គល និង ខ្លះទៀតក្រៅឆន្ទៈបុគ្គល ។ កិច្ចសន្យាដែលបានបង្កើតនៅតែមានសុពល តែអាចលុបចោលបាន ដែលមានសញ្ញាណដូចខាងក្រោម៖

- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ
- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត
- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។

## ផ្នែកទី២ ៖ ប្រភេទនៃវិការៈក្នុងកិច្ចសន្យា

### ២.១ ការភាន់ច្រឡំ

ការភាន់ច្រឡំគឺ ជាការបង្ហាញឆន្ទៈ ខុសទៅនឹងឆន្ទៈពិតរបស់ភាគី ដោយមិនបានដឹងពីភាពខុសគ្នានេះនៅពេលធ្វើការបង្ហាញឆន្ទៈ ឬ បង្កើតកិច្ចសន្យា ។ [25]

[24] សន្ធានុក្រម ផ្នែកក្រមរដ្ឋប្បវេណី លេខ ១៣៥

[25] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៥

## ២.១.១ ល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំ

ចំណុចសំខាន់នៃកិច្ចសន្យាមានការភាន់ច្រឡំដោយសារអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំពីចំណុចដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញសំខាន់ក្នុងការបង្កើតកិច្ចសន្យាហើយភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងពីភាពសំខាន់នៃចំណុចនេះ នឹងអំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ។

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញ ចំណុចសំខាន់ជាទូទៅ ថ្លៃលក់ វត្ថុលក់ អ្នកលក់ និង អ្នកទិញ ហើយចំណុចដែលមិនសំខាន់ក្នុងកិច្ចសន្យាលក់ទិញជាទូទៅ ពេលវេលា ទីកន្លែង បង្កើតកិច្ចសន្យាលក់ទិញ។

នៅក្នុងល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំដោយអ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានក្នុងករណីដូចខាងក្រោម៖

### ២.១.១.១ ចំណុចដែលភាគីបង្ហាញឆន្ទៈយល់ឃើញថាសំខាន់

កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបាន ប្រសិនបើកិច្ចសន្យានោះ មានការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។ [26]

ឧទាហរណ៍៖ អ្នកទិញបានទិញម៉ូតូដោយនឹងស្មានថាជាផលិតផលរបស់ប្រទេសជប៉ុន ប៉ុន្តែម៉ូតូនោះជាផលិតផលរបស់ប្រទេសថៃទៅវិញនៅពេលដែលមានការបញ្ជាក់សួរដេញដោរទៅអ្នកលក់ហើយបានធ្វើកិច្ចសន្យាហើយក្តី ដោយហេតុផលនេះ អ្នកទិញដែលជាអ្នកបង្ហាញឆន្ទៈអាចធ្វើការលុបចោលនូវកិច្ចសន្យាលក់ទិញនេះបាន។

### ២.១.១.២ ភាគីទាំងសងខាងភាន់ច្រឡំ

ការភាន់ច្រឡំដោយភាគីទាំងសងខាង អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានទោះបីជាភាគីម្ខាងទៀត មិនបានដឹងអំពីការភាន់ច្រឡំនេះក៏ដោយ ។ នៅក្នុងករណីនេះគូភាគីទាំងសងខាងមានការភាន់ច្រឡំដូច្នេះភាពចាំបាច់នៅក្នុងការការពារភាគីម្ខាងទៀត គឺមានភាពសមធម៌រវាងគ្នា ដែលខុសពីករណីដែលមានតែភា

[26] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, គន្ថីទី៤, រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា ៣៥៦

គីម្ខាងមានការភាន់ច្រឡំ។ ដូច្នេះវាមិនមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀតឡើយ។ ឧទាហរណ៍៖ អ្នកលក់មានការភាន់ច្រឡំថាទូរស័ព្ទម៉ាកអាយហ្វូនដែលខ្លួនបានលក់ទៅឲ្យអ្នកទិញជាផលិតផលរបស់សហរដ្ឋអាមេរិក ហើយអ្នកទិញក៏មានការភាន់ច្រឡំផងដែរទៅលើផលិតផលនោះជាក់ស្តែងជាផលិតផលរបស់ប្រទេសកូរ៉េទៅវិញ ដូចនេះភាគីទាំងសងខាងអាចបង្ហាញឆន្ទៈលុបចោលនៅពេលដែលបានដឹងការពិត។

## ២.២ ការឆបោក

ការឆបោក គឺជាការបោកបញ្ឆោត ការបន្លំ ការបោកប្រាស់ ការកុហក ឬប្រើប្រាស់កលល្បិចផ្សេងៗ ដែលធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ។[27] ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថាបុគ្គលណាម្នាក់ ឬតតិយជនបានធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងមិនបានដឹងពីភាពខុសគ្នានេះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ។

### ២.២.១ លក្ខខណ្ឌនៃការឆបោក

លក្ខខណ្ឌដើម្បីកំណត់ថាវាជាការឆបោកនោះ គឺមិនមានចែងក្នុងក្រមរដ្ឋប្បវេណីច្បាស់លាស់ ប៉ុន្តែយើងអាចកំណត់បាននូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងទុច្ចរិត
- សកម្មភាពឆបោកដោយចេតនា ត្រូវបានទទួលស្គាល់ថាខុសច្បាប់
- អ្នកបង្ហាញឆន្ទៈ បានភាន់ច្រឡំដោយសារសកម្មភាពឆបោក

[27] វចនានុក្រមសម្តេចសង្ឃជួនណាត

### ២.២.១.១ គោលបំណងទុច្ចរិត

គោលបំណងទុច្ចរិត សំដៅទៅលើភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ និងបង្ហាញឆន្ទៈដោយមានវិការៈដោយសារតែការភាន់ច្រឡំនោះ។ គោលបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ មានន័យថាភាគីម្ខាងទៀត ឬតតិយជនបានដឹងថាសកម្មភាពរបស់ខ្លួនគឺជាសកម្មភាពឆបោក និងអ្នកបង្ហាញឆន្ទៈនឹងមានការភាន់ច្រឡំដោយសារសកម្មភាពរបស់ខ្លួន។ ទន្ទឹមនឹងនេះគោលបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈបង្ហាញឆន្ទៈដោយវិការៈដោយការភាន់ច្រឡំ។[28]

### ២.២.១.២ ការឆបោក ដែលប្រព្រឹត្តដោយភាគីម្ខាងទៀត

ភាគីម្ខាងទៀតបានផ្តល់ព័ត៌មានក្លែងក្លាយដោយចេតនា ជាការបោកបញ្ឆោតមួយធ្វើឲ្យអ្នកបង្ហាញឆន្ទៈយល់ខុសពីការគិតរបស់ខ្លួន ហើយបានបង្ហាញឆន្ទៈដោយយល់ខុស។ បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ឧទាហរណ៍៖ ហាងលក់សម្លៀកបំពាក់មួយកន្លែង មានអ្នកលក់ហៅ A និងអ្នកទិញហៅ B ដែល B បានដាក់សំណើចង់ទិញអាវពីហាងរបស់ A ហើយ A ជាអ្នកលក់បានធ្វើការបោកបញ្ឆោត កុហកដោយចេតនា ថាអាវដែលខ្លួនលក់ឲ្យ B ជាផលិតផលដើមរបស់សហរដ្ឋអាមេរិក ឬ Original ប៉ុន្តែការពិតជាផលិតផលរបស់ថៃ ឬ Copy ។ ប្រសិនបើអ្នកធ្វើសំណើបានបង្កើតកិច្ចសន្យាខុសពីឆន្ទៈពិតដែលកើតចេញពីការកុហក បោកបន្លំបានបង្កើតកិច្ចសន្យាពិតរួចហើយក្តី បើទោះបីអ្នកបង្ហាញឆន្ទៈត្រូវបានបន្ទោសថាឲ្យគេបោកក៏ដោយ ក៏ចាំបាច់ត្រូវការពារអ្នកបង្ហាញឆន្ទៈដែរ ដោយអ្នកធ្វើសំណើ ឬ អ្នកធ្វើការបង្ហាញឆន្ទៈនោះមានសិទ្ធិអះអាងអំពីវិការៈនេះជាហេតុនាំឱ្យមានការរំលាយកិច្ចសន្យា ។

### ២.២.១.៣ ការឆបោក ដែលប្រព្រឹត្តដោយតតិយជន

ក្នុងករណីដែលការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោករបស់ភាគីម្ខាងទៀត វាមិនមានបញ្ហាអ្វីកើតឡើងឡើយ ការលុបចោលត្រូវបានអនុញ្ញាតសម្រាប់អ្នកមានសិទ្ធិលុបចោល ព្រោះច្បាប់មិនការពារជនទុច្ចរិតដែលជាភាគីម្ខាងទៀតទេ។ [29] ប៉ុន្តែ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោក

[28] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៧កថាខណ្ឌទី ១

[29] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៧ កថាខណ្ឌទី ២

របស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬអាចដឹងអំពីការឆបោកនោះ។

ឧទាហរណ៍៖ លោក A ជាអ្នកចង់ទិញរថយន្តរបស់លោក B ប៉ុន្តែគ្មានចំណេះជំនាញខាងមើលរថយន្តឡើយ ហើយក៏បានពឹងពាក់ឱ្យលោក C ដែលជាអ្នកមានជំនាញខាងមើលបច្ចេកទេសរថយន្ត ដើម្បីអាចដឹងថារថយន្តនោះមានប្រវត្តិយ៉ាងណា ពោលគឺធ្លាប់ត្រូវបានខូចខាតដោយគ្រោះថ្នាក់ចរាចរណ៍ដែរ ឬ យ៉ាងណា បើទោះបី C ដឹងថារថយន្តនេះធ្លាប់ខូចខាត់ដោយគ្រោះថ្នាក់ចរាចរណ៍ដ៏ដោយ ក៏លោកC មានចេតនាទុច្ចរិតក្នុងគោលបំណងដើម្បីប្រយោជន៍ខ្លួនបានប្រាក់ឈ្នួលពឹងពាក់ពី A ដោយកុហកថារថយន្តនេះមិនបុកប៉ះ ។

ក្នុងករណី A ត្រូវបានបោកបន្លំ ដោយចេតនាតាមរយៈរបស់តតិយជន C ហើយបានបង្កើតកិច្ចសន្យាជាមួយ B ប្រសិនបើ A ត្រូវបានអនុញ្ញាតឲ្យលុបចោលកិច្ចសន្យាជាមួយ B ដោយហេតុផលនៃការឆបោករបស់ C នោះភាគីសុចរិត B អាចទទួលរងនូវការខូចខាតដែលមិនបានគិតទុកមុន។ ក្នុងករណីនេះ ច្បាប់ការពារជនសុច្ចរិតដែលត្រូវនូវការឆបោកជាមួយនឹងផលប្រយោជន៍របស់ភាគីម្ខាងទៀត ។ ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន ប៉ុន្តែផ្ទុយទៅវិញអ្នកបង្ហាញឆន្ទៈ មិនអាចអះអាងពីការលុបចោលដោយសំអាងថា ការបង្ហាញឆន្ទៈរបស់ខ្លួនមានវិការៈបានទេ ប្រសិនបើតតិយជន បានធ្វើសកម្មភាពដោយសុចរិត និង គ្មានកំហុស។

#### ២.២.១.៤ ភាពខុសច្បាប់នៃសកម្មភាពឆបោក

ភាពខុសច្បាប់មានន័យថា សកម្មភាពឆបោករបស់ភាគីម្ខាងទៀត ឬ តតិយជនត្រូវតែជាសកម្មភាពផ្ទុយច្បាប់ និងមិនអាចទទួលយកបានក្នុងសង្គម។ ទន្ទឹមនឹងនេះសកម្មភាពទាំងនោះត្រូវបានចាត់ទុកថា ខុសច្បាប់ មិនត្រឹមតែក្នុងករណីដែលបង្ហាញពត៌មានមិនពិតនោះទេ គឺថែមទាំងជាការលាក់ពត៌មាន ឬរក្សាភាពស្ងប់ស្ងាត់ក្នុងករណីដែលជននោះមានកាតព្វកិច្ចបង្ហាញពត៌មានជាដើម។

## ២.៣ ព័ត៌មានមិនពិត

ព័ត៌មានមិនពិត សំដៅលើព័ត៌មានបង្ហាញហេតុការណ៍មិនពិត ហេតុដែលខុសពីការពិតជាអាទិ៍ ដែលភាគីម្ខាងបានមានកំហុសដោយអចេតនាទៅភាគីម្ខាងទៀតនៃកិច្ចសន្យា។ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុ

ទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។[30]

### ២.៣.១ ល័ក្ខខ័ណ្ឌនៃព័ត៌មានមិនពិត

នៅក្នុងករណីនៃព័ត៌មានមិនពិត គេតម្រូវឲ្យភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលគាត់បានលើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើភាគីម្ខាងទៀតនោះបានដឹងថាហេតុនោះខុសពីការពិត ត្រូវបានគេចាត់ទុកថាជាការឆបោក។ ល័ក្ខខ័ណ្ឌនៃព័ត៌មានមិនពិតយើងអាចទាញបាន ៣ ល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- ភាគីម្ខាងទៀតផ្តល់នូវហេតុ ឬ ព័ត៌មានណាមួយ ដោយហេតុ ឬ ព័ត៌មាននោះផ្ទុយពីការពិត
- អ្នកបង្ហាញឆន្ទៈជឿជាក់ថាព័ត៌មានដែលបានផ្តល់នោះជាការពិត ប្រសិនបើអ្នកបង្ហាញឆន្ទៈបានដឹងថាហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ
- ភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលខ្លួនបានបង្ហាញនោះ មិនមែនជាការពិត ។

#### ២.៣.១.១ ព័ត៌មានផ្ទុយពីការពិត

ជាសកម្មភាពការបង្កើតកិច្ចសន្យាមួយដែលធ្វើឡើងដោយមានវិការៈ ពីព្រោះដោយការផ្តល់នូវព័ត៌មានមិនពិត ដោយភាគីម្ខាងទៀត ដែលជាទូទៅក្នុងកិច្ចសន្យាលក់ទិញ គឺជាអ្នកលក់តែម្តង ដែលបានបង្កើតកំហុសឆ្គងដោយអចេតនា ភាពមិនប្រាកដវិជ្ជា ធ្វេសប្រហែស ដែលនាំឲ្យខូចផលប្រយោជន៍របស់អ្នកទិញជានិច្ចជាកាល។

ឧទាហរណ៍៖ លោក A បានលក់កាបូបទៅឲ្យលោកស្រី B ដោយប្រាប់ថាជាផលិតផលស្បែកសុទ្ធ១០០%មិនប្រែពណ៌ ដុតមិនងាយឆេះជារបស់ប្រទេសItaly ប៉ុន្តែធាតុពិតក្នុងការផ្តល់ព័ត៌មានរបស់ A នោះជាផលិតផលស្បែកលាយជ័រ និង គុណភាពខុសពីការពិតទៅវិញ។

[30] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៨

### ២.៣.១.២ អ្នកបង្ហាញឆន្ទៈដឹងថាហេតុមិនពិត និងមិនបង្ហាញឆន្ទៈទេ

ការផ្តល់ព័ត៌មានមិនពិត ពិតជាធ្វើឲ្យបាត់បង់ទំនុកចិត្ត ព្រោះដោយហេតុថាការជឿជាក់ប្រែជាផ្ទុយនឹងឆន្ទៈសម្រេចចិត្តរបស់ភាគីទៅវិញ គឺខុសការគិត និង បំណង ប្រសិបបើអ្នកបង្ហាញអាចដឹងពីការពិត ច្បាស់ណាស់ខ្លួននឹងមិនបង្ហាញឆន្ទៈក្រៅឆន្ទៈរបស់ខ្លួនឡើយ ឬ យើងអាចនិយាយបានថានឹងគ្មានកិច្ចសន្យាកើតឡើងបានឡើយ ប្រសិនដឹងហេតុការណ៍ពិត ក៏ប៉ុន្តែយ៉ាងណា ច្បាប់មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស។

### ២.៣.១.៣ ភាគីម្ខាងទៀតមិនដឹងអំពីព័ត៌មានមិនពិត

ការផ្តល់ព័ត៌មានមិនពិត ត្រូវបានសង្គមបច្ចុប្បន្ន ឬក៏មហាជន ធ្វើការភាន់ច្រឡំថាជាការឆបោក ប៉ុន្តែតាមទិដ្ឋភាពច្បាប់ ការបង្ហាញឆន្ទៈនេះមិនអាចលុបចោលដោយហេតុផលនៃការឆបោកបានឡើយ ពីព្រោះដោយហេតុថាគូភាគីនៃកិច្ចសន្យាអាចសុទ្ធតែជាបុគ្គលសុច្ចរិតដែលមិនបានដឹង អំពីការណ៍មិនពិត ម្យ៉ាងទៀតក្នុងករណីដែលព័ត៌មានមិនពិតត្រូវបានបង្ហាញដោយភាគីម្ខាងទៀត មានករណីច្រើនដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូច្នេះការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផលនៃការភាន់ច្រឡំផង ដែរ ។ ប្រសិនបើភាគីដែលបង្ហាញព័ត៌មានមិនពិត មានកំហុសក្នុងការបង្ហាញព័ត៌មានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងសំណងការខូចខាត ។ ក្នុងករណីនេះ ការកំណត់លំអិតអំពីការខូចខាតមានការលំបាក។ ការលំបាកនេះទុកឲ្យដោះស្រាយតាមរយៈយុត្តិសាស្ត្រ និង ទ្រឹស្តី នៅពេលអនាគត។ កិច្ចសន្យាដែលត្រូវបានលុបចោលដោយសារហេតុផលនៃព័ត៌មានមិនពិត អានុភាពនៃការលុបចោលកិច្ចសន្យាអាចតតាំងបាន មិនត្រឹមចំពោះភាគីម្ខាងទៀតប៉ុណ្ណោះទេ ថែមទាំងតតិយជន ដូចជាអ្នកដែលធ្វើលទ្ធកម្មជាបន្តបន្ទាប់ផងដែរ ។

ឧទាហរណ៍ ៖ គោយន្តមួយគ្រឿងត្រូវបានចោរលួចដោយ A ហើយលក់ទៅឱ្យ B ដោយចោរនោះប្រាប់ថា ជាគោយន្តរបស់ខ្លួន ហើយ A បានទិញដោយជឿកជាក់ថាពិតជារបស់ A ពីព្រោះគោយន្តគ្មានកាត់គ្រី មិនអាចកំណត់អត្តសញ្ញាណជារបស់បុគ្គលណាឡើយ ហើយ B បានធ្វើការលក់បន្តទៅឱ្យតតិយជនផ្សេងទៀត ។ [31]

[31] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, គន្ថីទី៤, រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា ៣៤៨

## ២.៤ ការរំលោភលើស្ថានភាព

ការរំលោភលើស្ថានភាព គឺជាការប្រើដោយមិនត្រឹមត្រូវនូវឋានៈរបស់ខ្លួន ទៅលើភាគីម្ខាងទៀតដែលមិនអាចតបតបាន។ នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ការលុបចោលកិច្ចសន្យាដោយមូលហេតុនៃការរំលោភ លើស្ថានភាពនៃ ភាគីមិនអាចអះអាងចំពោះ តតិយជនបានឡើយ ប្រសិនបើតតិយជននោះសុចរិត និងគ្មានកំហុស។[32]

### ២.៤.១ល័ក្ខខ័ណ្ឌនៃការរំលោភលើស្ថានភាព

លក្ខខណ្ឌនៃការរំលោភបំពានលើស្ថានភាព យើងអាចទាញបាន ៣ ល័ក្ខខ័ណ្ឌៈ

- ភាគីម្ខាងមានឋានៈ ឬស្ថានភាពផ្សេងទៀត ដែលមានឥទ្ធិពលជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម
- បង្ហាញឆន្ទៈដោយមានការភ័យខ្លាច
- ភាគីម្ខាងទៀត មិនអាចប្រឆាំងតបតបាន ហើយធ្វើការបង្ហាញឆន្ទៈ

#### ២.៤.១.១. ឋានៈ ឬ ស្ថានភាព មិនស្មើគ្នា

ករណីដែលភាគីម្ខាងបង្ខំភាគីម្ខាងទៀតឲ្យចុះកិច្ចសន្យាតាមរយៈការប្រើឋានៈរបស់ខ្លួនដែលមានអាទិភាពជាងខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ទោះបីជាករណីនេះមិនមែនជាការគម្រាមកំហែងក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈត្រូវបានបង្ខំឲ្យបង្ហាញឆន្ទៈដែលខ្លួនមិនមានបំណងធ្វើដែរ ហេតុដូច្នេះ ការបង្ហាញឆន្ទៈនោះមានវិការៈ ហើយច្បាប់អនុញ្ញាតអាចឲ្យធ្វើការលុបចោលកិច្ចសន្យាដែលមានការបង្ហាញបែបនេះជាធាតុផ្សំ។ ប៉ុន្តែ មានករណីជាច្រើនដែលកិច្ចសន្យាត្រូវបានបង្កើតឡើងតាមរយៈការប្រើឋានៈដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ហើយមិនមែនគ្រប់ករណីទាំងអស់ដែលគេអាចលុបចោលនូវកិច្ចសន្យាបាននោះទេ ដូច្នេះអ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន លុះត្រាតែក្នុងករណីដែលមាន ការប្រើដោយមិនត្រឹមត្រូវនូវឋានៈ ឬ

[32] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៩

ស្ថានភាព ។ តើការប្រើដោយមិនត្រឹមត្រូវ មានន័យបែបណានោះ ត្រូវវិនិច្ឆ័យផ្អែកតាមករណីនីមួយៗ។

ឧទាហរណ៍ ៖ A ជាមន្ត្រីឃោធាដែលមានអំណាចជាភាគីដាក់សំណើចង់ទិញដីរបស់ B ជាកសិករធ្វើស្រែចំការ ។ ការរំលោភលើស្ថានភាព ក្នុងករណីដែលភាគីម្ខាងដឹង ឬ គួរដឹងថា ភាគីម្ខាងទៀត ត្រូវបាននាំឲ្យធ្វើសកម្មភាពគតិយុត្តដែលជាលទ្ធផលនៃស្ថានភាពពិសេសដូចជា ភាពចាំបាច់ ភាពពឹងពាក់ ការធ្វើសកម្មភាពភ្លាមៗដែលខ្វះការពិចារណា ស្ថានភាពខាងប្រាជ្ញាមិនប្រក្រតី ឬ ភាពខ្វះខាតបទពិសោធន៍ ហើយជំរុញឲ្យភាគីម្ខាងទៀតធ្វើសកម្មភាពបែបនេះ ទោះបីជាខ្លួនមិនគួរនាំឲ្យភាគីម្ខាងទៀតធ្វើសកម្មភាពនោះក៏ដោយ នោះភាគីនោះប្រព្រឹត្តសកម្មភាពរំលោភលើស្ថានភាព។ ហេតុដូច្នេះច្បាប់គិតពីប្រយោជន៍ក្នុងការការពារអ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬ សង្គម។

#### ២.៤.១.២. បង្ហាញឆន្ទៈដោយមានការភ័យខ្លាច

យើងអាចសន្មត់ក្នុងចិត្តអ្នកបង្ហាញឆន្ទៈបានថាមានការភិតភ័យ ដោយហេតុផលស្ថិតក្រោមរូបភាពមួយ ក្នុងស្ថានភាពដែលខុសគ្នា ក្នុងជីវភាពផ្នែកសេដ្ឋកិច្ច ឬ ឋានៈ ឬ ឥទ្ធិពលអំណាចក្នុងការប្រៀបផ្ទឹម វាពិតណាស់ពិបាកក្នុងការបង្កើតកិច្ចសន្យាមួយដោយមិនរំលោភបំពានភាគី ដោយសារហេតុនេះហើយ អ្នកបង្ហាញឆន្ទៈអាចជាមានការភ័យខ្លាច ដោយខ្លួនឯងដាក់ជាមិនខាននឹងបង្ហាញឆន្ទៈច្បាស់ជាមានវិការៈ។

#### ២.៤.១.៣. ការបង្ហាញឆន្ទៈដោយមិនអាចតបតបាន

ការរំលោភលើស្ថានភាពសំដៅលើករណីដែលភាគីបានធ្វើការចុះកិច្ចសន្យាដោយឆ្លាតឱកាស ដែលភាគីម្ខាងទៀតកំពុងប្រទះនូវការលំបាកដោយសារកម្រិតនៃចំណេះវិជ្ជា ឬ ជាបុគ្គលទុនខ្សោយផ្នែកសង្គម ហើយភាគីម្ខាងទៀតបានប្រើមិនត្រឹមត្រូវនូវស្ថានភាព ដែលភាគីបង្ហាញឆន្ទៈមិនអាចប្រឆាំងតបតបាន។ ក្នុងករណីនេះភាគីដែលបានរំលោភបំពានលើស្ថានភាពមិនត្រូវបានគេចាត់ទុកថាបានគំរាមគំហែងឡើយ ព្រោះគាត់មិនបានប្រើវិធានការបង្ខិតបង្ខំឡើយ គឺវាស្រដៀងនឹងអំពើកេងចំណេញហួសហេតុទៅវិញ ព្រោះមានគោលបំណងចង់បានផលប្រយោជន៍លើសលុប ។ អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈខ្លួន ព្រោះគាត់មិនអាចបដិសេដការសំណើរបស់ភាគីម្ខាងទៀត ដោយសារឋានៈ និង ស្ថានភាពជីវភាពរបស់ខ្លួនទាបជាង។

## ២.៥ ការគម្រាមកំហែង

ការគម្រាមកំហែង គឺជាការប្រើប្រាស់ពាក្យសម្តី ឬកាយវិការជាអាទិ៍ ដើម្បីបង្ខំឲ្យនរណាម្នាក់ធ្វើអ្វីមួយទៅតាមការចង់បានរបស់ខ្លួន។ បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគំរាមគំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ [33]

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាទិញលក់អចលនទ្រព្យមួយកន្លែង លោក ក ដែលជាអ្នកមានបំណងចង់ទិញដីពីលោក ខ គាត់បានប្រើប្រាស់នូវសកម្មភាពដែលមានលក្ខណៈគំរាមគំហែងទៅលើលោក ខ ដោយសម្លុតថានឹងតាមធ្វើបាបក្រុមគ្រួសាររបស់លោក ខ ប្រសិនបើលោក ខ មិនលក់អចលនទ្រព្យមួយនោះឲ្យទៅខ្លួនក្នុងតម្លៃទាបមួយដែលខ្លួនចង់បាននោះទេ។ នៅក្នុងករណីនេះលោក ខ ដែលជាម្ចាស់អចលនទ្រព្យនោះ បានបង្ហាញឆន្ទៈរបស់ខ្លួនខុសពីឆន្ទៈពិតប្រាកដ លោក ខ អាចលុបចោលនូវកិច្ចសន្យានោះបានដោយហេតុថាគាត់ត្រូវបានគំរាមកំហែងពីសំណាក់លោក ក ដែលជាអ្នកទិញ។

### ២.៥.១ លក្ខខណ្ឌនៃការគម្រាមកំហែង

ល័ក្ខខ័ណ្ឌនៃការគំរាមគំហែង គឺមានដូចខាងក្រោម៖

- ភាគីម្ខាងទៀត ឬ តតិយជនមានគោលបំណង ឬ ចេតនាធ្វើឲ្យអ្នកបង្ហាញឆន្ទៈ ធ្វើការបង្ហាញឆន្ទៈដោយមានការភ័យខ្លាច
- សកម្មភាពគម្រាមកំហែងដោយខុសច្បាប់ ដោយភាគី ឬ តតិយជន
- អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈដោយការគំរាមកំហែង

#### ២.៥.១.១ ភាគីម្ខាងទៀត គម្រាមគំហែង

ការបង្ហាញឆន្ទៈដោយមានការគំរាមគំហែង សំដៅលើករណីដែលអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដែលផ្ទុយនឹងគោលបំណងពិត ដែលបង្កឡើងនូវភាពភ័យខ្លាចពីភាគីម្ខាងទៀត ឬ តតិយជន។

[33] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥០

### ២.៥.១.២ បង្ខិតបង្ខំដោយខុសច្បាប់

ការគំរាមកំហែងត្រូវបានសង្កត់ធ្ងន់បើកសិទ្ធិអនុញ្ញាតឲ្យអ្នកបង្ហាញឆន្ទៈធ្វើការលុបចោលនូវកិច្ចសន្យាខុសគ្នានឹងករណីការឆបោក ឬ ការភាន់ច្រឡំ ដោយច្បាប់បានកំណត់ក្នុងករណីនៃការគម្រាមកំហែងដែលធ្វើដោយតតិយជនក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈអាចអះអាងពីអានុភាពនៃការលុបចោលចំពោះតតិយជនបានទោះបីជាតតិយជននោះជាជនសុចរិត គ្មានកំហុស។ ហេតុនេះហើយ ផ្អែកតាមគោលការណ៍ទូទៅ អានុភាពនៃការលុបចោលកិច្ចសន្យា ដោយសារការគម្រាមកំហែង អាចតតាំងចំពោះតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់បាន។ ការកំណត់បែបនេះ មានគោលបំណងឲ្យជនរងគ្រោះនៃការគម្រាមកំហែង ទទួលបាននូវការការពារធំជាងជនរងគ្រោះនៃការឆបោក ជាអាទិ៍។

### ២.៥.១.៣ បង្កើតកិច្ចសន្យាដោយការភ័យខ្លាច

ស្ថានភាពមួយដែលអ្នកបង្ហាញឆន្ទៈភិតភ័យ ព្រួយបារម្ភ ការសំឡុតបំភ័យ តាមរយៈពាក្យសំដី ឬ កាយវិការ អាចធ្វើចំពោះអ្នកបង្ហាញឆន្ទៈផ្ទាល់ ឬ តាមរយៈជាសាច់ញាតិ ដែលបង្កឲ្យអ្នកបង្ហាញឆន្ទៈធ្វើដោយបង្ខំដោយគ្មានជម្រើស។ ក្នុងករណីនេះបញ្ញត្តិច្បាប់ បានការពារអ្នកបង្ហាញឆន្ទៈដោយការគម្រាមកំហែង អាចធ្វើការលុបចោលកិច្ចសន្យាបានដោយគ្មានកម្រិតការតតាំងចំពោះអានុភាពនៃការលុបចោលឡើយ។

## ២.៦ ការកេងចំណេញហួសហេតុ

ការកេងចំណេញហួសហេតុ គឺជាការឆ្លៀតឱកាសកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីភាគីម្ខាងទៀតដែលកំពុងជួបប្រទះការលំបាក។ អំពើកេងចំណេញហួសហេតុ សំដៅទៅលើករណីដែលភាគីម្ខាង បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាក ខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ [34]

[34] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥១

## ២.៦.១ លក្ខខណ្ឌនៃការកេងចំណេញហួសហេតុ

លក្ខខណ្ឌនៃការកេងចំណេញហួសហេតុ ៖

- អ្នកបង្ហាញឆន្ទៈ ស្ថិតក្នុងស្ថានភាពជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ដែលជះឥទ្ធិពលដល់ការបង្ហាញឆន្ទៈ
- ភាគីម្ខាងទៀតបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះពិសោធន៍
- ភាគីម្ខាងទៀត បានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា។

### ២.៦.១.១ លំបាកផ្នែកសេដ្ឋកិច្ច ភាពល្ងង់ ខ្វះបទពិសោធន៍

ការកេងចំណេញហួសហេតុកើតឡើងក្នុងស្ថានភាពមួយ ដែលអ្នកបង្ហាញឆន្ទៈកំពុងជួបផលវិបាកផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ខ្វះបទពិសោធន៍ ដែលជាឱកាសឲ្យភាគីម្ខាងទៀតកេងចំណេញ។

ឧទាហរណ៍៖ ភាគី ក ជាម្ចាស់អចលនវត្ថុដីមួយកន្លែង ដែលជាប្រភេទដីកសិកម្ម ដាំដុះដំណាំហូបផ្លែផ្សេងៗ ហើយភាគី ខ បានសុំទិញដីរបស់ភាគី ក ក្នុងតម្លៃទាបជាងទីផ្សារ ដោយភាគី ខ ដឹងថា ភាគី ក ជាមនុស្សល្ងង់មិនដឹងពីទីផ្សារអចលនវត្ថុរបស់ខ្លួន ហើយបានកេងចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់ពីភាគី ក ។ ហេតុនេះ នាំឲ្យការបង្កើតកិច្ចសន្យាមួយមានវិការៈ ហើយអ្នកបង្ហាញឆន្ទៈនោះ អាចមានសិទ្ធិលុបចោល ដោយបញ្ញត្តិច្បាប់បានការពារអ្នកទន់ខ្សោយ ក៏ដូចជាការពារ ការបំពាន់របស់ភាគីម្ខាងទៀត។

### ២.៦.១.២ ការកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់

ការកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ គឺកើតចេញពីឆន្ទៈរំលោភបំពានដៃគូនៃកិច្ចសន្យា ពីព្រោះដើម្បីទទួលបានផលប្រយោជន៍កេងចំណេញពីដៃគូដែលជាបុគ្គលមានចំណុចទន់ខ្សោយជាងលើសលប់ ។ ការកេងចំណេញមិនមានខ្នាត ការកម្រិតច្បាស់លាស់នោះទេ ដោយសង្គមនាពេលបច្ចុប្បន្នអាចសន្មត់ទៅតាមហេតុផលសីលធម៌សង្គម ឬ ការទទួលស្គាល់ពីសង្គម ។

ប្រទេសដែលអនុវត្តយកប្រព័ន្ធច្បាប់បារាំងចែងអំពីការហាមឃាត់ការកេងចំណេញហួសហេតុ (lésion)។ ប៉ុន្តែមានការលំបាកក្នុងការនិយាយថា ជានិច្ចកាល ការទទួលបានចំណេញយ៉ាងច្រើនពីកិច្ចសន្យាដោយភាគីមួយ គឺជាសកម្មភាពមិនត្រឹមត្រូវ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីបារាំង បានកម្រិតការហាមឃាត់នៃការកេងចំណេញហួសហេតុ (lésion) ចំពោះករណីដែលភាគីម្ខាងទៀតជាអនីតិជន ជាអាទិ៍ តែប៉ុណ្ណោះ។

## ២.៧ បឋមនីយផ្លូវចិត្ត

បឋមនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈផ្ទុយពីឆន្ទៈពិតប្រាកដរបស់ខ្លួន ដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ។ ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។[35]

### ២.៧.១ ល័ក្ខខ័ណ្ឌនៃបឋមនីយផ្លូវចិត្ត

ល័ក្ខខ័ណ្ឌបឋមនីយផ្លូវចិត្តមានដូចខាងក្រោម៖

- អ្នកបង្ហាញឆន្ទៈមានបឋមនីយផ្លូវចិត្ត
- ភាគីម្ខាងទៀត បានដឹងថាការបង្ហាញឆន្ទៈមានបឋមនីយផ្លូវចិត្ត

#### ២.៧.១.១ អ្នកបង្ហាញឆន្ទៈមានបឋមនីយផ្លូវចិត្ត

ការបង្ហាញឆន្ទៈដោយបឋមនីយផ្លូវចិត្ត គឺជាការក្រែងចិត្ត ការបារម្ភ ការសម្រេចចិត្តដោយស្មុគស្មាញដែលខុសពីឆន្ទៈពិតនាំឱ្យមានផលអវិជ្ជមានគូភាគីទាំងសងខាង ចំពោះអ្នកបង្ហាញឆន្ទៈដោយបឋមនីយផ្លូវចិត្តដែលពុំអាចសម្តែងចេញឱ្យភាគីម្ខាងទៀងដឹងបានទេនោះ គឺការបង្កើតកិច្ចសន្យាអាចអនុវត្តបានដោយសុពល ។

ឧទាហរណ៍៖ A បង្ហាញឆន្ទៈ ធ្វើប្រទានកម្មឲ្យទៅ B ទោះបីជា A គ្មានបំណងធ្វើបែបនេះក៏ដោយ ការបង្ហាញឆន្ទៈដែលមិនពិតគឺជា ការបង្ហាញឆន្ទៈដែលមាននិការៈ ហើយតាមគោលការណ៍នៃកិច្ចសន្យាដែលមានការ

[35] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥២

បង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលបាន ។ A ហាក់ដូចជាត្រូវបានអនុញ្ញាតឲ្យលុបចោលកិច្ចសន្យាប្រទានកម្ម ប៉ុន្តែ ការអនុញ្ញាតឲ្យលុបចោលក្នុងករណីនេះ ធ្វើឲ្យខូចប្រយោជន៍របស់ B យ៉ាងខ្លាំង ប្រសិនបើ B មិនដឹងថា ការបង្ហាញឆន្ទៈរបស់ A មិនមែនជាពិត ។ បន្ថែមពីនេះ ដោយសារ A បង្ហាញឆន្ទៈមិនពិត ប្រសិនបើ B មិនដឹងអំពីឋបនីយផ្លូវចិត្តនោះទេ ហេតុដូច្នេះ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយឋបនីយផ្លូវចិត្ត មានសុពលភាព។

#### ២.៧.១.២. ភាគីម្ខាងទៀតបានដឹងថាការបង្ហាញឆន្ទៈមានឋបនីយផ្លូវចិត្ត

ប្រសិនបើភាគីម្ខាងទៀតដឹងអំពីឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន។ ករណីនេះមិនមែនមានន័យថា ការបដិសេធនូវអានុភាពនៃកិច្ចសន្យាទេ។ ហេតុដូច្នេះហើយ ទោះបីជាភាគីម្ខាងទៀត B មិនអាចទាមទារការអនុវត្តកិច្ចសន្យាចំពោះ A ក៏ដោយ ក៏អ្នកធ្វើលទ្ធកម្មបន្ត C អាចធ្វើលទ្ធកម្មនូវសិទ្ធិរបស់ B ដោយមានសុពលភាពបាន ហើយ A មិនអាចអះអាងអ្វីចំពោះ C បានទេ។

## ២.៨ ការបង្ហាញឆន្ទៈមិនពិត

ការបង្ហាញឆន្ទៈមិនពិត គឺជាការបង្ហាញឆន្ទៈដោយការក្លែងបន្លំ ដោយការធ្វើពុត ជាការសម្តែង បំភាន់ភ្នែកអ្នកដទៃ បង្កើតនូវទំនាក់ទំនងគតិយុត្តិក្លែងក្លាយ ដែលមិនកើតចេញពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈឡើយ។ កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ។[36]

### ២.៨.១ លក្ខខណ្ឌនៃការបង្ហាញឆន្ទៈមិនពិត

លក្ខខណ្ឌនៃការបង្ហាញឆន្ទៈមិនពិត ដែលឆ្ពោះទៅមោឃៈមានដូចជា៖

- ភាគីសុទ្ធតែបង្ហាញឆន្ទៈខុសពីឆន្ទៈពិតរបស់ខ្លួន
- ភាគីបានឃុបឃិតគ្នា

[36] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៣

### ២.៨.១.១ អ្នកបង្ហាញឆន្ទៈមិនបង្ហាញឆន្ទៈពិតប្រាកដ

ប្រព័ន្ធក្រមរដ្ឋប្បវេណីអាល្លឺម៉ង់យកគោលការណ៍ថា ការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកជាមោឃៈ ពីព្រោះឆន្ទៈពិត មិនត្រូវបានបង្ហាញចេញ ។ ផ្ទុយទៅវិញ ប្រព័ន្ធក្រមរដ្ឋប្បវេណីបារាំងមិនចាត់ទុកការបង្ហាញឆន្ទៈនោះជាមោឃៈ ឬ មានវិការៈដោយស្វ័យប្រវត្តិទេ ប៉ុន្តែ ចាត់ទុកវាថាជាការផ្ទុយគ្នារវាង កិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាព និង ឆន្ទៈពិតដែលត្រូវបានលាក់បាំង វិញ។ ចំពោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ វិញ គឺយកតាមគោលការណ៍នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ គ្រប់កិច្ចសន្យាដែលផ្ទុយពីឆន្ទៈភាគី ក្នុង

គោលបំណងទុច្ចរិត មិនស្មោះត្រង់ ជាការរៀបចំសម្តែងណាមួយនោះ នាំឱ្យមានវិការៈដែលឈានទៅមោឃៈភាពនៃកិច្ចសន្យា ។

### ២.៨.១.២ ការបង្ហាញឆន្ទៈដោយឃុបឃិត

ផ្អែកតាមក្រមរដ្ឋប្បវេណីបារាំង ការបង្ហាញឆន្ទៈមិនពិត ត្រូវបានដោះស្រាយតាម ឆន្ទៈពិតដែលត្រូវបានលាក់បាំង រវាងគូភាគីហើយក្នុងទំនាក់ទំនងជាមួយតតិយជន តតិយជនអាចអះអាងអំពីគោលគំនិតណាមួយដែលមានផលប្រយោជន៍ច្រើនជាងចំពោះខ្លួន ក្នុងចំណោមការគិតទាំងពីរ។

ឧទាហរណ៍៖ A បានធ្វើកិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាព ជាមួយមិត្តភក្តិ B អំពីអនុប្បទានទ្រព្យសម្បត្តិរបស់ A ដើម្បីជៀសវាងពីការរឹបអូស របស់ម្ចាស់បំណុល Y ប៉ុន្តែ ឆន្ទៈពិតដែលត្រូវបានលាក់បាំង មិនមែនជាការផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិទេ តែគឺជាអាណត្តិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិនោះ។ ក្នុងករណីនេះរវាង A និង B កម្មសិទ្ធិមិនត្រូវបានផ្ទេរទ ហើយគ្រាន់តែទំនាក់ទំនងគតិយុត្តនៃអាណត្តិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិកើតឡើងប៉ុណ្ណោះ។ ដូច្នេះតតិយជនជាម្ចាស់បំណុល Y អាចរឹបអូសទ្រព្យសម្បត្តិបាន ដោយអះអាងអំពី ឆន្ទៈពិតដែលត្រូវបានលាក់បាំង ។ ប៉ុន្តែ មានតតិយជនប្រភេទផ្សេងទៀត។ ឧទាហរណ៍៖ ប្រសិនបើតតិយជន X បានទិញទ្រព្យសម្បត្តិពី B ដោយជឿជាក់ថា ទ្រព្យសម្បត្តិនោះជាកម្មសិទ្ធិរបស់ B នោះតតិយ X ទំនងជាអះអាងអំពី កិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាពនេះ។ ផ្អែកតាមក្រមរដ្ឋប្បវេណីបារាំង មានបញ្ហាលំបាកមួយដែលកើតឡើង ពីព្រោះប្រសិនបើមានតតិយជន ពីរ ឬ ច្រើន ពួកគេមានផលប្រយោជន៍ខុសៗគ្នា។ ហេតុនេះហើយបានជាប្រទេសខ្លះ ក្នុងចំណោមប្រទេសដែលប្រើប្រាស់ប្រព័ន្ធច្បាប់បារាំង ឱ្យអាទិភាពលើ កិច្ចព្រមព្រៀង

មានលក្ខណៈជារូបភាព នៅពេលដែលមានទំនាស់ផលប្រយោជន៍របស់តតិយជន (មាត្រា ១៤៥២ នៃក្រមរដ្ឋប្បវេណីកេបិច)។ ដោយពិចារណាលើភាពប្រឆាំងគ្នានៃច្បាប់ដូចបានរៀបរាប់ខាងលើនេះ ច្បាប់បានយកជំហរមួយថា កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកជាមោឃៈ។[37]

[37] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, គន្ថីទី៤, រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, មាត្រា ៣៥៣

# ជំពូកទី៣

# ការលុបចោល និង មោឃៈភាពនៃកិច្ចសន្យា

# ជំពូកទី៣

# ការលុបចោល និង មោឃៈភាពនៃកិច្ចសន្យា

## ផ្នែកទី១ ៖ ការលុបចោល

ការលុបចោល គឺសិទ្ធិពិសេសមួយដែលកំណត់ដោយច្បាប់ ក្នុងការការពារដល់ភាគីម្ខាងទៀតដែលបានបង្ហាញឆន្ទៈដោយមានវិការៈ ឬចំពោះកិច្ចសន្យាដែលបានធ្វើឡើងដោយអសមត្ថជន ដែលនាំឱ្យមានការខាតបង់នូវផលប្រយោជន៍ដល់ភាគី ឬអសមត្ថជននោះ ។ កិច្ចសន្យា ដែលរងនូវការលុបចោល គឺច្បាស់ណាស់ប៉ះពាល់ត្រឹមតែផលប្រយោជន៍របស់បុគ្គលឯកជនដែលជាភាគីតែប៉ុណ្ណោះ ហើយការលុបចោលនូវកិច្ចសន្យាតម្រូវឱ្យអ្នកមានសិទ្ធិលុបចោល អនុវត្តសិទ្ធិលុបចោលនោះ ទើបកិច្ចសន្យាអសុពលភាព ។

### ១.១ មូលហេតុនៃការលុបចោល

ក្នុងកិច្ចសន្យាដែលជាមូលហេតុនៃការលុបចោល មានមូលហេតុ ចំនួន ០៣ (បី) គឺដោយមូលហេតុខ្វះសមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និង បញ្ញត្តិដោយច្បាប់ ។ នៅក្នុងករណីភាគីម្ខាងនៃកិច្ចសន្យាបានបង្ហាញឆន្ទៈដោយមានវិការៈ ឬដោយមូលហេតុនៃសមត្ថភាពក្នុងការយល់ដឹងរបស់ខ្លួន ឬដោយអំពើទុច្ចរិតរបស់ភាគីម្ខាងទៀត ដែលបានធ្វើឱ្យខាតបង់នូវផលប្រយោជន៍របស់ភាគីនោះ។[38]

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិដល់ភាគីម្ខាងទៀតដែលបានខូចខាតនូវផលប្រយោជន៍ពីការចុះកិច្ចសន្យាដោយមានវិការៈ ឬកិច្ចសន្យាដែលបានធ្វើឡើងដោយអសមត្ថជនអាចធ្វើការលុបចោលកិច្ចសន្យានោះវិញបាន។

តាមន័យនេះ មានន័យថាកិច្ចសន្យាមិនអាចមានអានុភាពឡើយប្រសិនបើ ត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ឬកិច្ចសន្យាដែលនាំឱ្យមានការខាតបង់នូវផលប្រយោជន៍របស់ភាគីណាមួយ ហើយភាគីនោះ ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធអាចអនុវត្តសិទ្ធិលុបចោលនូវកិច្ចសន្យានោះបាន។

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ហើយក្រោយពេលលុបចោល សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពី

[38] កម្រងឯកសារកិច្ចសន្យាវិភាគទានច្បាប់ សិស្សជំនាន់ទី ៧

ដំបូង ក៏ប៉ុន្តែការលុបចោលត្រូវធ្វើឡើងតាមវិធីនៃការជូនដំណឹងទៅភាគីម្ខាងទៀត ហើយនឹងមានអានុភាពគិតចាប់ពីពេលដែលដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត។

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មូលហេតុនៃការលុបចោលកិច្ចសន្យា មាន ០២ (ពីរ)ល័ក្ខខ័ណ្ឌគឺ (១) ក្នុងករណីដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយអសមត្ថជន (ជនដែលគ្មានសមត្ថ--ភាពខាងឆន្ទៈ ឬខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព) និង (២) ក្នុងករណីដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានវិការៈក្នុងការបង្ហាញឆន្ទៈ។

### ១.១.១ ជនខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និង វិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន។ ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ សំដៅទៅលើបុគ្គលដែលបានធ្វើសកម្មភាពក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ របបស្តីពីសមត្ថភាពខាងឆន្ទៈ និង របបកម្រិតសមត្ថភាពក្នុងការធ្វើសម្មភាព គឺសម្រាប់ការពារកុំឲ្យមានការខូចខាតដោយកិច្ចការជួយជូររបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ។ បើទោះបីជាមិនមែនជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ពិតមែន ប៉ុន្តែក៏អាចលុបចោលបាននូវសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង ក្នុងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ [39]

ឧទាហរណ៍៖ លោក ក បានដាក់ថ្នាំញៀនឲ្យ លោក ខ ធ្វើឲ្យលោក ខ បាត់បង់ស្មារតី ហើយព្យាយាមឲ្យលោក ខ ចុះហត្ថលេខាលើកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដែលមានខ្លឹមសារ ជាអចលនវត្ថុ ដីមួយកន្លែងដែលជាកម្មសិទ្ធិរបស់ លោក ខ ដើម្បីធានាកាតព្វកិច្ចរបស់ លោក ក ចំពោះលោក គ។ ពេលដឹងខ្លួនឡើងវិញ លោក ខ បានឃើញកិច្ចសន្យានោះ ហើយគិតថាដូចជាមិនដឹងអំពីការណ៍នោះទេ(មិនបានចុះកិច្ចសន្យា)។ ផ្អែកតាមមាត្រា ១៤ នៃក្រមរដ្ឋប្បវេណី សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន។

[39] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៤

ក្នុងករណីនេះ បានធ្វើការសន្មត់ថា លោក ខ ពិតជាត្រូវថ្នាំញៀន ហើយសារធាតុញៀននោះ បានបណ្តាលឲ្យលោក ខ បាត់បង់ស្មារតី ហើយមិនដឹងថា ខ្លួនបានចុះកិច្ចសន្យានោះទេ នាំឲ្យកិច្ចសន្យាបង្កើតហើប៉ុន្តែកនោះ មានមូលហេតុនៃការលុបចោល ហេតុនេះ លោក ខ អាចលុបចោលកិច្ចសន្យាបាន។

## ១.១.២ ជនខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព

ជាទូទៅមនុស្សគ្រប់រូបត្រូវបានទទួលស្គាល់យ៉ាងពេញលេញអំពីសិទ្ធិរបស់ខ្លួន ដែលពួកគេអាចប្រើប្រាស់សិទ្ធិនេះ ក្នុងការធ្វើសកម្មភាពផ្សេងៗបានដោយសេរី កុំឱ្យតែប៉ះពាល់ ដល់សិទ្ធិអ្នកដ៏ទៃ និងផ្ទុយនឹងបញ្ញត្តិច្បាប់ ។ ក៏ប៉ុន្តែសកម្មភាពដែលបានធ្វើឡើង មានសកម្មភាពមួយចំនួនត្រូវបានច្បាប់ទទួលស្គាល់ និងមានសុពលភាពពេញលេញ ហើយសកម្មភាពដែលបានធ្វើឡើងដោយជនមួយចំនួនទៀតត្រូវបាន ច្បាប់មិនទទួលស្គាល់ថាមានសុពលភាព ឬតម្រូវឱ្យមានការយល់ព្រមដោយជនដែលមានផលប្រយោជន៍ផ្សេងទៀតដើម្បីឱ្យមានសុពលភាពលើសកម្មភាពទាំងនោះជាអាទិ៍ ។

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព សំដៅដល់រូបវន្តបុគ្គលទាំងឡាយណាដែលខ្វះសមត្ថភាពក្នុងការយល់ដឹងនិងវិនិច្ឆ័យពី សកម្មភាពតាមផ្លូវច្បាប់របស់ខ្លួនបាន ដោយមូលហេតុ អាយុ សតិ និងបញ្ញាស្មារតី របស់ជននោះ ។ ហើយបានកំណត់យកជនដែលត្រូវបានកម្រិតសមត្ថភាពមានចំនួន ០៣ (បី)ប្រភេទ គឺ អនីតិជន, ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ ។ ពាក្យថាសកម្មភាពនេះផងដែរ គឺសំដៅការបង្ហាញឆន្ទៈ ជាឯកតោភាគី ឬតាមរយៈកិច្ចសន្យា ។

### ១.១.២.១ អនីតិជន

អនីតិជនសំដៅដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[40] ប៉ុន្តែមិនមែនអនីតិជនគ្រប់រូបសុទ្ធតែត្រូវបានកម្រិតសមត្ថភាពនោះទេ ដូចជាអនីតិជនដែលទទួលបានអត្តាធិនភាព គឺមិនត្រូវមានការកម្រិតសមត្ថភាព

[40] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៧

ឡើយ និងត្រូវចាត់ទុកថាបានដល់នីតិភាព ។[41] អ្នកដែលមានអំណាចមេបា (ឪពុក ឬម្ដាយ) មានសិទ្ធិ និងករណីយកិច្ចបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន ។ តែបើក្នុងករណីអនីតិជនគ្មានឪពុក ឬម្ដាយ នោះទេគេត្រូវបង្កើត របបអាណាព្យាបាល សម្រាប់អនីតិជន ដើម្បីជ្រើសតាំងបុគ្គលណាម្នាក់សម្រាប់គ្រប់គ្រងអនីតិជន ដែលមានសិទ្ធិ និងករណីយកិច្ចដូចអ្នកមានអំណាចមេបាដែរ ។

ជាគោលការណ៍សកម្មភាពដែលអនីតិជនបានធ្វើ ដោយគ្មានការយល់ព្រមពីឪពុកម្ដាយ សកម្មភាពនោះនឹងត្រូវបានលុបចោលដោយ ឪពុកម្ដាយរបស់អនីតិជន ។[42] ប៉ុន្តែសកម្មភាពខ្លះគឺ មិនអាចលុបចោលបានទេដូចជា ការទទួលយកប្រទានកម្ម, ការចុះកិច្ចសន្យាដោយរួចផុតពីកាតព្វកិច្ច, ការទិញលក់របស់ប្រើប្រាស់ប្រចាំថ្ងៃ, ការចាត់ចែងទ្រព្យសម្បត្តិដោយមានការអនុញ្ញាតពីឪពុកម្ដាយ, ការប្រកបអាជីវកម្មត្រឹមការអនុញ្ញាតរបស់ឪពុកម្ដាយ ។[43]

### ១.១.២.២ ជនស្ថិតក្រោមអាណាព្យាបាលទូទៅ

ចំពោះបុគ្គលដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ហើយខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យជាអចិន្ត្រៃយ៍ ដោយខ្លួនមានបញ្ហាស្មារតី តុលាការអាចប្រកាសចាប់ផ្ដើមរបបអាណាព្យាបាលទូទៅ តាមរយៈពាក្យសុំរបស់សាមីខ្លួន, សហព័ទ្ធ, ញាតិដែលស្ថិតក្នុង ៤ ថ្នាក់, អ្នកអាណាព្យាបាលសម្រាប់អនីតិជន, អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន, ហិតូបត្ថម្ភកៈ, មេឃុំ ឬចៅសង្កាត់, ឬតំណាងអយ្យការ ។ មុនពេលប្រកាសរបបនេះ តុលាការត្រូវស្ដាប់មតិយោបល់របស់វេជ្ជបណ្ឌិត និងផ្ដល់ឱកាសឲ្យសាមីខ្លួនធ្វើសេចក្ដីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួន ពិតជាមានបញ្ហាផ្នែកស្មារតីពិតប្រាកដមែន ។[44]

អ្នកអាណាព្យាបាលទូទៅ ជាអ្នកគ្រប់គ្រងត្រួតពិនិត្យលើជននៅក្រោមអាណាព្យាបាលទូទៅ ហើយតុលាការជ្រើសតាំងអ្នកអាណាព្យាបាលដោយឆន្ទានុសិទ្ធិ និងត្រូវធ្វើឡើងតាមរយៈការទាមទាររបស់ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ, ជនក្រោមអាណាព្យាបាលទូទៅ, សហព័ទ្ធ, ញាតិនៅក្នុង ៤ ថ្នាក់, មេឃុំ, ចៅសង្កាត់, តំណាងអយ្យការ ឬបុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍។

[41] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២២

[42] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៨

[43] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០

[44] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៤

ជាគោលការណ៍សកម្មភាពរបស់ជនក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន លើកលែងតែសកម្មភាពនោះជាសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាការទិញបាយម្ហូប របស់ប្រើប្រាស់ប្រចាំថ្ងៃជាដើម ។[45]

### ១.១.២.៣ ជនស្ថិតក្រោមហិតូបត្ថម្ភ

ចំពោះបុគ្គលដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារបញ្ហាស្មារតី តុលាការអាចប្រកាសចាប់ផ្ដើមហិតូបត្ថម្ភតាមរយៈពាក្យសុំរបស់សាមីខ្លួន, សហព័ទ្ធ, ញាតិដែលស្ថិតក្នុង ៤ ថ្នាក់, អ្នកអាណាព្យាបាល, អ្នកត្រួតពិនិត្យអាណាព្យាបាលទូទៅ, មេឃុំ ឬចៅសង្កាត់ ឬតំណាងអយ្យការ ។ មុនពេលប្រកាសរបបនេះ តុលាការត្រូវស្ដាប់ មតិយោបល់របស់វេជ្ជបណ្ឌិត និងផ្ដល់ឱកាសឲ្យសាមីខ្លួនធ្វើសេចក្ដីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួន ពិតជាមានបញ្ហាផ្នែកស្មារតី និងមានការយល់ដឹងតិចតួចពិតប្រាកដមែន ។[46]

ហិតូបត្ថម្ភកៈ ជាអ្នកមានតួនាទីត្រួតពិនិត្យ និងថែរក្សាជនស្ថិតក្រោមហិតូបត្ថម្ភ។ តុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈដោយឆន្ទានុសិទ្ធិ ចំណែកឯនីតិវិធីនៃការជ្រើសតាំង ហិតូបត្ថម្ភកៈត្រូវអនុវត្តដូចការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ។

ជាគោលការណ៍ សកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ ដែលមិនបានការយល់ព្រមពីហិតូបត្ថម្ភកៈ ត្រូវមានការលុបចោល លុះត្រាតែសកម្មភាពនោះជាសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ។ ប៉ុន្តែក្នុងករណីមានការយល់ព្រមពី ហិតូបត្ថម្ភកៈ សាមីខ្លួនអាចធ្វើសកម្មភាពដូចជាៈ ការទទួល ឬការប្រើប្រាស់ទុន, ការខ្ចីទ្រព្យ ឬការធានា, ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឲ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត, ការធ្វើសកម្មភាពបណ្ដឹង, ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម, ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសន្តតិកម្ម ឬការបែងចែកមត៌ក, ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់បន្ទុក, ការសាងសង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ, ការធ្វើភតិសន្យា ដែលមាន

[45] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៦

[46] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៨

អំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លីលើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែចំពោះអចលនវត្ថុ និងសកម្មភាពដែលតុលាការប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហាគូបត្ថម្ភកៈ ។[47]

### ១.១.៣ ការលុបចោលដោយមូលហេតុវិការៈនៃកិច្ចសន្យា

មូលហេតុនៃការលុបចោលកិច្ចសន្យា៖

ការលុបចោលកិច្ចសន្យាដោយមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈនៅក្នុងករណីដែលកិច្ចសន្យាត្រូវបានធ្វើឡើងដោយការបង្ហាញឆន្ទៈមានវិការៈ ភាគីនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យានោះបាន។ វិការៈនៃការបង្ហាញឆន្ទៈមានដូចជា ក្នុងករណីដែលការចុះកិច្ចសន្យាដោយការ ភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភលើស្ថានភាព ការគម្រាមកំហែង និងមូលហេតុនៃអំពើកេងចំណេញហួសហេតុ ។ [48]

## ១.២ អ្នកមានសិទ្ធិ និង វិធីលុបចោល

### ១.២.១ អ្នកមានសិទ្ធិ

អ្នកមានសិទ្ធិលុបចោល ត្រូវធ្វើឡើងដោយភាគីដែលបានបង្ហាញឆន្ទៈដែលមានវិការៈនោះ និង អ្នកមានសិទ្ធិលុបចោលក្នុងករណីខ្វះសមត្ថភាព ( សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព ) ។

ក. ករណីវិការៈនៃការបង្ហាញឆន្ទៈ

អ្នកមានសិទ្ធិលុបចោលក្នុងករណីវិការៈក្នុងការបង្ហាញឆន្ទៈមានដូចជា៖ ទី១ (មួយ) អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ទី២ (ពីរ) អ្នកតំណាងដែលច្បាប់បានកំណត់ ឬហិតូបត្ថម្ភកៈរបស់អ្នកដែលបានបង្ហាញឆន្ទៈដោយមានវិការៈ ទី៣ (បី) សន្តតិជន ឬអច្ច័យលាភីសកលរបស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ទី៤ (បួន) អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ។

[47] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣០

[48] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៩ កថាខណ្ឌទី១

ខ. ករណីខ្វះសមត្ថភាព

អ្នកមានសិទ្ធិលុបចោលក្នុងករណីខ្វះសមត្ថភាពមានដូចជា៖ ទី១ (មួយ) អ្នកដែលខ្វះសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ទី២ (ពីរ) អ្នកតំណាងដែលច្បាប់បានកំណត់ ឬហិតូបត្ថម្ភកៈរបស់អ្នកដែលខ្វះសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ទី៣ (បី) សន្តតិជន ឬអច្ច័យលាភីសកលរបស់អ្នកដែលខ្វះសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ទី៤ (បួន) អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលខ្វះសមត្ថភាពក្នុងការបង្ហាញឆន្ទៈ។[49]

## ១.២.២ វិធីលុបចោល

អ្នកដែលមានសិទ្ធិលុបចោល អាចបង្ហាញឆន្ទៈលុបចោលដោយការជូនដំណឹងទៅភាគីម្ខាងទៀត ហើយអានុភាពនៃការលុបចោល ត្រូវកើតឡើងនៅពេលដែលដំណឹងនោះ បានទៅដល់ភាគីម្ខាងទៀត ( មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណី )។ វិធីនៃការជូនដំណឹង ត្រូវធ្វើឡើងតាមការបង្ហាញឆន្ទៈទៅកាន់ភាគីម្ខាងទៀត តាមមាត្រា ៣១០ នៃក្រមរដ្ឋប្បវេណី។ ការបង្ហាញឆន្ទៈ មានអានុភាពភ្លាម ក្នុងករណីដដែលការបង្ហាញឆន្ទៈត្រូវបានធ្វើដោយផ្ទាល់ខ្លួន នៅចំពោះមុខភាគីម្ខាងទៀត ឬ តាមរយៈសារអេឡិចត្រូនិច ជាដើម។ ក្នុងករណីដែលការបង្ហាញឆន្ទៈ ធ្វើឡើងតាមរយៈលិខិតដែលផ្ញើតាមប្រៃសណីយ៍ ក្នុងករណីនេះការបង្ហាញឆន្ទៈនោះ ត្រូវមានអានុភាព នៅពេលបានទៅដល់ភាគីម្ខាងទៀត។ វិធីនៃការជូនដំណឹងត្រូវបានកំណត់នៅក្នុងមាត្រា ៣១០ សំដៅលើកាបង្ហាញឆន្ទៈបានទៅដល់ភាគីម្ខាងទៀត។ ពាក្យថា បានទៅដល់ មានន័យថា ការជូនដំណឹងនោះបានទៅដល់តំបន់ត្រួតត្រារបស់ភាគីម្ខាងទៀត ដែលសំដៅទៅលើដែនសមត្ថកិច្ចរបស់អ្នកទទួលដំណឹង មិនមែនជាការបានទទួល ឬបានដឹងនោះទេ។ ចំពោះវិធីនៃការជូនដំណឹង មិនត្រូវបានកម្រិតថា ត្រូវធ្វើតាមទម្រង់ណាមួយនោះទេ ហេតុនេះ ឲ្យតែបានជូនដំណឹង ទោះជាកាជូនដំណឹងដោយផ្ទាល់មាត់ក៏ដោយ ក៏មានអានុភាពដែរ។

[49] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៩ កថាខណ្ឌទី២

## ១.៣ ការផ្តល់សច្ចានុមតិ

### ១.៣.១ អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ

អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន។ អ្នកមានសិទ្ធិលុបចោល ជាបុគ្គលដែលអាចផ្តល់សច្ចានុមតិបាន។ ចំពោះសកម្មភាពដែលបានធ្វើដោយជនដែលត្រូវ

បានកម្រិតសមត្ថភាព អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោល ត្រូវបានរលត់។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល។ [50]

ឧទាហរណ៍៖ X បានចុះកិច្ចសន្យាជាមួយ Y ដោយមានការភាន់ច្រឡំលើកម្មវត្ថុនៃកិច្ចសន្យា ( ចង់ទិញកាបូបម៉ាក A ប៉ុន្តែបែរជាទិញម៉ាក B ដែលមានភាពស្រដៀងគ្នាទៅវិញ ) ប៉ុន្តែក្រោយពេលប្រើប្រាស់ X ពេញចិត្តនឹងគុណភាពកាបូបម៉ាក B ហើយមិនចង់លុបចោលកិច្ចសន្យាលក់ទិញរវាង Y នោះទេ។

ក្នុងករណីកិច្ចសន្យាអាចលុបចោលដោយមូលហេតុវិការៈក្នុងការបង្ហាញឆន្ទៈ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិលើកិច្ចសន្យាបាន ដោយធ្វើការជូនដំណឹងទៅភាគីម្ខាងទៀត គិតចាប់ពីពេលដែលបានដឹងអំពីមូលហេតុនៃការលុបចោល ហើយអានុភាពនៃការផ្តល់សច្ចានុមតិ នាំឲ្យសកម្មភាពដែលអាចលុបចោលបានមានសុពលភាព។

### ១.៣.២ សច្ចានុមតិដែលកំណត់ដោយច្បាប់

អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន ឬបានធ្វើនូវសកម្មភាពដែលត្រូវបានចាត់ទុកថា ផ្តល់សច្ចានុមតិតាមច្បាប់កំណត់។ សច្ចានុមតិដែលបានកំណត់ដោយច្បាប់ រួមមាន ៖

ទី១ (មួយ) ការអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ

[50] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៦១

ទី២ (ពីរ) ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត

ទី៣ (បី) អនុប្បទាន ឬការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬមួយផ្នែកចំពោះសិទ្ធិដែលទទួលពីសកម្មភាពដែលអាចលុបចោលបាន ។ [51]

ឧទាហរណ៍៖ X បានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូម៉ាក A ជាមួយ Y ក្នុងតម្លៃ 500$ នៅថ្ងៃទី 01.01.2018 បន្ទាប់មកនៅថ្ងៃទី01.03.2018 X បានដឹងថា ខ្លួនបានចាញ់បោក Y ប៉ុន្តែ មិនបានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាទេ ហើយបានបង់ប្រាក់ថ្លៃលក់ទិញឲ្យ Y ។

សកម្មភាពនៃការបង់ប្រាក់ថ្លៃលក់ទិញ ជាការអនុវត្តកាតព្វកិច្ច ដែលកើតឡើងដោយសារកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល ហើយត្រូវបានធ្វើនៅក្រោយពេលដែលអ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិបាន ហេតុនេះត្រូវនឹងលក្ខខណ្ឌនៃមាត្រា ៣៦២ ចំណុច ក នាំឲ្យ ត្រូវបានចាត់ទុកថា ជាការផ្តល់សច្ចានុមតិដែលកំណត់ដោយច្បាប់។

## ១.៤ អានុភាពនៃការលុបចោល

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលមានអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ប៉ុន្តែនៅពេលដែលអ្នកមានសិទ្ធិលុបចោល បានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា នាំឲ្យសកម្មភាពនោះ ត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង នាំឲ្យភាគីមិនមានសិទ្ធិ និងករណីកិច្ចចំពោះគ្នានោះទេ។ ក្នុងករណីដែលមានភាគីម្ខាង បានទទួលតាវកាលិកពីកិច្ចសន្យាដែលត្រូវបានលុបចោល អាចទាមទារឲ្យអ្នកទទួលផ្តល់តាវកាលិកនោះមកវិញបាន ផ្អែកតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ( មាត្រា ៧៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ) ឬផ្អែកតាមបញ្ញត្តិស្តីពីកម្មសិទ្ធិ ( មាត្រា ១៩៥ នៃក្រមរដ្ឋប្បវេណី )។

ឧទាហរណ៍៖ X ( អនីតិជន ) បានចុះកិច្ចសន្យាលក់ទិញម៉ូតូម៉ាក A ជាមួយ Y ក្នុងតម្លៃ ១០០០$។ Y បានប្រគល់ម៉ូតូរួចហើយប៉ុន្តែ X មិនទាន់បង់ប្រាក់នោះទេ ស្រាប់តែ C ដែលជាឪពុករបស់ X បានលុបចោលកិច្ចសន្យាលក់ទិញនេះ។

[51] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៦២

ក្នុងករណីខាងលើ C បានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាលក់ទិញរវាង X និង Y នាំឲ្យ កិច្ចសន្យានោះក្លាយជាមោឃៈតាំងពីដំបូង ( គ្មានកិច្ចសន្យា ) ហេតុនេះ Y មិនអាចទាមទារឲ្យ X អនុវត្តកិច្ចសន្យានោះបានទេ។ ក៏ប៉ុន្តែ ដោយសារ Y បានប្រគល់ម៉ូតូឲ្យទៅ X រួចហើយ នាំឲ្យការណ៍ដែល X បានទទួលម៉ូតូ ក្លាយជាសេចក្តីចម្រើនដោយឥតហេតុ ព្រោះ X គ្មានមូលហេតុផ្លូវច្បាប់ក្នុងការទទួលម៉ូតូនោះទេ ហេតុនេះ Y អាចទាមទារឲ្យ X ប្រគល់ម៉ូតូមកវិញបាន។ ក្រៅពីនេះ Y ក៏អាចទាមទារឲ្យ X ប្រគល់ម៉ូតូមកវិញដោយផ្អែកលើកម្មសិទ្ធិផងដែរ។

### ១.៤.១ អាជ្ញាយុកាលនៃការលុបចោល

សិទ្ធិលុបចោល ត្រូវអនុវត្តក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនបានអនុវត្តក្នុងអំឡុងពេលនោះទេ សិទ្ធិលុបចោលនឹងត្រូវរលត់ ហើយសកម្មភាពដែលអាចលុបចោលបាន នឹងក្លាយជសកម្មភាពដែលមានសុពលភាពជាស្ថាពរ។ [52]

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ត្រូវបានកំណត់នៅក្នុងមាត្រា ៣៦៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី គឺ ៖

ទី១ (មួយ) អំឡុងពេល ៣ ឆ្នាំ គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ឬ

ទី២ (ពីរ) អំឡុងពេល ១០ ឆ្នាំ គិតចាប់ពីពេលដែលបានបង្កើតសកម្មភាពដែលអាចលុបចោលបាន

ឧទាហរណ៍៖ នៅថ្ងៃទី 01.01.2023 X និង Y បានចុះកិច្ចសន្យាលក់ទិញរថយន្តក្នុងតម្លៃ 10000$ ដោយមានការភាន់ច្រឡំ។ X បានដឹងពីការភាន់ច្រឡំនៅថ្ងៃទី 01.11.2024 ហើយបានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យានៅថ្ងៃទី 01.01.2025។

ផ្អែកតាមឧទាហរណ៍ខាងលើ គិតចាប់ពីពេលដែល X បានដឹងអំពីមូលហេតុនៃការលុបចោលថ្ងៃទី 01.11.2024 រហូតដល់ថ្ងៃទី 01.01.2025 មានអំឡុងពេល 2 ខែ នាំឲ្យអាជ្ញាយុកាលនៃការអះអាងសិទ្ធិលុបចោលមិនទាន់បានរលត់នោះទេ ហេតុនេះ X អាចលុបចោលកិច្ចសន្យាបាន។

[52] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៦៣

ឧទាហរណ៍៖ នៅថ្ងៃទី01.01.2023 X និង Y បានចុះកិច្ចសន្យាលក់ទិញរថយន្តក្នុងតម្លៃ 10000$ ដោយមានការភាន់ច្រឡំ។ X បានដឹងពីការភាន់ច្រឡំនៅថ្ងៃទី01.11.2032 ហើយបានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យានៅថ្ងៃទី01.11.2034។

ផ្អែកតាមឧទាហរណ៍ខាងលើ គិតចាប់ពីពេលដែល X បានដឹងអំពីមូលហេតុនៃការលុបចោលថ្ងៃទី 01.11.2032 រហូតដល់ថ្ងៃទី01.11.2034 មានអំឡុងពេល 2 ឆ្នាំ ដែលស្ថិតនៅក្នុងអំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលបាន ប៉ុន្តែប្រសិនបើគិតចាប់ពីថ្ងៃចុះកិច្ចសន្យា ( 01.01.2023 ) មកដល់ថ្ងៃបង្ហាញឆន្ទៈលុបចោល គឺមានអំឡុងពេល 10 ឆ្នាំ 10 ខែ នាំឲ្យសិទ្ធិលុបចោល ត្រូវបានរលត់ដោយអាជ្ញាយុកាល ហេតុនេះ X មិនអាចលុបចោលកិច្ចសន្យានេះបានទេ។

នៅក្រោយពេលលុបចោល អ្នកដែលមានសិទ្ធិលុបចោល អាចទាមទារឲ្យសងតាមរយៈសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើងដោយសារការលុបចោលបាន ហើយសិទ្ធិនេះ ត្រូវអនុវត្តក្នុងអំឡុងពេល 3 ឆ្នាំ គិតចាប់ពីថ្ងៃដែលអ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន។ អ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យា អាចទាមទារតាមរយៈសេចក្តីចម្រើនដោយឥតហេតុ ផ្អែកតាមការលុបចោលកិច្ចសន្យាបាន ក្នុងអំឡុងពេល 3 ឆ្នាំ គិតចាប់ថ្ងៃដែលអាចផ្តល់សច្ចានុមតិបាន ហើយប្រសិនបើមិនអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលជាកំណត់ទេ មិនអាចទាមទារបាននោះទេ។

## ផ្នែកទី២ ៖ មោឃៈភាព

អត្ថន័យនៃមោឃៈភាពនៃកិច្ចសន្យា ៖ គឺសំដៅលើកិច្ចសន្យាដែលច្បាប់មិនទទួលស្គាល់។ ជនណាក៏អាចអះអាងនូវមោឃៈភាពនៃកិច្ចសន្យានេះបានដែរ។ ច្បាប់មិនបានកំណត់ពីរយៈពេលនៃមោឃៈភាពចំពោះកិច្ចសន្យានេះទេ ។ កិច្ចសន្យាអាចត្រូវមោឃៈភាពដាច់ខាត់ ឬ មិនដាច់ខាត់។ ″ មោឃៈភាពមិនដាច់ខាត ″ ដែលមានចែងក្នុងក្រឹត្យច្បាប់លេខ ៣៨ គឺមានលក្ខណៈស្មើតែដូចគ្នាជាមួយនឹង ការលុបចោល ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ រីឯ ″ មោឃភាពមិនដាច់ខាត ″ ក៏មានសញ្ញាណប្រហាក់ប្រហែលជាមួយនឹង មោឃភាព ដែលមានមានចែងក្នុងក្រមរដ្ឋប្បវេណីផងដែរ ។ មោឃភាពនៃកិច្ចសន្យាមានន័យថា កិច្ចសន្យាមួយមិន

មានអានុភាពតាំងពីដំបូង ។ បានជាគេបង្កើតឱ្យមានមោឃភាពនៃកិច្ចសន្យា ព្រោះដើម្បីកម្រិតនូវសេរីភាពនៃការបង្កើតកិច្ចសន្យា ។ [53]

## ២.១ មូលហេតុនៃមោឃៈភាព

យោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី មូលហេតុដែលនាំឱ្យកិច្ចសន្យាទទួលរងនូវមោឃភាពមានដូចជា៖ ការបង្ហាញឆន្ទៈមិនពិត; ភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ; ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ និងភាពផ្ទុយនឹងទម្រង់នៃច្បាប់។

ហេតុផល៤យ៉ាងដែលនាំឲ្យកិច្ចសន្យាអាចត្រូវបានមោឃៈភាព៖

### ២.១.១ ខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ៖

ខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ កិច្ចសន្យានោះនឹងទទួលរងនូវមោឃភាព ។ បញ្ញត្តិអនុវត្តដោយបង្ខំ សំដៅលើបទបញ្ញត្តិច្បាប់ដែលនៅជាធរមានទាំងឡាយណាដែលបង្ខំឱ្យត្រូវតែអនុវត្តតាម បើមិនដូច្នោះទេ ច្បាប់មិនទទួលស្គាល់អានុភាពគតិយុត្តិនៃកិច្ចសន្យានោះទេ ។

ឧទាហរណ៍ ៖ ការហាមបញ្ចាំផ្តាច់ (មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)

### ២.១.២ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំម្លាប់ល្អ៖

សំដៅដល់អត្ថន័យកិច្ចសន្យាមានភាពផ្ទុយនឹងរបៀបរៀបរយសាធារណៈ និងទំនៀមទម្លាប់ល្អ។ អត្ថ--ន័យ ឬខ្លឹមសារដែលគូភាគីបានព្រមព្រៀងគ្នាបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ឬ ជាកិច្ចសន្យាដែលសង្គមមិនអាចទទួលយកបាន អាចជាកិច្ចសន្យាជួញដូរគ្រឿងញៀន កិច្ចសន្យារួមភេទ ឬកិច្ចសន្យាជួលស្ត្រីពរពោះ ជាដើម ។

ឧទាហរណ៍៖ កិច្ចសន្យាទិញលក់គ្រឿងក្នុងមនុស្ស កិច្ចសន្យាសម្លាប់មនុស្ស ឬ កិច្ចសន្យាឲ្យប្តីប្រពន្ធលែងលះគ្នាជាដើមកិច្ចសន្យាបែបនេះ គឺខុសពីសណ្តាប់ធ្នាប់សាធារណៈទាំងស្រុង ក៏ដូចជាទំនៀមទម្លាប់នៅក្នុងសង្គមជាតិ។

---

[53] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៧

### ២.១.៣ ខុសនឹងទម្រង់ច្បាប់៖

សំដៅដល់ករណីដែលសកម្មភាពចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមានដោយក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត។ ភាពផ្ទុយនឹងទម្រង់នៃច្បាប់ អាចជាករណីសិទ្ធិជួលអចិន្ត្រៃយ៍ ដោយក្រមរដ្ឋប្បវេណីមាត្រា២៤៥ កថាខណ្ឌទី ១ បានបញ្ញត្តិថា ពុំមានអានុភាពឡើយ បើពុំបានធ្វើជាលាយល័ក្ខណ៍អក្សរ ដូច្នេះក្នុងករណីដែលគូភាគីចង់បង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ គឺត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដូចដែលមានចែងក្នុងបញ្ញត្តិច្បាប់។

ឧទាហរណ៍៖ សន្យាទិញលក់ដី និងផ្ទះ ច្បាប់បានកំណត់ថាត្រូវធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរបើគ្រាន់តែធ្វើឡើងដោយផ្ទាល់មាត់ កិច្ចសន្យានោះនឹងមិនមានអានុភាពឡើយ ហើយអាចចាត់ទុកជាមោឃៈភាព។

### ២.១.៤ ការបង្ហាញឆន្ទៈមិនពិត៖

កិច្ចសន្យាដែលបង្កើតឡើងដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ដោយមានការឃុបឃិតជាមួយភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។ [54]ការបង្ហាញឆន្ទៈមិនពិតសំដៅលើការបង្ហាញឆន្ទៈខុសពីការពិត ដែលធ្វើឡើងដោយការឃុបឃិតគ្នាជាមួយភាគីម្ខាងទៀត ។ ប្រសិនបើយើងប្រៀបធៀបការបង្ហាញឆន្ទៈមិនពិតជាមួយបបនីយផ្លូវចិត្ត គឺមានតែភាគីម្ខាងទេដែលដឹងថា ការបង្ហាញឆន្ទៈនោះវាខុសពីការពិត ហើយភាគីនោះនៅតែបង្ហាញឆន្ទៈទៀត ។ ចំណែកឯការបង្ហាញឆន្ទៈមិនពិតដែលជាមូលហេតុនូវមោឃភាពនេះ គឺការបង្ហាញឆន្ទៈធ្វើឡើងដោយការឃុបឃិតគ្នា ភាគីនៃកិច្ចសន្យាទាំងសងខាងដឹងច្បាស់ណាស់ថា កិច្ចសន្យាដែលខ្លួនធ្វើឡើងគ្រាន់តែជាការបំភាន់ភ្នែកអ្នកដទៃតែប៉ុណ្ណោះ ។

ឧទាហរណ៍៖ A បានធ្វើកិច្ចសន្យាលក់ដីL មួយកន្លែងទៅឱ្យ B ក្នុងគោលបំណងទុច្ចរិត ឃុបឃិត ដើម្បីគេចផុតពីម្ចាស់បំណុល C ក្នុងការអនុវត្តសិទ្ធិរឹបអូសតាមផ្លូវតុលាការ ។

[54] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៣

## ២.២ អ្នកមានសិទ្ធិអះអាងអំពីមោឃៈភាព និង វិធីអះអាង

### ២.២.១ អ្នកមានសិទ្ធិ

ផ្អែកតាមមាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី ចំពោះមោឃភាពដាច់ខាតដែលត្រូវបានកំណត់ដោយមូលហេតុដូចមានចែងនៅក្នុងមាត្រា ៣៥៤ អាចអះអាងគ្រប់បុគ្គលទាំងអស់ ។ ក្នុងករណីសកម្មភាពត្រូវចាត់ទុកជា

មោឃៈ នោះបានសេចក្តីថាជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យាបានដែរ ដោយមានលក្ខណៈខុសគ្នាពីការលុបចោល ជាទូទៅការលុបចោល គឺភាគីជាអ្នកធ្វើការអះអាងអំពីការរំលាយនៃកិច្ចសន្យាពីព្រោះជាបុគ្គលទទួលបានផលប្រយោជន៍ ចំណែកឯមោឃភាពមានភាពប៉ះពាល់ជារួមទៅលើសណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់សង្គម ដូច្នេះជនណាក៏មានសិទ្ធិអះអាងនូវមោឃភាពដែរ ។

មោឃភាព ត្រូវកើតឡើងដោយស្វ័យប្រវត្តិ ចំពោះកិច្ចសន្យាដែលមានខ្លឹមសារ ផ្អែកតាមមាត្រា ៣៥៤ និង មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណី ហើយអានុភាពនៃមោឃភាព នាំឲ្យកិច្ចសន្យានោះ ពុំមានអានុភាពតាំងពីដំបូង ហេតុនេះ ពុំមានភាពចាំបាច់ត្រូវធ្វើការបញ្ជាក់អំពីមោឃភាពនៃកិច្ចសន្យាដោយតុលាការនោះទេ។

ឧទាហរណ៍៖ X លក់ទិញដី L ( ដីដែលបានចុះបញ្ជី ) ឲ្យ Y ក្នុងតម្លៃ 100000$ កិច្ចសន្យាលក់ទិញនេះ ធ្វើជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ កិច្ចសន្យាលក់ទិញរវាង X និង Y ពុំមានអានុភាពទេ ពីព្រោះមិនបានធ្វើជាលិខិតយថាភូត ( មូលហេតុនៃមោឃភាព តាមមាត្រា ៣៥៤ កថាខណ្ឌទី ១ ចំណុច ក នៃក្រមរដ្ឋប្បវេណី ) ទោះបីជាគ្មានការបញ្ជាក់ពីតុលាការអំពីមោឃភាពក៏ដោយ ក៏កិច្ចសន្យានេះ គ្មានអានុភាពតាំងពីដំបូង។

### ២.២.២ វិធីអះអាង

អ្នកមានសិទ្ធិអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យានៅពេលណាក៏បាន ដោយមោឃភាពនៃកិច្ចសន្យាពុំមានកំណត់អាជ្ញាយុកាលនោះទេ ។ ការអះអាងអាចជាតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀត អំពីមូលហេតុនាំឱ្យកិច្ចសន្យាមោឃៈភាព ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មាត្រា ៣៥៤ ដោយពុំចាំបាច់ទទួលការយល់ព្រមពីភាគីទទួលដំណឹងនោះទេ កិច្ចសន្យាត្រូវបានរំលាយដោយមោឃៈ ។

## ២.៣ អានុភាពនៃមោឃៈភាព

បើកិច្ចសន្យាត្រូវបានមោឃភាពចោលដោយមូលហេតុណាមួយកិច្ចសន្យានោះត្រូវចាត់ទុកថាគ្មានអានុភាពតាំពីដំបូងមកម្ល៉េះ ហេតុនេះ គ្មានភាគីណាមួយ អាចទាមទារឲ្យអនុវត្តសិទ្ធិ និងករណីកិច្ច ផ្អែកតាមកិច្ចសន្យានោះទេ។ ប៉ុន្តែក្នុងករណីភាគីបានផ្តល់តាវកាលិករួចហើយ ភាគីនោះឲ្យអាចទាមទារឲ្យប្រគល់តាវកាលិកត្រឡប់មកវិញបាន ផ្អែកតាមសេចក្តីចម្រើនដោយឥតហេតុ ( មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ )។ ទោះបីជាបែបនេះក៏ដោយ ចំពោះតាវកាលិកដែលបានទទួលដោយមូលហេតុផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ល្អ ឬច្បាប់ដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ជាអាទិ៍ បុគ្គលដែលបានផ្តល់តាវកាលិកនោះ មិនអាចទាមទារឲ្យប្រគល់វិញបានឡើយ ( មាត្រា ៧៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ )។[55]

### ១.៣.១. អាជ្ញាយុកាលនៃការអះអាងអំពីមោឃៈភាព

អាជ្ញាយុកាលនៃការអះអាងមោឃភាពនៃកិច្ចសន្យា ត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ដែលជាយន្តការមួយប្រើប្រាស់ដើម្បីបញ្ជាក់ថា កិច្ចសន្យាដែលធ្វើឡើងមានអត្ថន័យផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងទម្រង់នៃច្បាប់ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ឬការបង្ហាញឆន្ទៈមិនពិត គឺត្រូវបានចាត់ទុកជាកិច្ចសន្យាគ្មានអានុភាពតាំងពីដំបូងមកម្ល៉េះ ពោលគឺគ្មានកិច្ចសន្យាកើតឡើង។ ការអះអាងអំពីមោឃភាព ពុំមានអាជ្ញាយុកាលទេ ហេតុនេះ ភាគីអាចលើកឡើងអំពីមោឃភាពនៅពេលណាក៏បាន។

សរុបមកយើងអាចនិយាយបានថា ជាទូទៅក្នុងករណីមោឃភាព គឺជនណាក៏អាចធ្វើការអះអាងបានដែរ ប៉ុន្តែចំពោះការលុបចោល អ្នកដែលមានសិទ្ធិអះអាងគឺជាបុគ្គលដែលទាក់ទងនឹងផលប្រយោជន៍កិច្ចសន្យាតែប៉ុណ្ណោះ ជាពិសេសសាមីខ្លួន ឬបុគ្គលមួយចំនួនទៀតដែលច្បាប់បានកំណត់ ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ មាត្រា ៣៥៩ ។

[55] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៤១

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវនិងបកស្រាយខាងលើ យើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថារាល់ការបង្កើតកិច្ចសន្យាទាំងអស់ត្រូវធ្វើឡើងដោយសំណើរ និងស្ទីការត្រូវគ្នា។ សំណើ និងស្ទីការមានអានុភាពទៅបានលុះត្រាតែមានការជូនដំណឹងអំពីស្ទីការ បានមកដល់អ្នកស្នើ ឡើងដោយការព្រមព្រៀងរបស់គូភាគីមានកម្មវត្ថុស្របច្បាប់ហើយធ្វើឡើង ដោយសមត្ថជន នោះកិច្ចសន្យានឹងមានអានុភាពអនុវត្ត ។ ប៉ុន្តែនៅក្នុងករណីមួយចំនួនកិច្ចសន្យាដែលបានបំពេញគ្រប់ល័ក្ខខ័ណ្ឌខាងលើ នៅតែវាត្រូវបានគេលុបចោល ដោយសារមានវិការៈតាមរូបភាពមួយចំនួនដូចជា ការភាន់ច្រឡំ ការឆបោក ការគម្រាម ឬ ការកេងចំនេញហួសហេតុជាដើម នាំឱ្យកិច្ចសន្យាមួយមិនអាចយកជាការបាន មិនមានសុពលភាព ឬមិនអាចអនុវត្តបានទេ។ ធ្ងន់ធ្ងរជាងនេះទៅទៀតកិច្ចសន្យានោះអាចនឹងត្រូវបានលុបចោលវិញ ប្រសិនបើត្រូវបានគេរកឃើញថាមានវិការៈក្នុងការបង្ហាញឆន្ទៈ។ ការលុបចោលកិច្ចសន្យា គឺសិទ្ធិពិសេសមួយដែលកំណត់ដោយច្បាប់ ក្នុងការការពារដល់ភាគីម្ខាងទៀតដែលបានបង្ហាញឆន្ទៈដោយមានវិការៈ ឬចំពោះកិច្ចសន្យាដែលបានធ្វើឡើងដោយវិការៈ។ ការលុបចោលកិច្ចសន្យានេះទៀតសោត ត្រូវធ្វើឡើងនៅក្នុងកំឡុងពេលដែលកំណត់ដោយច្បាប់ ហើយក្រោយពេលដែលភាគីបានអនុវត្តសិទ្ធិលុបចោលនោះហើយ កិច្ចសន្យានោះត្រូវចាត់ទុកថាមោឃៈតាំងពីដំបូង ហើយរាល់សកម្មភាពនៃកិច្ចសន្យាដែលបានអនុវត្តហើយ ត្រូវធ្វើបដិទានឡើងវិញ ។ មោឃៈភាពនៃកិច្ចសន្យា ត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ដែលជាយន្តការមួយប្រើប្រាស់ដើម្បីបញ្ជាក់ថា កិច្ចសន្យាដែលធ្វើឡើងមានអត្ថន័យផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងទម្រង់នៃច្បាប់ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ឬការបង្ហាញឆន្ទៈមិនពិត គឺត្រូវបានចាត់ទុកជាកិច្ចសន្យាគ្មានអានុភាពតាំងពីដំបូងមកម្ល៉េះពោលគឺគ្មានកិច្ចសន្យាកើតឡើង។ ដើម្បីឱ្យកិច្ចសន្យាមួយអាចមានអានុភាព ឬមានសុពលភាពតាមផ្លូវច្បាប់ គូភាគីគួរគប្បីសិក្សាពីទិដ្ឋភាពផ្លូវច្បាប់ មុនឈានចូលដល់ការបង្កើតកិច្ចសន្យា ដើម្បីចៀសវាងកិច្ចសន្យាដែលបានបង្កើតហើយត្រូវទទួលរងនូវការរំលាយកិច្ចសន្យាជាហេតុនាំឱ្យមានការលុបចោល ឬមោឃៈភាព ។ ប៉ុន្តែចំពោះកិច្ចសន្យាដែលត្រូវបានមោឃៈភាពដោយមូលហេតុផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ និងច្បាប់ដែលទាក់ទងនឹងសណ្ដាប់ធ្នាប់សាធារណៈ ភាគីមិនអាចធ្វើការទាមទារឱ្យប្រគល់តាវកាលិកនោះត្រឡប់មកវិញនោះទេ ដោយហេតុថា តាវកាលិកនៃកិច្ចសន្យានោះ អាចជាតាវកាលិកខុសច្បាប់ ដូចជា កិច្ចសន្យាជួញដូរគ្រឿងញៀន កិច្ចសន្យាជួញដូរផ្លូវភេទជាដើម ។

ដើម្បីឱ្យភាគីនៃកិច្ចសន្យាបានបង្ហាញឆន្ទៈពិតរបស់ខ្លួន ចាំបាច់ត្រូវតែមានការយល់ដឹង នឹងស្វែងយល់ឱ្យបានច្បាស់ពីល័ក្ខខ័ណ្ឌ នៃការបង្កើតកិច្ចសន្យា ។ ល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យាមានសារៈសំខាន់ណាស់ ដោយសារកិច្ចសន្យាកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគីដែលមានបំណងក្នុងការបង្កើតកាតព្វកិច្ចសម្រាប់ជាផលប្រយោជន៍ និងជៀសវាងកំហុសកើតឡើងដោយចេតនា និងអចេតនាណាមួយដោយសារមិនគោរពតាមល័ក្ខខ័ណ្ឌ។ ដូចច្នេះប្រសិនបើកិច្ចសន្យាដែលបានបង្កើតហើយ ឬ និងកំពុងតែបង្ហាញឆន្ទៈក្នុងការបង្កើតមានវិការៈ អាចជាមូលហេតុនាំឱ្យមានមោឃៈ ឬការលុបចោលកិច្ចសន្យានោះបាន ។

សរុបសេចក្ដីមក បើទោះជាការបង្កើតកិច្ចសន្យាឡើងដោយមានការ ព្រមព្រៀងគ្នាពីគូភាគីក៏ដោយ នៅពេលដែលកិច្ចសន្យាកំពុងអនុវត្ត ប្រសិនបើភាគីណាម្ខាងអាចកំណត់ថាកិច្ចសន្យានោះមានវិការៈ កិច្ចសន្យានិងត្រូវបានលុបចោលវិញ ឬអាចមោឃភាពទៅវិញបាន ។ កិច្ចសន្យា ត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ដែលជាយន្តការមួយប្រើប្រាស់ដើម្បីបញ្ជាក់ថា កិច្ចសន្យាដែលធ្វើឡើងមានអត្ថន័យផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងទម្រង់នៃច្បាប់ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ឬការបង្ហាញឆន្ទៈមិនពិតជាដើម ។ ដូច្នេះដើម្បីឱ្យកិច្ចសន្យាមួយអាចមានអានុភាព ឬមានសុពលភាពតាមផ្លូវច្បាប់ គូភាគីគួរគប្បីសិក្សាពីទិដ្ឋភាពផ្លូវច្បាប់ មុនឈានចូលដល់ការបង្កើតកិច្ចសន្យា ដើម្បីចៀសវាងកិច្ចសន្យាមានវិការៈដែលអាចធ្វើអោយកិច្ចសន្យាឈានទៅដល់ការលុបចោលបាន ហើយត្រូវទទួលរងនូវមោឃភាពទៀតផង។

# អនុសាសន៍

# អនុសាសន៍

៙❖៙

ក្រោយពីបានធ្វើការស្រាវជ្រាវតាក់តែងអត្ថបទសារណាមួយនេះ ក្រោមប្រធានបទមួយដែលមានចំណងជើងថា " **វិការៈនៃកិច្ចសន្យា** " រួចមកយើងខ្ញុំបានយលឃើញថា កិច្ចសន្យា គឺពិតជាមានសារៈសំខាន់ណាស់ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ សម្រាប់ប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់យើងគ្រប់រូប។ ប្រសិនបើយើងមិនបានធ្វើការសិក្សាស្រាវជ្រាវស្វែងយល់ពីវិការៈនៃកិច្ចសន្យាបានច្បាស់លាស់នោះទេ ពិតណាស់ប្រាកដកើតមន្ទិលសង្ស័យជាបញ្ហាដែលកើតមានឡើងក្នុងការប្រាស្រ័យទាក់ទងជំនួញ របរផ្សេងៗ។ ទន្ទឹមនឹងនេះប្រសិនបើយើងបានសិក្សាស្វែងយល់លម្អិតអំពីវិការៈនៃកិច្ចសន្យាឱ្យបានច្បាស់លាស់ យើងច្បាស់ជាឈានផុតអំពីហានិភ័យ និង បញ្ហាប្រឈមនានានៃការបង្កើតកិច្ចសន្យា និង ការរំលាយកិច្ចសន្យា ។

ស្របពេលប្រទេសជាតិកំពុងមានការអភិវឌ្ឍន៍ មានភាពជឿនលឿនខ្លាំងទៅលើផ្នែកសេដ្ឋកិច្ច ក៏ដូចជាស្ថេរភាពសង្គម ធ្វើឱ្យគ្រប់វិស័យរួមមាន វិស័យការងារ វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម និង វិស័យផ្សេងៗទៀងជាអាទិ៍ បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរមានជីវភាពល្អប្រសើរជាងមុខ ក៏ព្រោះដោយសារការរក្សាបានសុខសន្តិភាព ជាជំហានដែលនាំឱ្យមានអ្នកវិនិយោគទុនទាំងអន្តរជាតិ និង ជាតិ ហេតុនេះហើយយើងគួរគប្បីសិក្សាស្វែលយល់ឱ្យបានលម្អិតទៅលើកិច្ចសន្យា ដែលរួមមានការបង្កើត ការរំលាយនៃកិច្ចសន្យា និងជាពិសេសត្រូវដឹងច្បាស់ពីវិការៈនៃកិច្ចសន្យាតែម្តង ព្រោះដើម្បីយល់ច្បាស់ពីសិទ្ធិរបស់ខ្លួនក្នុងការរំលាយ ក៏ដូចជាការការពារសិទ្ធិរបស់ខ្លួនកុំឱ្យមានការរំលោភបំពានពីសំណាក់ជនទុច្ចរិត ខិលខូច មិនស្មោះត្រង់ប្រកបដោយប្រសិទ្ធិភាព និង យុត្តិធម៌។

ជាចុងក្រោយយើងខ្ញុំទាំងពីររូបដែលជាម្ចាស់នៃស្នាដៃសារណានេះ សង្ឃឹមយ៉ាងមុតមាំថា ប្រធានបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយនេះនឹងចូលរួមចំណែកលើកម្ពស់ដ៏ប្រសើរលើការតាក់តែងចងក្រង ការវិភាគ និង ការសិក្សាស្រាវជ្រាវជុំវិញទិដ្ឋភាពគតិយុត្តនៃកិច្ចសន្យា និង ទិដ្ឋភាពគតិយុត្តដ៏ទៃផ្សេងទៀតនៅក្នុងសង្គមនីតិរដ្ឋកម្ពុជាយើង អោយកាន់តែមានភាពជឿនលឿន និង ការអភិវឌ្ឍនភាព និង និរន្តភាពបន្ថែមទៀតឥតឈប់ឥតឈរជាតរៀងទៅ ។

# ឯកសារយោង

# ឯកសារយោង

៚❖៛

## លិខិតបទដ្ឋានគតិយុត្ត និង ច្បាប់

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០៣០, ចុះថ្ងៃ ០៨ ធ្នូ ២០០៧

ក្រមនីតិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី ០៦ កក្កដា ២០០៦

ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា, ចុះថ្ងៃទី ២៨ តុលា១៩៨៨

សៀវភៅ

- កិច្ចសន្យា រៀបរៀងដោយមេធាវី អ៊ីវ ប៉ូលី ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១
- កិច្ចសន្យាពិសេស រៀបរៀងដោយដោយសាស្ត្រាចារ្យ ឆាយ ហុង
- គណៈកម្មការទទួលបន្ទុកធ្វើសេចក្តីព្រាងរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ១ ដល់ ភាគ ៦

# ឧបសម្ព័ន្ធ

# គំរូកិច្ចសន្យាព្រមព្រៀងជួលដី និង ឃ្លាំង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចសន្យាជួលដី និងឃ្លាំង**

**កិច្ចសន្យាជួលដី និងឃ្លាំងនេះ ធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃទី....... ខែ............ ឆ្នាំ............. ៖**

**រវាង**

លោក/លោកស្រី.................... ភេទ........ អាយុ..........ឆ្នាំ ជនជាតិ........ សញ្ជាតិ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ........................ ចុះថ្ងៃទី......... ខែ........ ឆ្នាំ.............. មានអាសយដ្ឋានផ្ទះលេខ......... ផ្លូវ......... ភូមិ........... សង្កាត់/ឃុំ.................. ខណ្ឌ/ស្រុក........... រាជធានី/ខេត្ត.................................. [តទៅនេះហៅថា **ម្ចាស់ដី និងឃ្លាំងជួល** ឬ**ភាគី"ក"** ] ។

**និង**

លោក/លោកស្រី ........................ភេទ....... **អាយុ**.........ឆ្នាំ ជនជាតិ......... សញ្ជាតិ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ........................... ចុះថ្ងៃទី........ ខែ........... ឆ្នាំ........... មានអាសយដ្ឋានផ្ទះលេខ............ ផ្លូវ.......... ភូមិ......... សង្កាត់/ឃុំ.......... ខណ្ឌ/ស្រុក ................... រាជធានី/ខេត្ត.........................[តទៅនេះហៅថា**អ្នកជួលដី និងឃ្លាំង ឬ ភាគី"ខ"** ] ។

**ភាគី"ក"** និង **ភាគី"ខ"** អាចត្រូវបានហៅរួមថា " **គូភាគី** " ឬហៅដោយឡែកថា " **ភាគី** " ។

**បុព្វបទ**

**ដោយហេតុថា ៖ ភាគី "ក"** គឺជាម្ចាស់កម្មសិទ្ធិករលើអចលនវត្ថុសម្គាល់ដោយវិញ្ញាបនប័ត្រ សំគាល់ម្ចាស់អចលនវត្ថុលេខ: ......................... លេខក្បាលដី............. ទំហំ............ម៉ែត្រការ៉េ ចុះថ្ងៃទី......... ខែ............ ឆ្នាំ............និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ................ លេខក្បាលដី.................... ទំហំ.................ម៉ែត្រការ៉េ ចុះថ្ងៃទី......... ខែ........... ឆ្នាំ................... ចេញដោយមន្ទីររៀបចំដែនដីនគរូប នីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានទីតាំង ស្ថិតនៅភូមិ.................. សង្កាត់/ឃុំ...................... ខណ្ឌ/ស្រុក....................... រាជធានី/ខេត្ត ....................... តទៅនេះហៅរួមគ្នាថា **ដី និងឃ្លាំងជួល**" ។

**ដោយហេតុថា ៖ ភាគី"ក"** មានបំណងជួល ដី និងឃ្លាំងខាងលើនេះឱ្យទៅ**ភាគី"ខ"** ហើយ **ភាគី"ខ"**មានបំណងជួលដី និងឃ្លាំងខាងលើពី**ភាគី"ក"** ស្របតាមល័ក្ខខ័ណ្ឌ និងបទបញ្ញត្តិដែលមានចែងនៅក្នុងកិច្ចសន្យានេះ ។

## ក្រោយពីបានពិភាក្សាគ្នា ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ៖

### ប្រការ ១ ៖ លក្ខណៈ និងទីតាំងនៃដី និងឃ្លាំងជួល

ដី និងឃ្លាំងជួល ដែល**ភាគី "ក"** ជួលឱ្យទៅ**ភាគី "ខ"** មានទំហំ ..............**ម**$^{២}$មានទីតាំងស្ថិតនៅភូមិ.................. សង្កាត់/ឃុំ...................... ខណ្ឌ/ស្រុក............................រាជធានី/ខេត្ត .......................................។

### ប្រការ ២ ៖ កម្មវត្ថុនៃកិច្ចសន្យាជួលដី និងឃ្លាំង

ដី និងឃ្លាំងជួលដែលបានចែងក្នុង**ប្រការ១** ខាងលើ **ភាគី"ក"**មានបំណងជួលឱ្យទៅ**ភាគី"ខ"** ហើយ**ភាគី"ខ"** យល់ព្រមជួលពី **ភាគី"ក"** ដើម្បីបើកធ្វើអាជីវកម្ម...............................................។

### ប្រការ ៣ ៖ រយៈពេលជួល

**ភាគី"ក"** និង **ភាគី"ខ"** បានព្រមព្រៀងគ្នាជួលដី និងឃ្លាំងខាងលើនេះ សម្រាប់រយៈពេល .......................... **ឆ្នាំ** ស្មើនឹង..................... (........................)**ខែ** ដោយចាប់ផ្តើមគិតចាប់ពីថ្ងៃទី........ ខែ............. ឆ្នាំ................ រហូតដល់ថ្ងៃទី........... ខែ............. ឆ្នាំ............។ កិច្ចសន្យាជួលដី និងឃ្លាំងនេះ អាចត្រូវបានបន្តតាមរយៈការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីភាគីទាំងពីរ ។

### ប្រការ ៤ ៖ ថ្លៃឈ្នួល និងការទូទាត់

៤-១ **ភាគី"ក"**យល់ព្រមជួលដី និងឃ្លាំងដូចមានចែងក្នុង **ប្រការ១** ខាងលើនេះឱ្យទៅ**ភាគី"ខ"**ក្នុងតម្លៃថ្លៃឈ្នួលជួលដូចខាងក្រោម ៖

-ឆ្នាំទី១ ៖ ក្នុងតម្លៃ US**$** .................(.....................)**ដុល្លារអាមេរិក**ក្នុងមួយខែ ។

-ឆ្នាំទី២ ៖ ក្នុងតម្លៃ **US$** .................(.....................)**ដុល្លារអាមេរិក**ក្នុងមួយខែ ។

-ឆ្នាំទី៣ ៖ ក្នុងតម្លៃ **US$** .................(.....................)**ដុល្លារអាមេរិក**ក្នុងមួយខែ ។

៤-២ ថ្លៃឈ្នួលប្រចាំខែតាមឆ្នាំនីមួយៗដូចមានចែងក្នុងចំណុច**៤.១**ខាងលើ **ភាគី"ខ"**ត្រូវទូទាត់នៅចន្លោះពីថ្ងៃទី......... ដល់ថ្ងៃទី............ នៃរៀងរាល់ខែនីមួយៗ ។

៤-៣ ភាគី"ខ"ត្រូវបង់ប្រាក់ឈ្នួលជួលដី និងឃ្លាំង ចំនួន**០១(មួយ)ខែ**មុនស្មើនឹងចំនួន **US$**................ (.....................)**ដុល្លារអាមេរិក** ជូន**ភាគី"ក"** មុននឹងចូលធ្វើការបើកអាជីវកម្ម ។

៤.៤ ក្នុងអំឡុងពេលជួលដី និងឃ្លាំង ករណី **ភាគី"ខ"** ខកខាន ឬមិនបានបង់ថ្លៃឈ្នួលជួលដី និងឃ្លាំងចំនួន **០១(មួយ)ខែ** នោះ**ភាគី"ក"**មានសិទ្ធិបញ្ចប់ ឬរំលាយកិច្ចសន្យាជួលដី និងឃ្លាំងនេះជាឯកតោភាគី ។ ចំណែកប្រាក់កក់ដូចមានចែងក្នុង**ប្រការ៥ ចំនុច៥-១** ត្រូវបានជាប្រយោជន៍ទាំងស្រុងរបស់**ភាគី"ក"** ហើយ**ភាគី"ខ"** ត្រូវប្រគល់ទីតាំងជួលដី និងឃ្លាំងនេះឱ្យទៅ**ភាគី"ក"** គ្រប់គ្រងវិញដោយគ្មានល័ក្ខខ័ណ្ឌ ឬតវ៉ាអ្វីឡើយ ។

**ប្រការ ៥ ៖ ប្រាក់កក់**

៥-១ **ភាគី "ខ"** ឯកភាពទូទាត់ប្រាក់កក់ចំនួន **០៣(បី)ខែ** នៃថ្លៃឈ្នួលជួលដី និងឃ្លាំងក្នុងឆ្នាំទី១ដូចមានចែងនៅក្នុង**ប្រការ៤ ចំណុច៤.១** ខាងលើ ដែលស្មើនឹងទឹកប្រាក់ចំនួន **US$ ..................... (........................)ដុល្លារអាមេរិក**ឱ្យទៅ**ភាគី"ក"**(តទៅនេះហៅថា**ប្រាក់កក់**) ។

៥-៣ ប្រាក់កក់នេះ មិនត្រូវបានប្រើប្រាស់សម្រាប់ទូទាត់ថ្លៃឈ្នួលជួលដី និងឃ្លាំងប្រចាំខែសម្រាប់រយៈពេល**០៣(បី)ខែចុងក្រោយ** មុនកាលបរិច្ឆេទបញ្ចប់នៃកិច្ចសន្យាជួលដី និងឃ្លាំងនោះទេ ។ ប្រាក់កក់នេះ ត្រូវប្រើប្រាស់សម្រាប់កាត់ថ្លៃចំណាយដូចជា ៖ ការបង់ពន្ធអាករផ្សេងៗ , ថ្លៃសេវាកម្មទឹក-ភ្លើង , សេវាប្រមូលសំរាម ដែល **ភាគី"ខ"**ខកខានបង់ ។ បន្ទាប់ពីកាត់កងរួចរាល់ ប្រសិនបើមានប្រាក់កក់នៅសល់ **ភាគី"ក"** ត្រូវប្រគល់ជូន**ភាគី"ខ"**វិញក្នុងរយៈពេល១០(ដប់)ថ្ងៃបន្ទាប់ពីកិច្ចសន្យាជួលដី និងឃ្លាំងត្រូវបានបញ្ចប់ ។

**ប្រការ ៦៖ ការប្រគល់ដី និងឃ្លាំងជួល**

**ភាគី "ក"** ត្រូវប្រគល់ដី និងឃ្លាំងជួលឱ្យទៅ**ភាគី "ខ"** នៅថ្ងៃចុះកិច្ចសន្យានេះ ប្រសិនបើគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះពេលវេលាផ្សេងពីនេះ។

**ប្រការ ៧ ៖ ភារកិច្ចបង់ពន្ធអចលនទ្រព្យ**

៧-១ **ភាគី"ក"**ត្រូវទទួលខុសត្រូវបង់ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំនៃដី និងឃ្លាំងជួល និងពន្ធពាក់ព័ន្ធនឹងកម្មសិទ្ធិលើអចលនទ្រព្យជួលស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៨ ៖ ការផ្គត់ផ្គង់ទឹក អគ្គិសនី ការជួសជុល និងសម្ភារៈបំពាក់**

៨-១ **ភាគី"ក"**អនុញ្ញាតឱ្យ**ភាគី"ខ"**ប្រើប្រាស់ប្រព័ន្ធបណ្តាញទឹក-អគ្គិសនីនៅក្នុង និងទីបរិវេណនូវដី និងឃ្លាំងជួលដែលមានស្រាប់ ព្រមទាំងបំពាក់បន្ថែមលើប្រព័ន្ធបណ្តាញទឹក-អគ្គិសនីសម្រាប់សម្របសម្រួលដល់ដំណើរការអាជីវកម្មរបស់**ភាគី"ខ"**(**ប្រសិនបើមានការចាំបាច់**) ។

៨-២ ការជួសជុលប្រព័ន្ធចែកចាយ និងប្រព័ន្ធបង្ហូរទឹកឬប្រព័ន្ធបណ្តាញអគ្គិសនីនៅក្នុង និងទីបរិវេណនូវដី និងឃ្លាំងជួលដែលមានស្រាប់ គឺជាបន្ទុករបស់**ភាគី "ក"** ។

**ប្រការ ៩ ៖ ការចំណាយលើការប្រើប្រាស់ទឹក អគ្គិសនី អនាម័យ និងសេវាផ្សេងៗ**

នៅក្នុងអំឡុងពេលប្រើប្រាសដី និងឃ្លាំងជួល **ភាគី"ខ"** ត្រូវទទួលបន្ទុកបង់ថ្លៃសេវាទឹក-អគ្គិសនីព្រមទាំងអនាម័យ និងសេវាផ្សេងៗទៀតជូនរដ្ឋ ។ **ភាគី"ក"** មិនទទួលខុសត្រូវលើបំណុលដែលមានមុនពេល**ភាគី"ខ"**ចូលកាន់កាប់ទីតាំងជួលឡើយ ។

**ប្រការ ១០ ៖ សិទ្ធិ និងភារកិច្ចរបស់ភាគី "ក"**

១០-១ ភាគី**"ក"**ត្រូវធានា ឬអះអាងថា ដី និងឃ្លាំងដែលជាកម្មវត្ថុនៃការជួលនេះ ពិតជាកម្មសិទ្ធិរបស់ខ្លួនប្រាកដមែន ។ គ្មានអង្គភាព ឬបុគ្គលផ្សេងណាមួយមានកម្មសិទ្ធិ ឬផលប្រយោជន៍តាមរយៈកិច្ចសន្យា ឬសិទ្ធិប្រើប្រាស់ប្រភេទណាមួយលើអចលនទ្រព្យជួលនេះឡើយ ។

១០-២ ភាគី**"ក"**ត្រូវទទួលខុសត្រូវនៅពេលដែលមានតតិយជនណាមួយមកអះអាងអំពីកម្មសិទ្ធិលើដីនិងឃ្លាំងជួលដែលជាកម្មវត្ថុនៃការជួលនេះ ដោយសុខចិត្តចេញមុខដោះស្រាយជូនភាគី**"ខ"**

១០-៣ **ភាគី "ក"** អនុញ្ញាតឱ្យ**ភាគី "ខ"** មានសិទ្ធិប្រើប្រាស់ដី និងឃ្លាំងជួល និងទីបរិវេណដី និងឃ្លាំងជួលទាំងអស់ ដោយគ្មានការរំខានពីសំណាក់ខ្លួន ឬពីសំណាក់ជនដទៃណាផ្សេងឡើយ ។

១០-៣ ភាគី **"ក"** មិនទទួលខុសត្រូវលើដំណើរការការងារអាជីវកម្មរបស់ **ភាគី"ខ"** ដែលផ្ទុយទៅនឹងច្បាប់ជាធរមានឡើយ និងមិនទទួលខុសត្រូវលើការបង់ពន្ធអាករផ្សេងៗពាក់ព័ន្ធនឹងអាជីវកម្មរបស់**ភាគី"ខ"**ឡើយ ។ រាល់សកម្មភាពល្មើសដែលផ្ទុយទៅនឹងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ភាគី **"ខ"** ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។

១០-៤ ក្នុងរយៈពេលជួលនៃកិច្ចសន្យាជួលដី និងឃ្លាំងនេះ ភាគី **"ក"** មិនអាចយកអចលនវត្ថុ( ដី )នេះជួលឱ្យអ្នកផ្សេងទៀតបានឡើយ និងមិនបង្កជាការលំបាកដែលធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មរបស់**ភាគី"ខ"**។

១០-៥ ភាគី **"ក"** មានសិទ្ធិក្នុងការលក់ ឬធ្វើអនុប្បទានដី និងឃ្លាំងជួលបានគ្រប់ពេល ប៉ុន្តែភាគី**"ក"**ត្រូវថាធានាថាអ្នកទិញទទួលអនុវត្តបន្តនូវកិច្ចសន្យាជួលអចលនទ្រព្យនេះ រហូតដល់ចប់រយៈពេលជួលដី និងឃ្លាំង ព្រមទាំងជូនដំណឹងទៅភាគី **"ខ"** ។

**ប្រការ ១១ ៖ សិទ្ធិ និងភារកិច្ចរបស់ភាគី"ខ"**

១១-១ ភាគី**"ខ"**ត្រូវទូទាត់ប្រាក់ថ្លៃឈ្នួលដីនិងឃ្លាំងជួលជូនភាគី **"ក"** ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលាកំណត់ដូចមានចែងក្នុង**ប្រការ ៤ ចំណុច៤.១** ខាងលើ ។

១១-២ ភាគី"**ខ**"មិនអាចផ្ទេរសិទ្ធិលើការជួលដី និងឃ្លាំង ឬអនុប្បទានដី និងឃ្លាំងជួល ទោះបីជាដោយផ្នែក ឬទាំងស្រុងឱ្យតតិយជនឡើយ ទោះក្រោមអត្ថន័យ និងទម្រង់បែបណាក៏ដោយ ប្រសិនបើគ្មានការយល់ព្រមជាមុនពី**ភាគី"ក"** ។

១១-៣ ភាគី"**ខ**"ត្រូវទទួលខុសត្រូវលើការបង់សេវាកម្មនានា និងបំណុលផ្សេងទៀតដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន និងត្រូវទទួលខុសត្រូវបង់ពន្ធអាករផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន និងត្រូវទទួលខុសត្រូវបង់ពន្ធអាករផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួនទាំងអស់ ។

១១-៤ រាល់ហានិភ័យកើតឡើងដែលជាកំហុសរបស់ភាគី "**ខ**" នោះភាគី "**ខ**" ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទាំងស្រុង ។

១១-៥ ក្នុងអំឡុងពេលជួលដី និងឃ្លាំង ភាគី "**ខ**" ត្រូវគ្រប់គ្រងអចលនទ្រព្យជួលដោយប្រុងប្រយ័ត្ន ។ ករណីមានអគ្គីភ័យឆេះដី និងឃ្លាំងជួលដែលបង្កឡើងដោយ **ភាគី"ខ"** នោះភាគី"ខ"ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាតទាំងអស់ដែលមានលើដី និងឃ្លាំងជួលចំពោះ **ភាគី"ក"** ។ **ភាគី"ខ"**មិនទទួលខុសត្រូវលើការខូចខាតដែលមិនមែនបណ្តាលមកពីកំហុសរបស់ភាគី"ខ"ឡើយ។

**ប្រការ ១២ ៖ ការគ្រប់គ្រង និងការថែទាំដី និងឃ្លាំងជួល**

ក្នុងអំឡុងពេលជួលដី និងឃ្លាំង **ភាគី"ខ"** ត្រូវគ្រប់គ្រង ថែទាំទ្រព្យ ដែលមាននៅក្នុងដី និងឃ្លាំងជួល និងទីបរិវេណដី និងឃ្លាំងជួលឱ្យបានល្អ សម្រាប់ការប្រើប្រាស់ជាប្រក្រតីប្រចាំថ្ងៃ និងទុកជូនប្រគល់ជូន**ភាគី "ក"** នៅពេលបញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំងនេះ លើកលែងតែការខូចខាតដី និងឃ្លាំងជួលដែលបណ្តាលមកពីការសឹករិចរិលធម្មជាតិ ឬដល់អាយុកាលដោយការប្រើប្រាស់ ។

**ប្រការ ១៣ ៖ ការបញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំង**

១៣-១ នៅក្នុងករណី**ភាគី "ក"** បញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំងមុនកាលកំណត់ ដោយគ្មានកំហុសរបស់ **ភាគី"ខ"** នោះ **ភាគី"ក"** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ភាគី"ខ"** យ៉ាងហោចណាស់**០៣(បី) ខែ**មុន ហើយសុខចិត្តផ្តល់សំណងការខូចខាត និងជម្ងឺចិត្តជាទឹកប្រាក់ស្មើនឹង **០២ (ពីរ) ដង** នៃប្រាក់កក់ដូចមានចែងក្នុង**ប្រការ ៥** ជូនមក **ភាគី "ខ"** ។

១៣-២ នៅក្នុងករណី**ភាគី"ខ"** បញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំងមុនកាលកំណត់ ដោយគ្មានកំហុសរបស់**ភាគី "ក"** នោះ **ភាគី"ខ"** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ភាគី"ក"** យ៉ាងហោចណាស់០២ **(ពីរ) ខែ**មុន ហើយប្រាក់កក់ត្រូវទុកជាប្រយោជន៍របស់ភាគី"ក" ។

**ប្រការ ១៤ ៖ ការបំពេញបែបបទចាកចេញពីដី និងឃ្លាំងជួល**

១៤-១ មុនពេលបញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំង ទោះបីក្នុងករណីណាក៏ដោយ **ភាគី"ខ"** ត្រូវដោះស្រាយពន្ធអាករ-ការចំណាយផ្សេងៗ (សេវាសំរាម ទឹក-អគ្គីសនី អនាម័យ និងសេវាផ្សេងៗ-ល-) ជាមួយអាជ្ញាធររដ្ឋ ឬតតិយជន ។ ក្នុងករណីមិនទាន់ត្រូវបានដោះស្រាយចប់សព្វគ្រប់ដោយសារការធ្វេសប្រហែស ឬដោយសារស្ថានភាពណាមួយផ្សេងទៀត នោះ**ភាគី "ខ"** ត្រូវទទួលខុសត្រូវដោះស្រាយរហូតទាល់តែចប់សព្វគ្រប់ ។

១៤-២ នៅពេលបញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំង **ភាគី "ខ"** ត្រូវប្រគល់ដី និងឃ្លាំងជួលដូចមានចែងក្នុង**ប្រការ ១** ខាងលើ និងសម្ភារៈបំពាក់ផ្សេងៗដែលជារបស់**ភាគី"ក"**ឱ្យមកភាគី**"ក"**វិញ ។

**ប្រការ ១៥ ៖ អំពីការបន្តកិច្ចសន្យា**

នៅរយៈពេល០៣(បី) ខែ មុនពេលបញ្ចប់កិច្ចសន្យាជួលដី និងឃ្លាំង ភាគី **"ក"** ត្រូវផ្តល់អាទិភាពឱ្យភាគី**"ខ"** ដើម្បីពិភាក្សាអំពីការជួលបន្ត ។ ចំណែកឯថ្លៃឈ្នួលជួលបន្ត គូភាគីនឹងពិភាក្សាគ្នាតាមការជាក់ស្តែង ។

**ប្រការ ១៦ ៖ អំពីការកែប្រែ ឬការផ្លាស់ប្តូរ**

១៦-១ ភាគីទាំងពីរត្រូវអនុវត្ត និងបំពេញកាតព្វកិច្ចទាំងឡាយ ដែលចែងក្នុងកិច្ចសន្យាជួលដី និងឃ្លាំងនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពបំផុត ដោយមិនអាចកែប្រែខ្លឹមសារ ឬលក្ខខណ្ឌណាមួយជាឯកតោភាគីបានឡើយ លើកលែងតែភាគីទាំងពីរបានព្រមព្រៀងគ្នាយ៉ាងពិតប្រាកដក្នុងការកែប្រែ ផ្លាស់ប្តូរខ្លឹមសារ ឬលក្ខខ័ណ្ឌណាមួយនៅក្នុងកិច្ចសន្យាជួលអចលនទ្រព្យនេះ ។

១៦-២ ក្នុងករណីភាគីណាមួយចង់កែប្រែខ្លឹមសារ ឬលក្ខខណ្ឌណាមួយនៅក្នុងកិច្ចសន្យាជួលដី និងឃ្លាំងនេះ ត្រូវតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីគូភាគី ។

**ប្រការ ១៧ ៖ ករណីប្រធានសក្តិ**

ក្នុងករណីមានគ្រោះធម្មជាតិ អគ្គីភ័យ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី បន្ទុះភ្នំភ្លើង ឬ បទបញ្ជារាជរដ្ឋាភិបាលជាដើមកើតឡើងបណ្តាលឱ្យអចលនទ្រព្យដែលជាកម្មវត្ថុនៃកិច្ចសន្យាជួលដី និងឃ្លាំងត្រូវបានខូចខាត ឬបាត់បង់នាំឱ្យជាមូលហេតុនៃការរំលាយកិច្ចសន្យានេះ ភាគីទាំងសងខាងត្រូវរួចផុតពីការទទួលខុសត្រូវទៅលើសំណងនៃការខូចខាតចំពោះគ្នាទៅវិញទៅមក ។

**ប្រការ ១៨ ៖ អំពីវិធានច្បាប់ និង ការដោះស្រាយវិវាទ**

១៨-១ ភាគីទាំងពីរត្រូវអនុវត្តខ្លឹមសារ ដែលមានចែងក្នុងកិច្ចសន្យាជួលដី និងឃ្លាំងនេះយ៉ាងម៉ឺងម៉ាត់បំផុត និងទទួលខុសត្រូវខ្ពស់បំផុត ហើយក្នុងករណីដែលមានភាគីណាមួយបំពាន ឬមិនបំពេញកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាជួលដី និងឃ្លាំងនេះ ភាគីនោះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

១៨-២ ករណីមានវិវាទកើតឡើងដោយថាហេតុ ភាគីទាំងពីរត្រូវព្យាយាមដោះស្រាយវិវាទនោះដោយសន្តិវិធី និងយោគយល់គ្នាខ្ពស់បំផុត។

១៨-៣ ករណីដែលវិវាទនោះមិនអាចដោះស្រាយដោយសន្តិវិធីបាន ភាគីទាំងពីរបានឯកភាពយកវិវាទនោះទៅដោះស្រាយនៅស្ថាប័នតុលាការដែលមានសមត្ថកិច្ច ដោយផ្អែកលើច្បាប់ និងបទបញ្ញារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១៩ ៖ អំពីការបកស្រាយកិច្ចសន្យា**

១៩-១ កិច្ចសន្យាជួលដី និងឃ្លាំងនេះ ត្រូវបានបកស្រាយដោយឈរលើគោលការណ៍ស្មើភាពគ្នារវាងភាគីទាំងពីរដោយមិនមានការលំអៀងឬប្រឆាំងនាំឱ្យខូចប្រយោជន៍ភាគីណាមួយឡើយ ។

១៩-២ ក្នុងករណីមានការភាន់ច្រឡំទៅលើពាក្យពេចន៍ ឬឃ្លាណាមួយនៅក្នុងកិច្ចសន្យាជួលដី និងឃ្លាំងនេះ ភាគីត្រូវបកស្រាយដោយឈរលើគោលការណ៍ព្រមព្រៀង ប៉ុន្តែប្រសិនបើភាគីនៅតែមានការខ្វែងគំនិតគ្នាដដែល នោះកិច្ចសន្យាជួលដី និងឃ្លាំងនេះត្រូវបកស្រាយដោយយកច្បាប់ធ្វើជាគោល ។

**ប្រការ ២០ ៖ អំពីអានុភាពអនុវត្តកិច្ចសន្យា**

កិច្ចសន្យាជួលដី និងឃ្លាំងនេះមានអានុភាពអនុវត្ត ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំនេះតទៅ ។

**ប្រការ ២១ ៖ អំពីការធ្វើកិច្ចសន្យា**

ភាគីទាំងពីរបានអាន និងពិនិត្យនូវរាល់ខ្លឹមសារដែលមានចែងក្នុងកិច្ចសន្យាជួលដី និងឃ្លាំងនេះទាំងអស់យ៉ាងល្អិតល្អន់ និងប្រុងប្រយ័ត្នខ្ពស់បំផុតទើបយល់ព្រមផ្តិតមេដៃស្តាំ ឬចុះហត្ថលេខាលើកិច្ចសន្យាជួលដី និងឃ្លាំងនេះទុកជាភស្តុតាង។

**ប្រការ ២២ ៖ អំពីការរក្សាទុកកិច្ចសន្យា**

កិច្ចសន្យាជួលដី និងឃ្លាំងនេះ ធ្វើឡើងជាភាសាខ្មែរ ចំនួន ០៣ ច្បាប់ ដែលមានតម្លៃស្មើៗគ្នា ហើយត្រូវរក្សាទុកនៅៈ - **ភាគី "ក"** ចំនួន ០១ ច្បាប់ - **ភាគី "ខ"** ចំនួន ០១ ច្បាប់ - **មេធាវី** ចំនួន ០១ ច្បាប់ ។

រាជធានីភ្នំពេញ ,ថ្ងៃទី........ ខែ.......... ឆ្នាំ.........

ស្នាមមេដៃស្តាំ **ភាគី "ក"**

ស្នាមមេដៃស្តាំ **ភាគី "ខ"**

**ឈ្មោះ**...............................

**ឈ្មោះ**.............................